MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង
# នៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ
## សំរាប់អាងទន្លេមេគង្គភាគខាងក្រោម





**យុទ្ធសាស្ត្រអភិវឌ្ឍន៍ផ្អែកតាម IWRM នេះត្រូវបានអនុម័តដោយក្រុមប្រឹក្សា MRC ក្នុងអំឡុងកិច្ចប្រជុំលើកទី១៧ របស់ខ្លួនកាលពី ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១ កន្លងទៅ។** សមាជិកក្រុមប្រឹក្សា MRC បានប្រមើលឃើញថា ការអនុវត្តយុទ្ធសាស្ត្រនេះនឹងជួយជម្រុញដល់កិច្ចសហប្រតិបត្តិការក្នុងតំបន់ជួយដល់កិច្ចអភិវឌ្ឍធនធានទឹកដោយចីរភាព និងផ្តោតលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការពារប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅ។ បណ្តាប្រទេសទាំងនេះបានអំពាវនាវប្រជាជនដែលរស់នៅក្នុងអាងឱ្យចូលរួមអនុវត្តយុទ្ធសាស្ត្រនេះយ៉ាងសកម្ម និងផ្តោតលើតម្រូវការសម្រាប់កសាងសមត្ថភាព និងចូលរួមសិក្សាស្រាវជ្រាវ។

# អារម្ភកថា

**តាងនាមឱ្យក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ (MRC)** ខ្ញុំមានក្តីសោមនស្សរីករាយជាពន្លឹកក្នុងការបង្ហាញជូននូវយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេមេគង្គភាគខាងក្រោម(LMB) ដោយមានការចូលរួមសហការ និងការរៀបចំពីបណ្តាប្រទេសជាសមាជិកនៃគណៈកម្មការទន្លេមេគង្គ (កម្ពុជា ឡាវ ថៃ និងវៀតណាម) ផ្អែកទៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ។

ដោយមានការព្រមព្រៀងពីក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ ការចូលរួមរៀបចំយុទ្ធសាស្ត្រនេះគឺ ជាសមិទ្ធិផលសំខាន់មួយឆ្ពោះទៅការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គដោយចីរភាព។ យុទ្ធសាស្ត្រនេះ ស្របតាមសេចក្តីថ្លែងការណ៍នៃជំនួបកំពូលរបស់គណៈកម្មការទន្លេមេគង្គលើទី១ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០ នៅហួហ៊ីន ប្រទេសថៃ ដោយទទួលស្គាល់ថាភាពជឿនលឿននៃការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធដទៃទៀត និងជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅក្នុងតំបន់ ប៉ុន្តែទន្ទឹមនេះក៏មានការទទួលស្គាល់ដែរថាអាចមានផលប៉ះពាល់អវិជ្ជមានដែលតម្រូវឱ្យយកចិត្តទុកដាក់បរិស្ថានអាងបានពេញលេញ ។

ចាប់តាំងពីចុះហត្ថលេខាដំបូងលើកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ បានចូលរួមចែករំលែកការយល់ដឹងអំពីកាលានុវត្តភាព និងហានិភ័យនៃផែនការជាតិសម្រាប់ការអភិវឌ្ឍ និងបានឯកភាពទៅលើអាទិភាពយុទ្ធសាស្ត្រមួយចំនួន ដើម្បីធ្វើឱ្យប្រសើរដល់កាលានុវត្តភាពអភិវឌ្ឍន៍ និងកាត់បន្ថយភាពមិនច្បាស់លាស់ និងហានិភ័យដែលពាក់ព័ន្ធឱ្យដល់កម្រិតអប្បបរមា។ កត្តានេះជួយដល់ការអនុវត្តនីតិវិធីដែលបានឯកភាពក្រោមកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ ឱ្យបានសម្រេចទាន់ពេលវេលា ។

ប្រទេសដែលជាសមាជិកបានទទួលស្គាល់នូវតម្រូវការ ដើម្បីបន្តអភិវឌ្ឍន៍កាលានុវត្តភាព ទាក់ទងនឹងទឹក (កាត់បន្ថយហានិភ័យពីទឹកជំនន់និង គ្រោះរាំងស្ងួត ជលផល និងនាវាចរណ៍) ក៏ដូចជាកាលានុវត្តភាពក្រៅ ពីវិស័យទឹកដែលផ្តល់លទ្ធភាពសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងដើម្បីឆ្ពោះទៅការអភិវឌ្ឍអាងប្រកបដោយចីរភាព ។

ប្រទេសដែលជាសមាជិកទទួលស្គាល់នូវអាទិភាពបន្ទាន់ ដើម្បីអភិវឌ្ឍន៍ និងឯកភាពលើកម្មវត្ថុ សង្គម និងបរិស្ថានអាង និងសូមយកមូលដ្ឋានយ៉ាងទូលំទូលាយសម្រាប់ធ្វើការពិចារណា និងដើម្បីអនុវត្តកិច្ចអភិវឌ្ឍន៍ និងណែនាំការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនេះនាពេលអនាគត។

យើងយល់ដឹងពីសារៈសំខាន់ចាំបាច់នៃការគ្រប់គ្រងអាងដែលត្រូវពង្រឹង និងជាពិសេសលើកម្មវិធី ផ្អែកកសាងសមត្ថភាពធនធានមនុស្សក្នុងការអភិវឌ្ឍអាងប្រកបដោយចីរភាព ការចាត់ចែងរៀបចំ សមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស។ ការអនុវត្តយុទ្ធសាស្ត្រនេះដោយជោគជ័យ ត្រូវទាមទារឱ្យមានការប្តេជ្ញាពីបណ្តាប្រទេសនៅក្នុងអាងទន្លេមេគង្គទាំងពីរអ្នកអភិវឌ្ឍគម្រោង និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងកិច្ចប្រឹងប្រែងឱ្យបានប្រសើរបំផុតលើសកម្មភាពគ្រប់គ្រងទឹក និងធនធានទាក់ទងនានា ជាមួយក្របខ័ណ្ឌដែលបានលំអិតនៅក្នុងយុទ្ធសាស្ត្រនេះ ។

តាងនាមឱ្យក្រុមប្រឹក្សាគណៈកម្មាទន្លេមេគង្គ ខ្ញុំស្នើសូមលើកទឹកចិត្តឱ្យមានការចូលរួមសហការ គាំទ្រជាមួយការងាររបស់យើងនៅក្នុងយុទ្ធសាស្ត្រនេះ ។



Pham Khoi Nguyen
ប្រធានក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ
ឆ្នាំ២០១០-២០១១

# សេចក្តីសង្ខេប

## ការទទួលយកយុទ្ធសាស្ត្រ ចំណុចគោលសំខាន់

ការរៀបចំនិងការទទួលយកនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ដោយបណ្តាលប្រទេសនៅអាងទន្លេមេគង្គភាគខាងក្រោម (LMB) គឺជាចំណុចគោលសំខាន់មួយនៅក្នុងប្រវត្តិនៃកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌគណៈកម្មាការទន្លេមេគង្គ ចំពេលដែលអាង និងទន្លេមេគង្គ ដែលជាទន្លេធំក្នុងចំណោមទន្លេធំជាងគេនានាក្នុងពិភពលោកកំពុង ត្រូវបានគេមើលឃើញថាមានការប្រែប្រួលយ៉ាងខ្លាំង។ ការប្រែប្រួលទាំងនេះរួមមានទាំងការប្រែប្រួលផ្នែកប្រជាសាស្ត្រ សេដ្ឋកិច្ច ធាតុអាកាស និងវារីសាស្ត្រ ដែលទទួលរងឥទ្ធិពលពីចលករថ្នាក់ជាតិ កម្រិតតំបន់ និងកម្រិតពិភពលោក។

ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ចតម្រូវឱ្យមានការអភិវឌ្ឍធនធានទឹកសម្រាប់គោលបំណងច្រើនយ៉ាង រួមទាំងផលិតផលថាមពល ផលិតកម្មកសិកម្ម និងជលផល និងការធ្វើពាណិជ្ជកម្មតាមទន្លេ។ ប្រការនេះ ក៏ទាមទារផងដែរនូវការគ្រប់គ្រងទន្លេ និងជីវភាពប្រព័ន្ធអេកូឡូស៊ីរបស់ទន្លេ ដើម្បីធានានិរន្តរភាពសម្រាប់រយៈពេលវែង។ ការធានានិរន្តរភាពសម្រាប់រយៈពេលវែងដែលកាន់តែលំបាកខណៈ ដែលទន្លេមេគង្គកំពុងប្រឈមនឹងការប្រែប្រួលអាកាសធាតុ។

ការអភិវឌ្ឍនៅតំបន់ឡានឆាងនៅក្នុងអាងទន្លេមេគង្គភាគខាងលើក្នុងប្រទេសចិន និងនៅតំបន់អាងទន្លេមេគង្គភាគខាងក្រោមកំពុងធ្វើឱ្យមានការផ្លាស់ប្តូររបបលំហូរនៅទន្លេមេគង្គ ។ បច្ចុប្បន្នវិស័យឯកជនកំពុងស្វែងរក កាលានុវត្តភាពវិនិយោគយ៉ាងសកម្ម ដើម្បីបំពេញកំណើនតម្រូវការ ផលិតផលនិងសេវាកម្ម ដែលទន្លេនេះអាចផ្តល់បាន ប្រសិនបើមានប្រព័ន្ធនិយ័តកម្មប្រកបដោយប្រសិទ្ធភាពត្រឹមត្រូវមួយមាននៅនឹងន្លែង។

យុទ្ធសាស្ត្រនេះ គឺជាការឆ្លើយតបមួយដែលមានអត្ថប្រយោជន៍ និងអាចធ្វើទៅបានដោយប្រទេសនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនេះ។ ការឆ្លើយតបអាចមានដូចជា តាមរយៈការដកចេញនូវរបាំងដែលរារាំងដល់កាលានុវត្តភាពនៃកិច្ចអភិវឌ្ឍន៍ទន្លេមេគង្គដោយចីរភាព។

ចំណុចសំខាន់នៃយុទ្ធសាស្ត្រនេះ គឺចំណាត់ការលើសកិច្ចសហប្រតិបត្តិការ ជាពិសេសលើការទទួលបានចំណេះដឹង ឆ្ពោះទៅរកកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រង និងការអភិវឌ្ឍទឹក និងចំណាត់ការលើសពីការធ្វើផែនការតាមវិស័យនៅកំរិតថ្នាក់ជាតិឆ្ពោះទៅការធ្វើផែនការអាងឱ្យបានទូលំទូលាយ ។

## យុទ្ធសាស្ត្រ: កសាងមូលដ្ឋានគ្រឹះរឹងមាំ

មូលដ្ឋានគ្រឹះសម្រាប់យុទ្ធសាស្ត្រនេះ មានចែងក្នុងកិច្ចព្រមព្រៀង ដើម្បីសហប្រតិបត្តិការដោយចីរភាពនៃអាងទន្លេមេគង្គឆ្នាំ១៩៩៥។យុទ្ធសាស្ត្រនេះជាការឆ្លើយតបចំបងរបស់គណៈកម្មការទន្លេមេគង្គ ចំពោះមាត្រា២ ដែលអំពាវនាវអោយមាន ការបង្កើតផែនការអភិវឌ្ឍអាង ដើម្បីកំណត់ធ្វើចំណាត់ថ្នាក់ និងធ្វើអាទិភាពគម្រោង និងកម្មវិធីនានាសំដៅស្វែងរកការជួយគាំទ្រការអនុវត្តនៅកម្រិតទូទាំងអាងទន្លេមេគង្គ។ មូលដ្ឋាននេះ បង្ហាញផ្លូវគោលសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ទឹក នៅអាងទន្លេមេគង្គភាគខាងក្រោមប្រកបដោយចីរភាពនិង ដោយមានកិច្ចសហប្រតិបត្តិការដោយទទួលស្គាល់ថាទិន្នន័យ និងចំណេះដឹងនៅមានកំណត់ និងទទួលស្គាល់អំពីភាព ចាំបាច់បន្ទាន់សម្រាប់សកម្មភាព ដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍន៍ និងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង។

ដូច្នេះ យុទ្ធសាស្ត្រនេះកំណត់ដំណើរការធ្វើផែនការអភិវឌ្ឍអាងយ៉ាងសកម្មដែលនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំ សំដៅធានាថាការឆ្លើយតប និងចំណេះដឹងថ្មីៗ។ ការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនេះលើកទីមួយ ត្រូវបានគេរំពឹងថានឹងធ្វើក្នុងឆ្នាំ២០១៥ ។

## យុទ្ធសាស្ត្រស្តីពីកាលានុវត្តភាព និងហានិភ័យដែលពាក់ព័ន្ធ

កាលានុវត្តភាពអភិវឌ្ឍន៍ទឹកនៅអាងទន្លេមេគង្គភាគខាងក្រោម មានច្រើនដែលអាចផ្តល់ផលប្រយោជន៍សំខាន់នៅថ្នាក់ជាតិ និងតាមរយៈកិច្ចសហប្រតិបត្តិការនៅថ្នាក់តំបន់។ កាលានុវត្តភាពនេះ ក៏មានហានិភ័យ និងផលវិបាកធំផង ដែរដែលចាំបាច់ត្រូវមានការគ្រប់គ្រងនិងកាត់បន្ថយទាំងនៅថ្នាក់ជាតិ និងនៅកម្រិតពាក់ព័ន្ធទាំងអស់តាមរយៈ កិច្ចសហប្រតិបត្តិការនៅគ្រប់កម្រិតអន្តរព្រំដែនទាំងអស់។ យុទ្ធសាស្ត្រនេះកំណត់អត្តសញ្ញាណនៃកាលានុវត្តភាព និងហានិភ័យដែលពាក់ព័ន្ធដូចតទៅ :

- សក្តានុពលធំធេញជាច្រើនសម្រាប់ការអភិវឌ្ឍវារីអគ្គីសនីនៅតាមដៃទន្លេ ជាពិសេសនៅប្រទេសឡាវ និងកម្ពុជា ដែលទាមទារឱ្យមានស្តង់ដាបរិស្ថាន និងសង្គមរួមមួយដើម្បីធានានិរន្តរភាព។

- សក្តានុពលធំៗសម្រាប់ពង្រីក និងកំណត់អត្តសញ្ញាណផលិតកម្មកសិកម្មដោយប្រព័ន្ធស្រោចស្រពសំដៅបង្កើនសន្តិសុខស្បៀងក្នុងនោះរួមទាំងការប្រើប្រាស់ទឹកពីទន្លេមេគង្គភាគខាងក្រោម និងដើម្បីទប់ទល់ ការហូរចូលទឹក ប្រៃមកកាន់តំបន់ដីសណ្តរយោងទៅតាមការសម្របសម្រួលនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដទៃទៀតនៃទន្លេមេគង្គសំដៅ ធ្វើប្រតិបត្តិការរក្សាទំនប់វារីអគ្គីសនីដែលកំពុងដំណើរការ និងក្នុងគម្រោងក្នុងន័យធានាបានភាពល្អប្រសើរថែមទៀតសំរាប់ការត្រួតពិនិត្យ និងរក្សាបាននូវលំហូរទឹកនៅរដូវប្រាំង។

- សក្តានុពលសម្រាប់ការអភិវឌ្ឍវារីអគ្គីសនីនៅតាមទន្លេមេ ប្រសិនបើភាពមិនច្បាស់លាស់ និងហានិភ័យត្រូវបានដោះស្រាយទាំងស្រុងនិងការ វាយតម្លៃកំរិតឆ្លងព្រំដែនតំបន់ព្រមទាំងដំណើរ

ការឯកភាពគ្នាត្រូវបានអនុវត្ត។ ទោះបីជាផលប្រយោជន៍ ដែលអាចមានខ្ពស់ពិតមែន ការចំណាយក៏មានខ្ពស់ដែរ រួមទាំង ផលប៉ះពាល់នៅតាមឆ្លងព្រំដែន និង

- សក្តានុពលសម្រាប់ការអភិវឌ្ឍទាក់ទងនឹងទឹកជាអាទិភាព (ជលផល នាវាចរណ៍ ការគ្រប់គ្រងស្ងៀងនិង គ្រោះរាំងស្ងួត ទេសចរណ៍និងបរិស្ថាន និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី) ក៏ដូចជាទៅលើបញ្ហាផ្សេងៗទៀត ក្រៅពីវិស័យទឹកផងដែរ ជម្រើសនៃការផលិតថាមពលផ្សេងៗ ។

## យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍអាង

យុទ្ធសាស្ត្រនេះ ឱ្យនិយមន័យពីដំណើរការមួយដើម្បីឈានពីកាលានុវត្តភាពទៅរកការអនុវត្ត និងការអភិវឌ្ឍដោយចីរភាព ដែលក្នុងនោះរួមមានទាំងកំណត់និយមន័យសំរាប់អាទិភាពជាយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍអាងដូចតទៅ ៖

- កាលានុវត្តភាព និងហានិភ័យនៃការអភិវឌ្ឍបច្ចុប្បន្ន (ដល់ឆ្នាំ២០១៥) ត្រូវបានដោះស្រាយរួមទាំងការសម្របសម្រួលរវាងបណ្តាប្រទេសអាងទន្លេមេគង្គភាគខាងក្រោម និងកិច្ចសហប្រតិបត្តិការជាមួយចិនដែលសម្រេចបាន សំដៅធានាការកើនឡើងនៃលំហូរទឹកនៅរដូវប្រាំងការអនុវត្តកិច្ចព្រមព្រៀង ស្តីអំពីការរក្សាលំហូរ នៃផ្លូវទឹកនៅតាមតំបន់អាងទន្លេមេគង្គភាគខាងក្រោម ដែលបានអនុវត្ត និងហានិភ័យនៃគម្រោងដែលត្រូវគ្រប់គ្រង។

- កសិកម្មតាមរយៈប្រព័ន្ធស្រោចស្រពសម្រាប់សន្តិសុខស្បៀង និងលប់បំបាត់ភាពក្រីក្រត្រូវបានពង្រីក និងពង្រឹងកាន់តែខ្លាំង។

- និរន្តរភាពសង្គមនិងបរិស្ថាននៃការអភិវឌ្ឍវារីអគ្គីសនី ត្រូវបានពង្រីកយ៉ាងទូលំទូលាយ។

- ចំណេះដឹងសំខាន់ត្រូវបានទទួល ដើម្បីដោះស្រាយពីភាពមិនច្បាស់លាស់ និងការកាត់បន្ថយហានិភ័យ នៃកាលានុវត្តន៍ភាពអភិវឌ្ឍន៍ដែលអាចកើតឡើង។ ចំណេះដឹងទាំនោះរួមមានចំណេះ ដឹងអំពីបម្លាស់ទី និងការប្រែប្រួលនូវបរិមាណត្រី កំណក និងលំហូរកករ(ដីល្បាប់) និងជីវជាតិនានាបម្រែបម្រួលជីវចម្រុះ និងផលប៉ះពាល់ជីវភាពរស់នៅនិងសង្គម។

- ជម្រើសសម្រាប់ចែករំលែកផលប្រយោជន៍ពីការអភិវឌ្ឍ និងហានិភ័យដែលបានកំណត់។

- យុទ្ធសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុ។

- ការពិចារណាលើផែនការអាង ដែលត្រូវបានបញ្ចូលទៅក្នុងការធ្វើផែនការថ្នាក់ជាតិ និងទៅក្នុងប្រព័ន្ធនិយ័តកម្មថ្នាក់ជាតិ។

## យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងអាងទន្លេ

យុទ្ធសាស្ត្រនេះកំណត់អាទិភាពជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងអាង។ យុទ្ធសាស្ត្រនេះមានសារៈសំខាន់ដើម្បីធានាឱ្យការអភិវឌ្ឍអាងមាននិរន្តរភាព ដូចខាងក្រោមនេះ ៖

- គោលបំណង និងយុទ្ធសាស្ត្រគ្រប់គ្រងអាងត្រូវបានកំណត់សម្រាប់វិស័យទាក់ទងនឹងទឹកក្នុងនោះ មានជលផល ការគ្រប់គ្រងស្បៀង និងគ្រោះរាំងស្ងួត ការគ្រប់គ្រងតំបន់ដីសើម និងនាវាចរណ៍។

- ដំណើរការគ្រប់គ្រងធនធានទឹកនៅកម្រិតជាតិត្រូវបានពង្រឹងរួមទាំងការតាមដានធនធានទឹក ការចេញអាជ្ញាប័ណ្ណប្រើប្រាស់ទឹក និងការគ្រប់គ្រងទិន្នន័យ និងពត៌មាន។

- ដំណើរការគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធនៅកម្រិតអាងត្រូវបានពង្រឹងរួមទាំងការអនុវត្តនិតិវិធីរបស់គណៈកម្មការទន្លេមេគង្គទាំងស្ថានភាពនៃការតាមដាន និងការរាយការណ៍អំពីអាង ការតាមដានវដ្តគម្រោង និងរួមទាំងបង្កើនការចូលរួមពីភាគីពាក់ព័ន្ធឱ្យបានទូលំទូលាយ។

- គោលបំណងផ្នែកសង្គម និងផ្នែកបរិស្ថានច្បាស់លាស់របស់អាង និងសូចនាករមូលដ្ឋានបានត្រូវកំណត់ និង

- កម្មវិធីកសាងសមត្ថភាពគ្រប់គ្រងធនធានទឹកត្រូវបានអនុវត្ត ដោយផ្សារភ្ជាប់ទៅនឹងទស្សនៈផ្ដួចផ្ដើមរួមរបស់គណៈកម្មការទន្លេមេគង្គ និងបំពេញបន្ថែមសកម្មភាពកសាងសមត្ថភាពថ្នាក់ជាតិ។

## ការអនុវត្តយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនេះ ផ្ដល់នូវផែនទីបង្ហាញផ្លូវមួយយ៉ាងច្បាស់លាស់ ដែលកំណត់សកម្មភាពអាទិភាព រយៈពេល និង លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រ។ សកម្មភាពដំបូងនៅក្នុងផែនទីបង្ហាញផ្លូវជាការរៀបចំផែនការសកម្មភាពអាង ឆ្នាំ២០១១ ដែលក្នុងនោះមានផែនការសកម្មភាពថ្នាក់តំបន់ និងផែនការចង្អុលបង្ហាញថ្នាក់ជាតិបន្ថែមចំនួន៤ ទៀត ដែលស្របគ្នាទៅនឹងផែនការថ្នាក់ជាតិមួយសម្រាប់ប្រទេសនីមួយៗក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម។ ផែនការចង្អុលនឹងត្រូវផ្សំឡើងដោយសកម្មភាពបន្ថែម ដែលត្រូវបំពេញឱ្យផែនការថ្នាក់ជាតិបច្ចុប្បន្ន សម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ។ សកម្មភាពទាំងនេះនឹងខុសៗគ្នា ដែលឆ្លុះបញ្ចាំងពីអាទិភាព និងតំបន់គោលដៅនៃប្រទេសនីមួយៗ។

ការអនុវត្តយុទ្ធសាស្ត្រនេះ និងការអភិវឌ្ឍផែនការសកម្មភាពអាង គឺជាអាទិភាពស្នូលនៃកម្មវិធី BDP ឆ្នាំ២០១១-២០១៥ ក្រោមផែនការយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គ ឆ្នាំ២០១១-២០១៥។ ការ

រៀបផែនការចង្អុលបង្ហាញ ថ្នាក់ជាតិ នឹងត្រូវដឹកនាំដោយគណៈកម្មាធិការជាតិទន្លេមេគង្គ (NMCs) ដោយធ្វើការពិគ្រោះយោបល់ជាមួយស្ថានប័នបណ្តាញទទួលខុសត្រូវ និងដោយមានបញ្ចូលទៅក្នុងផែនការតាមវិស័យ និងសេដ្ឋកិច្ចជាតិ ដោយមានការសម្របសម្រួលពីលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គ (NMCs)។

ការរៀបចំ និងការអនុវត្តផែនការសកម្មភាពថ្នាក់តំបន់ នឹងត្រូវដឹកនាំដោយលេខាធិការដ្ឋានគណៈកម្មាធិការទន្លេមេគង្គ(NMCs) ។ កម្មវិធីតាមដានការអនុវត្តយុទ្ធសាស្ត្រទូលំទូលាយរួមទាំងលទ្ធផល និងសកម្មភាពនឹងត្រូវបង្កើតឡើងក្នុង ឆ្នាំ២០១១នេះ។

## ស្ថានភាពយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនេះ គឺជាផលិតផលមួយរបស់ប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គដូចជា កម្ពុជា ឡាវ វៀតណាម និងថៃ ហើយនឹងត្រូវអនុវត្តដោយបណ្តាប្រទេសទាំងនេះដោយមានការគាំទ្រ និងជួយសម្របសម្រួល ពីគណៈកម្មការទន្លេមេគង្គ និងជំនួយ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍សំខាន់ៗ។

ការចូលរួមយ៉ាងសកម្ម និងដោយតម្លាភាពពីអ្នកពាក់ព័ន្ធទាំងអស់នៃទន្លេមេគង្គ គឺជាការចាំបាច់ដើម្បីឱ្យគោលដៅសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងដោយចីរភាព និងដោយសហការល្អលើធនធានទឹកនៅអាងទន្លេមេគង្គភាគខាងក្រោម នឹងសម្រេចទៅបានក្នុងការចែករំលែកផលប្រយោជន៍ដល់ប្រជាជន ជាពិសេសអ្នកក្រីក្រ និងអ្នកដែលត្រូវការចាំបាច់។



# តារាងមាតិកា


អក្សរកាត់ xi

១ សេចក្តីផ្តើម ១

១.១ គោលបំណង និងវិសាលភាពនៃយុទ្ធសាស្ត្រ ១

១.២ កម្មវត្ថុ និង ន វិស័យរបស់យុទ្ធសាស្ត្រ ៣

១.៣ អភិក្រមក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រ ៤

២ ផែនការ និងនិន្នាការអភិវឌ្ឍន៍ ១៣

២.១ អាងទន្លេមេគង្គ ១៣

២.២ ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹកបច្ចុប្បន្ន ១៤

២.៣ និន្នាការអភិវឌ្ឍន៍ និងបញ្ហាប្រឈម ១៥

៣ កាលានុវត្តភាពអភិវឌ្ឍន៍ និងហានិភ័យ ១៩

៣.១ ការវាយតម្លៃជាមូលដ្ឋាន ១៩

៣.២ កាលានុវត្តភាពនិងហានិភ័យនៃការអភិវឌ្ឍធនធានទឹក ២០

៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍អាង ២៧

៤.១ ក្របខ័ណ្ឌកាលានុវត្តភាពនៃការអភិវឌ្ឍត្រូវបានកំណត់ ២៧

៤.២ អាទិភាពយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍អាង ២៩

៤.៣ អាទិភាពយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងអាង ៣៥

៤.៤ ការសិក្សា និងគោលការណ៍ណែនាំ ៤០

៥ ការអនុវត្តយុទ្ធសាស្ត្រ ៤៤

៥.១ ផែនទីបង្ហាញផ្លូវ ៤៤

៥.២ តួនាទី និងការទទួលខុសត្រូវ ៤៥

៥.៣ ត្រួតពិនិត្យ វាយតម្លៃ និងការធ្វើរបាយការណ៍ ៤៦

ឧបសម្ព័ន្ធ: ផែនទីបង្ហាញផ្លូវ ៤៩



# អក្សរកាត់



| | |
|---|---|
| ASEAN | សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ |
| BDP | ផែនការអភិវឌ្ឍន៍អាង |
| CNMC | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា |
| DOS | ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ |
| EIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| GMS | មហាអនុតំបន់មេគង្គ |
| IWRM | ការគ្រប់គ្រងធនធានទឹកចម្រុះ |
| LMB | តំបន់អាងទន្លេមេគង្គភាគខាងក្រោម |
| LNMC | គណៈកម្មការជាតិទន្លេមេគង្គឡាវ |
| MDG | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MNRE | ក្រសួងធនធានធម្មជាតិ និងបរិស្ថាន“ថៃ” |
| MONRE | ក្រសួងធនធានធម្មជាតិ និងបរិស្ថាន“វៀតណាម” |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម “កម្ពុជា” |
| MRC | គណៈកម្មការទន្លេមេគង្គ |
| MRCS | លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ |
| MPCC | វេទិកាទន្លេមេគង្គស្ដីពីការប្រែប្រួលអាកាសធាតុ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NMC | គណៈកម្មាធិការ ជាតិទន្លេមេគង្គ |
| NMCS | លេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គ |
| NPV | តម្លៃសុទ្ធបច្ចុប្បន្ន |
| PDIES | នីតិវិធីសម្រាប់ការដោះដូរ និងចែករំលែកទិន្នន័យ និងព័ត៌មាន |
| PNPCA | នីតិវិធីសម្រាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុននិងកិច្ចព្រមព្រៀង |
| PMFM | នីតិវិធីសម្រាប់ការរក្សាលំហូរនៅលើទន្លេមេគង្គ |
| PWQ | នីតិវិធីសម្រាប់គុណភាពទឹក |
| PMUM | នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក |
| RBC | គណៈកម្មាធិការអាងទន្លេ |
| RBO | អង្គការរៀបចំអាងទន្លេ |
| SIA | ការវាយតម្លៃហេតុប៉ះពាល់សង្គម |
| TbEIA | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតំបន់ឆ្លងដែន |
| TNMC | គណៈកម្មការជាតិទន្លេមេគង្គថៃ |
| US$ | ដុល្លារសហរដ្ឋអាមេរិក |
| VNMC | គណៈកម្មការជាតិទន្លេមេគង្គវៀងណាម |
| WREA | រដ្ឋបាលធនធានទឹក និងបរិស្ថាន “ឡាវ” |



**យុទ្ធសាស្ត្រជួយផ្តល់នូវដំណើរការធ្វើផែនការបន្សាំទូលំទូលាយមួយ** ផ្សារភ្ជាប់ការធ្វើផែនការនៅថ្នាក់ជាតិ និងថ្នាក់តំបន់ សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍដោយចីរភាព នៅតាមបណ្តាប្រទេសក្នុងតំបន់អាងមេគង្គភាគខាងក្រោម។

# ១. សេចក្តីផ្តើម

## ១.១ គោលបំណង និងវិសាលភាពនៃយុទ្ធសាស្ត្រ

**គោលបំណង:** យុទ្ធសាស្ត្រអភិវឌ្ឍន៍អាងផ្អែកតាមគោលការណ៍ គ្រប់គ្រងធនធានទឹកចម្រុះ (IWRM) គឺជាសេចក្តីថ្លែងការណ៍របស់បណ្តាប្រទេសនៅអាងទន្លេមេគង្គភាគខាងក្រោម(កម្ពុជា ឡាវ ថៃ និងវៀតណាម) ដែលបានកំណត់ថា តើនឹងត្រូវចែករំលែកត្រូវប្រើប្រាស់ គ្រប់គ្រង់ និងត្រូវអភិរក្សទឹក និងធនធានពាក់ព័ន្ធនៃទន្លេមេគង្គយ៉ាងដូចម្តេច? ដើម្បីសម្រេចបានគោលដៅនៃកិច្ចព្រមព្រៀងលើកិច្ចសហប្រតិបត្តិការសម្រាប់ធ្វើ ការអភិវឌ្ឍដោយចីរភាពនៃអាងទន្លេមេគង្គ ដែលត្រូវបានចុះហត្ថលេខាកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៩៥ (កិច្ចព្រមព្រៀងមេគង្គ១៩៩៥) ។

យុទ្ធសាស្ត្រនេះ គឺជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់គណៈកម្មការ ទន្លេមេគង្គចំពោះកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ក្រោមកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ និងពិសេសគឺជាការឆ្លើយតបមួយទៅនឹងមាត្រាទី២ ដែលស្នើឱ្យមានការបង្កើតនូវផែនការអភិវឌ្ឍន៍អាង។ យុទ្ធសាស្ត្រនេះផ្តល់ការណែនាំដោយឡែក សម្រាប់អភិវឌ្ឍន៍ និងគ្រប់គ្រងអាងដោយចីរភាពផ្តោតលើការត្រួតពិនិត្យ និងការធ្វើបច្ចុប្បន្នភាពដោយគណៈកម្មាការ ទន្លេមេគង្គរៀងរាល់៥ឆ្នាំម្តង។

**ក្របខ័ណ្ឌយុទ្ធសាស្ត្រ:** យុទ្ធសាស្ត្រនេះផ្តល់ជាវិភាគទាន នូវដំណើរការធ្វើផែនការបន្សំដ៏ទូលំទូលាយមួយ ដែលផ្សារភ្ជាប់ការធ្វើផែនការនៅថ្នាក់ជាតិនិងថ្នាក់តំបន់សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍប្រកបដោយចីរភាពនៅអាងទន្លេមេគង្គភាគខាងក្រោម។ វាត្រូវបានចាត់ទុកជាសេណារីយ៉ូអភិវឌ្ឍន៍ដោយព្យាករណ៍មួយក្នុងរយៈពេល៥០ឆ្នាំ ដើម្បីបង្កើតឡើងនូវទស្សនវិស័យ ការគ្រប់គ្រង និងអភិវឌ្ឍន៍អាង រយៈពេល២០ឆ្នាំ។ វាផ្តល់នូវទស្សនវិស័យចម្រុះមួយអំពីអាងសំរាប់យកទៅពិចារណាផ្ទៀងផ្ទាត់ ជាមួយផែនការអភិវឌ្ឍន៍ ធនធានទឹក

គោលណការណ៍គ្រប់គ្រងទឹកចម្រុះ (IWRM) គឺជាដំណើរការមួយជួយលើកស្ទួយដល់ការគ្រប់គ្រងការអភិវឌ្ឍទឹកដី និងធនធានពាក់ព័ន្ធនានាដោយការសម្របសម្រួលក្នុងន័យបង្កើតនូវសុខុមាលភាព សេដ្ឋកិច្ច និង សង្គម ឱ្យបានអតិបរមាទៅតាមដំណើរមួយ ដែលមានតុល្យភាពដោយមិនចាំបាច់មានការសម្រុះសម្រួល ដើម្បីនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីឡើយ។

គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ (IWRM) មិនមែនជាចំណុចបញ្ចប់ដោយខ្លួនឯងនោះ ប៉ុន្តែជាមធ្យោបាយមួយនៃការសម្រេច បានកម្មវត្ថុយុទ្ធសាស្ត្រចំបងៗទាំងបី គឺភាពសក្តិសិទ្ធី (ប៉ុនប៉ងក្នុងន័យបង្កើន សុខុមាលភាព សេដ្ឋកិច្ច និងសង្គមឱ្យបានជាអតិបរមាដែលមិន គ្រាន់តែបានពីធនធានទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីការវិនិយោគទៅលើការផ្តល់សេវាកម្មទឹកទៀតផង) ។ សមធម៌ (ទៅលើការបែងចែកធនធានកម្រ និងសេវាកម្មនៅទូទាំងបណ្តុំ សង្គម និង សេដ្ឋកិច្ច) និងនិរន្តរភាព (ស្របពេលដែលមូលដ្ឋានធនធានទឹក និងប្រព័ន្ធអេកូឡេស៊ីពាក់ព័ន្ធនានាមានកំណត់)។

នៅថ្នាក់ជាតិពេលបច្ចុប្បន្ន និងអនាគត ដើម្បីធានាតុល្យភាពមួយ ដែលអាចទទួលយកបានរវាងផលប្រយោជន៍សេដ្ឋកិច្ច បរិស្ថាន និងសង្គម និងផលប្រយោជន៍រួម រវាងប្រទេស នៅក្នុងតំបន់អាងមេគង្គភាគខាងក្រោមដូចដែលយុទ្ធសាស្ត្រនេះ

- កំណត់វិសាលភាពនៃកាលានុវត្តភាពសំរាប់ការអភិវឌ្ឍធនធានទឹក (វារីអគ្គីសនី ការស្រោចស្រព ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត) ហានិភ័យនៃការអភិវឌ្ឍ និងសកម្មភាពចាំបាច់ ដែលត្រូវធ្វើ ដើម្បីបង្កើនកាលានុវត្តភាព និងកាត់បន្ថយហានិភ័យ។
- កំណត់កាលានុវត្តភាពដទៃទៀតដែលពាក់ព័ន្ធទឹកដូចជា (ការគ្រប់គ្រងជលផល នាវាចរណ៍ បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី ការគ្រប់គ្រងទីជម្រាល) និង
- ផ្តល់ដំណើរការដោយមានការសម្របសម្រួលដែលការចូលរួម ន ិងមានតម្លាភាពដើម្បីលើកស្ទួយដល់ការអភិវឌ្ឍដោយចីរភាព។

**តម្រូវការសម្រាប់យុទ្ធសាស្ត្រ:** យុទ្ធសាស្ត្រនេះត្រូវបានបង្កើតឡើងក្នុងអំឡុងពេលមានការផ្លាស់ប្តូរធំៗ នៅពេលដែលការអភិវឌ្ឍទន្លេមេគង្គទ្រង់ទ្រាយធំ និងរហ័សបានកើតឡើងទៅហើយ វីងទំនប់វារីអគ្គីសនីនៅទន្លេឡានឆាងនៃប្រទេសចិនត្រូវបានសាងសង់ (ឡានឆាងអាងទន្លេមេគង្គខ្សែទឹកខាងលើ) និងនៅតាមទន្លេមេនៃទន្លេមេគង្គភាគខាងក្រោមកំពុងធ្វើឱ្យមានការប្រែប្រួលដល់របបលំហូរទឹកទន្លេមេគង្គ។ ការកើនឡើងតំរូវការរបស់ប្រទេសសមាជិក អ្នកវិនិយោគ និងអ្នកពាក់ព័ន្ធសំរាប់ការផ្តល់នូវទស្សនវិស័យចម្រុះស្តីពីអាងលើផែនការអភិវឌ្ឍន៍ធនធានទឹកថ្នាក់ជាតិ និងផលប៉ះពាល់បន្តបន្ទាប់របស់វាកាន់តែកើនឡើង។ តម្រូវការនេះកាន់តែជាក់ស្តែងសំរាប់បរិបទនៃការធ្វើផែនការណ៍ ដែលក្នុងនោះប្រតិបត្តិការរបស់វិស័យឯកជន គឺជាចលករសំខាន់ក្នុងការធ្វើឱ្យមានការផ្លាសប្តូរ។

> **យុទ្ធសាស្ត្រនេះ ជាក្របខ័ណ្ឌសកម្មមួយដែលនឹងត្រូវពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំ ដើម្បីធានាថាការធ្វើសេចក្តីសម្រេចអំពីទឹក និងអំពីធនធានពាក់ព័ន្ធនា នាពីអាស្រ័យនឹងការធ្វើបច្ចុប្បន្នកម្មចំណេះដឹងអំពីអាង។**

យុទ្ធសាស្ត្រនេះ ត្រូវបានរៀបចំឡើងក្នុងខណៈពេលដែលយើងមិនទាន់មានទិន្នន័យ និងចំណេះដឹងគ្រប់គ្រាន់។ ប៉ុន្តែសម្ពាធនៃការអភិវឌ្ឍយ៉ាងគំហុក ក៏ទាមទារនូវសកម្មភាពអនុវត្តយុទ្ធសាស្ត្រដែរ។ យុទ្ធសាស្ត្រនេះជាក្របខ័ណ្ឌសកម្មមួយដែលនឹងត្រូវពិនិត្យឡើង និងធ្វើបច្ចុប្បន្នភាពរៀងរាល់៥ឆ្នាំ ដើម្បីធានាថាការធ្វើសេចក្តីសម្រេចអំពីទឹក និងអំពីធនធានពាក់ព័ន្ធនឹងត្រូវបានធ្វើឡើងដោយផ្អែកលើចំណេះដឹងថ្មីៗអំពីអាង។ បច្ចុប្បន្នកម្មបន្ទាប់មកទៀតត្រូវបានរំពឹងថានឹងធ្វើក្នុងឆ្នាំ ២០១៥។

**ព្រឹត្តិការណ៍សំខាន់ៗ:** យុទ្ធសាស្ត្រនេះ បង្ហាញពីព្រឹត្តិការណ៍សំខាន់ក្នុងប្រវត្តិនៃកិច្ចសហប្រតិបត្តិការមេគង្គ។ ព្រឹត្តិការណ៍ទាំងនេះត្រូវបានគ្រប់គ្រង និងដឹកនាំដោយបណ្តាប្រទេសនៅតាមអាងទន្លេមេគង្គភាគខាងក្រោមតាមរយៈដំណើរការមួយនៃការវិភាគផែនការអភិវឌ្ឍន៍នៅថ្នាក់ជាតិ និងផលប៉ះពាល់ដែលអាចកើតមាននិងត្រូវបានជូនដំណឹងដោយមានការជម្រុញពីអ្នកពាក់ព័ន្ធនៅក្នុងអាងនេះ។

> **យុទ្ធសាស្ត្រនេះបង្ហាញពីគោលវាស់វែងសំខាន់មួយក្នុងប្រវត្តិនៃកិច្ចសហប្រតិបត្តិការមេគង្គ។**

តាមរយៈការចែករំលែកព័ត៌មាន និងកិច្ចពិគ្រោះយោបល់សម្រាប់ដំណាក់កាលដំបូងបណ្តាប្រទេសទាំងនេះបានឈានដល់ការយល់គ្នាទៅវិញទៅមក លើផែនការជារួមសំរាប់ការអភិវឌ្ឍធនធានទឹកធ្វើការសន្និដ្ឋានដំបូងរួមគ្នាទៅលើផលប៉ះពាល់នៅតំបន់ដែលមានព្រំដែនរួមគ្នាធ្វើការផ្តោតលើបញ្ហារបស់គ្នាទៅវិញទៅមកបង្កើតការយល់ដឹងរួមទៅលើ កាលានុវត្តភាព និងហានិភ័យនៃការអភិវឌ្ឍធនធានទឹក និងឯកភាពលើអាទិភាព ។

## ១.២ កម្មវត្ថុ និងទស្សនវិស័យរបស់យុទ្ធសាស្រ្ត

**គោលបំណងរបស់គណៈកម្មការទន្លេមេគង្គ:** កម្មវត្ថុមូលដ្ឋាននៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ គឺកិច្ចសហប្រតិបត្តិការ ដើម្បីសម្រេចបាន "សក្តានុពលទាំងស្រុងនៃផលប្រយោជន៍ដោយចីរភាពសំរាប់បណ្តាប្រទេសនៅតំបន់ពាមអាងទន្លេមេគង្គភាគខាងក្រោមទាំងអស់ និងទប់ស្កាត់នូវការប្រើប្រាស់ខ្ជះខ្ជាយធនធានទឹកនៅអាងទន្លេមេគង្គ"។ គោលបំណងនេះត្រូវបានបំពេញបន្ថែមដោយទស្សនវិស័យ ចែករំលែកសម្រាប់"ភាពចម្រើនផ្នែកសេដ្ឋកិច្ច យុត្តិធម៌ សង្គម និងចីរភាពបរិស្ថាន នៅអាងទន្លេមេគង្គ"។ ផ្ទៃផែនការអភិវឌ្ឍន៍អាង គឺជាចំណុចស្នូលនៃកិច្ចព្រមព្រៀងនេះដើម្បីសម្រេចបាននូវគោលបំណងនេះ និងត្រូវបានណែនាំតាមរយៈកម្មវត្ថុមូលដ្ឋាននិងគោលការណ៍គ្រឹះក្នុងកិច្ចព្រមព្រៀងនេះមានៈ

- ការពារតុល្យភាពបរិស្ថាន និងអេកូឡូស៊ី
- សមភាពនៃអធិបតេយ្យ និងបូរណភាពទឹកដី
- ការប្រើប្រាស់ដោយសមហេតុសមផល និងដោយសមធម៌
- រក្សាលំហូរទឹកនៅតាមទន្លេ ឬតាមស្ទឹង
- ទប់ស្កាត់ និងបញ្ឈប់នូវឥទ្ធិពលនានាដែលមានផលអាក្រក់
- ទំនួលខុសត្រូវរបស់រដ្ឋសម្រាប់ការបំផ្លិចបំផ្លាញនានា
- សេរីភាពក្នុងការធ្វើនាវាចរណ៍ និង
- ឆ្លើយតបទៅនឹងស្ថានភាពបន្ទាន់

**ទិសដៅយុទ្ធសាស្រ្ត:** តាមកម្មវត្ថុនិងគោលការណ៍គ្រឹះដែលកំណត់ក្រោមកិច្ចសហប្រតិបត្តិការគណៈកម្មការទន្លេមេគង្គទទួលស្គាល់នូវតម្រូវការសម្រាប់អភិក្រមចម្រុះ។ ក្នុងឆ្នាំ២០០៥ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ បានទទួលយក"ទិសដៅយុទ្ធសាស្រ្តសម្រាប់ IWRM នៅតាមប្រទេសក្នុងទន្លេមេគង្គភាគខាងក្រោម" បានកំណត់វិស័យអាទិភាពចំនួន៨សម្រាប់ គោលការណ៍ IWRM ជាគន្លឹះឆ្ពោះទៅនៃការអភិវឌ្ឍក្នុងអាងទន្លេមេគង្គដោយសមធម៌ និងដោយចីរភាព។

> “ទិសដៅយុទ្ធសាស្ត្រនៃគោលការណ៍ IWRM ” របស់MRC (២០០៥) អាទិភាព៨នៃវិស័យដែលជាលទ្ធផលចំបងរបស់IWRM:
> - ការអភិវឌ្ឍសេដ្ឋកិច្ចនិងការលប់បំបាត់ភាពក្រីក្រ
> - កិច្ចការពារបរិស្ថាន
> - សមធម៌ និងការអភិវឌ្ឍសង្គម
> - ដំណោះស្រាយការសំរាប់ការប្រែប្រួលអាកាសធាតុ
> - ការគ្រប់គ្រងនិងធ្វើផែនការផ្អែកតាមព័ត៌មាន
> - កិច្ចសហប្រតិបត្តិការថ្នាក់តំបន់
> - អភិបាលកិច្ច
> - សមាហរណកម្មរយៈការធ្វើផែនការអាង

**សេចក្ដីថ្លែងការណ៍នៃកិច្ចប្រជុំកំពូល:** ក្នុងកិច្ចប្រជុំកំពូលរបស់គណៈកម្មការទន្លេមេគង្គលើកទី១ (ថ្ងៃទី៥ ខែមេសា ២០១០) នាយករដ្ឋមន្ត្រីនៃប្រទេសនៅតាមអាងទន្លេមេគង្គ ភាគខាងក្រោមបានបញ្ជាក់ឡើងវិញ នូវការបន្តប្ដេជ្ញារបស់ខ្លួនលើកិច្ចសហប្រតិបត្តិការ លើកស្ទួយការគ្រប់គ្រង ការអភិរក្ស ការប្រើប្រាស់ ការអភិវឌ្ឍធនធានពាក់ព័ន្ធដោយចីរភាព (“សម្រេចបានតាមតម្រូវការរក្សាបាននូវតុល្យភាពឆ្ពោះទៅការអភិវឌ្ឍអាងទន្លេមេគង្គដោយចីរភាព”) ។

**កិច្ចប្រជុំកំពូលលើកទី១ MRC បានគូសបញ្ជាក់ពីតម្រូវការកិច្ចសហប្រតិបត្តិការបន្តសំដៅដោះស្រាយជំនះរាល់បញ្ហាដែលកើតឡើងនៅអាងទន្លេមេគង្គ។**

កិច្ចប្រជុំកំពូលនេះបានគូសបញ្ជាក់ ពីតម្រូវការសម្រាប់កិច្ចសហប្រតិបត្តិការបន្តសំដៅជំនះនូវរាល់ បញ្ហាកើតឡើងនៅអាងទន្លេមេគង្គរួមទាំងៈការគ្រប់គ្រងហានិភ័យនៃទឹកជំនន់ និងគ្រោះរាំងស្ងួត ដោយដាក់បញ្ចូលបញ្ហាចីរភាពទៅក្នុងសក្ដានុពលក្នុងការអភិវឌ្ឍវារីអគ្គីសនី កាត់បន្ថយការបំផ្លាញគុណភាពទឹក ការបាត់បង់តំបន់ដីសើម និងការកាប់បំផ្លាញព្រៃឈើ ដែលមានហានិភ័យចំពោះជីវចម្រុះ និងការចិញ្ចឹមជីវិតប្រជាជន ការគ្រប់គ្រងជលផលធម្មជាតិក្នុងអាង និងការងារស្រាវជ្រាវនិងការផ្ដោតលើការគម្រាមកំហែងដល់ជីវភាពរស់នៅ ដែលបង្កដោយការប្រែប្រួលអាកាសធាតុ។

## ១.៣ អភិក្រមប្រើក្នុងការបង្កើតយុទ្ធសាស្ត្រនេះ

**អភិក្រមទូទៅ:** ការបង្កើតផែនការអាងដូចដែលកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ១៩៩៥ តម្រូវឱ្យមានត្រូវបានសម្រេច តាមរយៈដំណើរការធ្វើផែនការអភិវឌ្ឍន៍អាងជំហានៗជា៧ ដំណាក់កាលដូចមានបង្ហាញក្នុងរូបទី១។ លក្ខណៈសំខាន់នៃដំណើរការនេះ ជាអន្តរកម្មរវាងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយកាលានុវត្តភាពនៅកម្រិតអាង។ អន្តរកម្មនេះកើតឡើងដោយកិច្ចសហប្រតិបត្តិការអន្តរព្រំដែនប្រកបដោយ ប្រសិទ្ធភាព។ យុទ្ធសាស្ត្រនេះនាំមកនូវអន្តរទំនាក់ទំនងរវាងការធ្វើផែនការអាងនៅថ្នាក់ជាតិការពិចារណាអំពី ធនធានទឹក និងធនធានពាក់ព័ន្ធនៅកម្រិតអនុអាង និងនៅថ្នាក់ជាតិក្នុងការវាយតម្លៃផលប៉ះពាល់រួមបន្តបន្ទាប់នៃសេណារីយ៉ូក្នុងការអភិវឌ្ឍអាង។ ការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រជាទៀងទាត់ គឺជាគន្លឹះសំរាប់ដំណើរការធ្វើផែនការអាងជាជំហានៗ។

**យុទ្ធសាស្ត្រនេះនាំមកនូវការអភិវឌ្ឍ ទឹក និងធនធានពាក់ព័ន្ធដែលមានស្រាប់ និងដែលបានធ្វើផែនការរួចនៅកម្រិតអនុអាង និងនៅថ្នាក់ជាតិក្នុងការវាយតម្លៃផលប៉ះពាល់រួមនៃសេណារីយ៉ូអភិវឌ្ឍអាងជាបន្ត។**

**ការវាយតម្លៃសេណារីយ៉ូ:** ការវាយតម្លៃសេណារីយ៉ូនេះ គឺជាការប៉ាន់ប្រមាណគម្រោងផែនការ និងគោលយោបាយអភិវឌ្ឍន៍ពេលអនាគតទល់នឹងលក្ខណៈវិនិច្ឆ័យ និងកម្មវត្ថុសង្គមបរិស្ថានដែលបានឯកភាព។ លទ្ធផលនេះគួបផ្សំជាមួយការវាយតម្លៃផ្សេងទៀតយ៉ាងទូលំទូលាយចំពោះអាង (ការវាយតម្លៃជាយុទ្ធសាស្ត្របរិស្ថានតាមវិស័យ) ផ្ដល់មូលដ្ឋានសម្រាប់ពិភាក្សា និងចរចារក្នុងកម្រិតផល

រូបទី១:

## វដ្តនៃការធ្វើផែនការអភិវឌ្ឍអាង






ប្រយោជន៍ទៅវិញទៅមកលើការអភិវឌ្ឍធនធានទឹក និងកម្រិតពាក់ព័ន្ធដែលមានផលប៉ះពាល់សង្គម និងបរិស្ថានត្រង់អន្តរព្រំដែន។ កត្តានេះនាំដល់ការយល់គ្នាជារួមទៅលើអ្វីដែលអាចចាត់ទុកថាជាកាលានុវត្តភាពអភិវឌ្ឍន៍ (ក្របខ័ណ្ឌកាលានុវត្តភាពនៃការអភិវឌ្ឍ) ។

**ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍:** យុទ្ធសាស្ត្រនេះ ប្រើប្រាស់នូវ“ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍” ដើម្បីបង្ហាញទាំងកាលានុវត្តភាពអភិវឌ្ឍន៍ធនធានទឹក (ដូចជាតើបរិមាណទឹកប៉ុន្មានដែលអាចប្រើសម្រាប់ផ្គត់ផ្គង់ក្នុង វិស័យឧស្សាហកម្ម វិស័យប្រព័ន្ធស្រោចស្រព និងវិស័យវារីអគ្គីសនី) និងកាលានុវត្តភាព ទាក់ទងនឹងទឹកដែលចូករួមជួយធ្វើអោយជីវភាពរស់នៅរបស់ប្រជាជនបានប្រសើរឡើង (ជលផល ការជូនដំណឹងអំពីទឹកជំនន់ ការគ្រប់គ្រងទីជម្រាល ការអភិរក្សជីវចម្រុះ ពាណិជ្ជកម្មតាមដងទន្លេ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ) ឬក៏ការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងទឹក និងធនធានដែលពាក់ព័ន្ធ (ប្រព័ន្ធតាមដានអាងប្រព័ន្ធនាវាចរណ៍ ព្រមទាំងការអភិវឌ្ឍសមត្ថភាព ការអភិវឌ្ឍស្ថាប័ន និងគោលនយោបាយ) ។

**ការវាយតម្លៃសេណារីយ៉ូនេះ គឺជាការប៉ាន់ប្រមាណគម្រោងផែនការ និងគោលនយោបាយអភិវឌ្ឍន៍ ពេលអនាគតទល់នឹងលក្ខណៈវិនិច្ឆ័យ និងកម្មវត្ថុសង្គមបរិស្ថានដែលបានឯកភាព**

កាលានុវត្តភាពទាំងពីរប្រភេទធំខាងលើនៃក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ (DOS) តំណាងឱ្យកាលានុវត្តភាពទាំងអស់ សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍដោយមានការសម្របសម្រួល។ វិសាលភាពនៃក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ (DOS) ត្រូវបានកំណត់ដោយគោលបំណង និងសូចនាករសង្គម និងបរិស្ថានអាងដែលបានឯកភាព ក៏ដូចជាចំណុចចាប់ផ្តើម(Thresholds) ដែលបានកំណត់នៅក្នុងនីតិវិធីសម្រាប់គណៈកម្មការទន្លេមេគង្គ ដូចជាក្របខ័ណ្ឌលំហូរដែលត្រូវថែរក្សានៅក្រោមនីតិវិធីសម្រាប់ថែទាំលំហូរទឹកនៅតាមទន្លេមេ(PMFM) និងស្តង់ដាគុណភាពទឹកសម្រាប់សុខភាពមនុស្ស និងសុខភាពវារីជាតិក្រោមនីតិវិធីសម្រាប់គុណភាពទឹក (PWQ) ។

**កាលានុវត្តភាព មិនមែនការអនុម័តគម្រោង:** យុទ្ធសាស្ត្រនេះប្រើប្រាស់ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ (DOS) ជាជំហានកណ្តាល ក្នុងការបំពេញដំណើរការដែលចាប់ផ្តើមពីការគិតគូ អំពីលទ្ធភាពអភិវឌ្ឍន៍គ្រប់ដំណាក់កាលទាំងអស់រហូតដល់សំណុំឯកសារគម្រោងដែល សម្រេចបានទស្សនវិស័យ ដោយអនុលោមទៅតាមតម្រូវការនិយ័តកម្មតាមផ្នែកនៅថ្នាក់ជាតិ និងថ្នាក់តំបន់។ វាមិនចង្អុលបង្ហាញអំពីការអនុម័តយល់ព្រមលើផែនការ និងគម្រោងពីថ្នាក់ជាតិណាមួយដែលយើងប្រើសេណារីយ៉ូក្នុងការអភិវឌ្ឍទាំងឡាយឡើយ។ យុទ្ធសាស្ត្រនេះផ្តល់នូវទិដ្ឋភាពទូលំទូលាយមួយនៃកម្រិតក្នុងការអភិវឌ្ឍអាងដែលត្រូវពិចារណាអាស្រ័យទៅតាមផលប៉ះពាល់សង្គម និងបរិស្ថាននៅព្រំដែន។ សម្រាប់កាលានុវត្តភាពប្រែក្លាយជាគម្រោងមួយវានឹង ឆ្លងកាត់ដំណើរការធ្វើផែនការ និងការព្រមព្រៀងរួមទាំងការកំណត់អត្តសញ្ញាណ លទ្ធភាពគម្រោង និងការវាយតម្លៃ និងការជូនដំណឹងជាលាយលក្សណ៍អក្សរ និងឬការពិគ្រោះយោបល់បឋម និងកិច្ចព្រមព្រៀង ជាមួយបណ្តាប្រទេសផ្សេងៗ ឆ្លងតាមនិតិវិធីរបស់គណៈកម្មការទន្លេមេគង្គ (ដែលអាចអនុវត្តបាន) ដូចមានបង្ហាញក្នុង តារាងទី១។

**យុទ្ធសាស្ត្រនេះមិនចង្អុលបង្ហាញអំពីការអនុម័តយល់ព្រមទៅលើផែនការ និងគម្រោងពីថ្នាក់ជាតិណាមួយដែលយើងប្រើ សម្រាប់បង្កើតជាសេណារីយ៉ូអភិវឌ្ឍឡើយ។ វាផ្តល់នូវទិដ្ឋភាពទូលំទូលាយមួយនៃកម្រិតអភិវឌ្ឍអាងដែលត្រូវពិចារ ណាអាស្រ័យតាមផលប៉ះពាល់សង្គម និងបរិស្ថានអន្តរព្រំដែន។**

ដំណើរការនេះ ទាមទារការប្តេជ្ញាដើម្បីធានាអាទិភាព យុទ្ធសាស្ត្រនេះសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍអាង ឯដំណើរការផ្សេងៗដែលមានកំណត់នៅក្នុងយុទ្ធសាស្ត្រនេះ នឹងត្រូវបានអនុវត្តគិតចាប់ពីដំណាក់កាលដែលគម្រោងត្រូវបានកំណត់អត្តសញ្ញាណ (និងត្រូវបានដាក់បញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យគ្រប់គ្រងគម្រោង ដែលអាចឱ្យធ្វើការវាយតម្លៃបន្ថែមបន្តពីដំបូងទី និងការអនុវត្តតាមនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ) រហូតដល់ពេលមួយដែលត្រូវបានអនុម័តយល់ព្រមតាមរយៈដំណើរការនិយ័តកម្មថ្នាក់ជាតិដែលជាប់ពាក់ព័ន្ធ និងនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ។ គំនិតផ្តួចផ្តើមដែលត្រូវធ្វើនឹងក្លាយជាសមាសភាគនៃសំណុំឯកសារគម្រោងជាក់លាក់។

**ការពង្រីកក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍:** យុទ្ធសាស្ត្រនេះ ទទួលស្គាល់ថា“ក្របខ័ណ្ឌកាលាអភិវឌ្ឍន៍ (DOS) ក៏ខ័ណ្ឌសហប្រតិបត្តិការ” ឬ “ក្របខ័ណ្ឌចរចាក្នុងការស្វែងរកជម្រើសផលប្រយោជន៍ទៅវិញទៅមកមានកិច្ចព្រមព្រៀងរួមក្នុងការស្វែងរកជម្រើសផលប្រយោជន៍ និងផលប៉ះពាល់ដែលក្រៅពីកម្រិតគម្រោង និងត្រូវបានប្រើ ដើម្បីពិចារណាចំពោះកាលានុវត្តភាពដទៃទៀតដែរ (អាចមិនពាក់ព័ន្ធនឹងធនធានទឹក ឧទាហរណ៍ ពាណិជ្ជកម្ម ឬការដឹកជញ្ជូន) សំរាប់ការសម្របសម្រួលឱ្យចេញជាលទ្ធផលក្របកដោយសមធម៌។

ដូច្នេះ គេអាចពង្រីកក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ (DOS) បន្ថែមទៀតដើម្បីឈានឆ្ពោះទៅការអភិវឌ្ឍដោយចីរភាពបានដែរ តាមរយៈដំណើរការមួយមានតម្លាភាពដែល (១) ស្វែងរកទំនាក់ទំនង និងកាលាវត្តភាពអភិវឌ្ឍន៍មានផលប្រយោជន៍ទៅវិញទៅមកលើសពីវិសាលភាពរបស់ផែនការថ្នាក់ជាតិទាំងខាងក្នុង និងខាងក្រៅវិស័យទឹក, (២) បង្រួមចន្លោះប្រហោងផ្នែកចំណេះដឹង និងអភិវឌ្ឍន៍វិធានការកែសំរួលដែលនឹងសំរួលដល់ការពិនិត្យ និងការធ្វើសេចក្តីសំរេចចិត្ត ចំពោះកាលានុវត្តភាពអភិវឌ្ឍន៍នាពេលអនាគត ។



តារាង ១ ចេញពីកាលានុវត្តភាពឆ្ពោះទៅគម្រោងអភិវឌ្ឍន៍ធនធានទឹក និងធនធានពាក់ព័ន្ធដោយចីរភាព

| ដំណាក់កាល | ដំណើរកាល | ឧបករណ៍គាំទ្រចីរភាព |
|---|---|---|
| ១ វាយតម្លៃតម្រូវការ តាម IWRM ដោយដាក់បញ្ចូល ផែនការអភិវឌ្ឍន៍ធនធានទឹកថ្នាក់ជាតិ ផែនការទាក់ទងនឹងវិស័យទឹក និង វិស័យអភិវឌ្ឍន៍ផ្សេងទៀតដែលអាចមាន។ | ចែករំលែក និងបូជូនដំណឹងជាលាយលក្សណ៍អក្សរអំពីគម្រោងដែលបានកំណត់នៅថ្នាក់ជាតិ សម្រាប់ដាក់បញ្ចូលទៅក្នុងទិន្នន័យមូលដ្ឋានគ្រប់គ្រងគម្រោង។<br><br>កិច្ចពិភាក្សាថ្នាក់ជាតិ និងថ្នាក់តំបន់ដើម្បីកំណត់សេណារីយ៉ូអាងទូទៅលក្ខណៈវិនិច្ឆ័យកម្មវត្ថុវាយតម្លៃសេដ្ឋកិច្ច បរិស្ថាន និងសង្គម។<br><br>ជំនាញការ និងដំណើរការចូលរួមវាយតម្លៃ និងការផ្ទៀងផ្ទាត់លទ្ធផល។ | ទិន្នន័យដ្ឋានគ្រប់គ្រងគម្រោង វាយតម្លៃសេណារីយ៉ូអភិវឌ្ឍន៍អាងឧបករណ៍ផ្សេងៗទៀតសម្រាប់វាយតម្លៃអាង ជាទូទៅ។ |
| ២ ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ (DOS) ៖ កំណត់អត្តសញ្ញាណសំណុំកញ្ចប់មួយទាំងការអភិវឌ្ឍធនធានទឹក និង កាលានុវត្តភាព ទាក់ទងនឹងទឹក។ | កិច្ចពិភាក្សា ន ិងការចរចារលើកម្រិតនៃការអភិវឌ្ឍអាងដែលអាចទទួលយកបាននៅថ្នាក់ជាតិ និងថ្នាក់តំបន់។<br><br>ការពិចារណាដែលអាចធ្វើទៅបានអំពីជម្រើសសម្រាប់ការចែករំលែកផលប្រយោជន៍ និងផលប៉ះពាល់ដែលនឹងពង្រីកក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ (DOS) ។ | ការវាយតម្លៃសេណារីយ៉ូសំរាប់ការអភិវឌ្ឍអាងដោយទូលំទូលាយ។ សូចនាករ និងបន្ទាត់គោលនិងសេចក្តីថ្លែងការណ៍ពីកម្មវត្ថុសង្គម និងបរិស្ថាន ដែលបានព្រមព្រៀង។ នីតិវិធីរបស់គណៈកម្មការទន្លេមេគង្គអាទិភាពបែបយុទ្ធសាស្ត្រ និងការសិក្សា ។ |

| | | | |
|---|---|---|---|
| ៣ | កំណត់អត្តសញ្ញាណនៃការអភិវឌ្ឍធនធានទឹក និងគម្រោងទាក់ទងនឹងទឹក តាមរយៈការប្រើប្រាស់ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍ (DOS) ។ | កំណត់អត្តសញ្ញាណគម្រោងរួមទាំងការវិភាគជម្រើស ទាំងនៅក្នុង និងនៅក្រៅវិស័យទឹក។ ធ្វើបច្ចុប្បន្នភាពទៀងទាត់ទៅលើទិន្នន័យមូលដ្ឋានគ្រប់គ្រងគម្រោង។ | ពិចារណាបញ្ហាចីរភាពកាន់តែទូលំទូលាយ (ថ្នាក់ជាតិ និងថ្នាក់តំបន់) ។ អាទិភាពយុទ្ធសាស្ត្រការវិភាគជម្រើសវិស័យ ទិន្នន័យមូលដ្ឋានគ្រប់គ្រងគម្រោង។ |
| ៤ | រៀបចំការអភិវឌ្ឍធនធានទឹក និងគម្រោងទាក់ទងនឹងទឹក ។ | រៀបចំគម្រោងរួមទាំង (បើអាចមាន) ការសិក្សាលទ្ធផលគម្រោង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ល។ ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទិន្នន័យមូលដ្ឋានគ្រប់គ្រងគម្រោង។ | ពិចារណាបញ្ហាចីរភាពកាន់តែទូលំទូលាយ (ថ្នាក់ជាតិ និងថ្នាក់តំបន់) ។ អាទិភាពបែបយុទ្ធសាស្ត្រ WRM និងគោលកាលណ៍ណែនាំតាមវិស័យទិន្នន័យមូលដ្ឋានគ្រប់គ្រងគម្រោង។ |
| ៥ | ការវាយតម្លៃគម្រោងអន្តរព្រំដែនដែលបានកំណត់រួច។ | អនុវត្តនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ។ | នីតិរបស់គណៈកម្មការទន្លេមេគង្គ អាទិភាពយុទ្ធសាស្ត្រ WRM និងគោលការណ៍ណែនាំតាមវិស័យសំណុំឯកសារគម្រោងលំអិត។ |
| ៦ | ការយល់ព្រមនៅថ្នាក់ជាតិ | យោងតាមក្របខ័ណ្ឌច្បាប់ថ្នាក់ជាតិ។ | បទប្បញ្ញតិ និងច្បាប់ថ្នាក់ជាតិ។ |
| ៧ | ការអនុវត្ត និងប្រតិបត្តិការគម្រោង។ | យោងតាមស្តង់ដារ តម្លៃគោលការណ៍ និង សុវត្ថិភាពនៅថ្នាក់ជាតិ និងថ្នាក់តំបន់។ | បទប្បញ្ញត្តិ និងច្បាប់ថ្នាក់ជាតិ WRM និងគោលការណ៍ណែនាំតាមវិស័យ។ |

**អាទិភាពយុទ្ធសាស្ត្រ:**
យុទ្ធសាស្ត្រនេះកំណត់នូវអាទិភាពជាយុទ្ធសាស្ត្រដែលផ្តល់ការណែនាំ និងការគាំទ្រ ដើម្បីបង្កើតកាលានុវត្តភាពអភិវឌ្ឍន៍ និងការកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធឱ្យដល់កម្រិតអប្បបរមា ក៏ដូចជាដើម្បីធានាថា ការអភិវឌ្ឍបន្តធ្វើក្នុងក្របខ័ណ្ឌច្បាប់ថ្នាក់តំបន់។ នៅពេលដែលកាលានុវត្តភាពនៃ ការអភិវឌ្ឍនេះក្លាយជាគម្រោងដែលបានកំណត់នោះការណែនាំអាទិភាពជាយុទ្ធសាស្ត្រ និងការរៀបចំ គាំទ្រគម្រោង ការវាយតម្លៃការយល់ព្រម និងការធ្វើឱ្យប្រសើរដល់ការអនុវត្តនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ ដែលបានឯកភាពកាត់បន្ថយផលប៉ះពាល់ដល់កម្រិតអប្បបរមា និងផ្តល់នូវគោលការណ៍ណែនាំអនុវត្តប្រសើរ។

**យុទ្ធសាស្ត្រនេះកំណត់នូវអាទិភាពជាយុទ្ធសាស្ត្រដែលផ្តល់ការណែនាំ និងការគាំទ្រ ដើម្បីបង្កើតកាលានុវត្តភាពអភិវឌ្ឍន៍ និងការកាត់បន្ថយហានិភ័យដែលពាក់ព័ន្ធឱ្យដល់កម្រិតអប្បបរមា**

អាទិភាពជាយុទ្ធសាស្ត្រ ក៏ដាក់ចេញការណែនាំដល់សកម្មភាពផ្នែកសេដ្ឋកិច្ចសង្គម ដែលទាក់ទងនឹងទឹក ដូចជាការគ្រប់គ្រងជលផលឱ្យបានប្រសើរ ការធ្វើសមាហរណកម្មផ្លូវថ្នល់ និងការដឹកជញ្ជូនតាមទន្លេ និងការផ្តោតលើគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ចំនុចទី៧ ដែលទាក់ទងនឹងលទ្ធភាពទទួលបានទឹកស្អាត ធ្វើឱ្យប្រសើរដល់ជីវចម្រុះតំបន់ដីសើម និងការអភិរក្សបរិស្ថាន។

**សំណុំឯកសារគម្រោង:** ការអនុវត្តយុទ្ធសាស្ត្រនេះ ទាមទារឱ្យមានការពិនិត្យលើគម្រោងយ៉ាងទូលំទូលាយ នៅថ្នាក់ជាតិ និងនៅកម្រិតអន្តរព្រំដែនដែលប្រការអនុវត្តនេះនឹងត្រូវដាក់បញ្ចូល ទៅក្នុងសំណុំឯកសារគម្រោង ជាមួយគោលបំណងនៃការទាក់ទាញ និងការជួយសម្របសម្រួលដល់ហិរញ្ញប្បទានគម្រោង។ គម្រោងទាំងនេះរួមមានកាលានុវត្តភាពអភិវឌ្ឍន៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការទ្រទ្រង់ការងារសិក្សាស្រាវជ្រាវ និងសកម្មភាពផ្សេងៗទៀតដែលបានកំណត់នៅក្នុងអាទិភាពបែបយុទ្ធសាស្ត្រ ។

ដូច្នេះសំណុំឯកសារនេះនឹងត្រូវមាន: ១)គម្រោងហេដ្ឋារចនាសម្ព័ន្ធ (ការវិនិយោគលើផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលប្រើប្រាស់ ឬត្រួតពិនិត្យទឹកដែលទាក់ទងនឹងដំណើរការនៅថ្នាក់ជាតិ និងនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ) ២)គម្រោងដែលមិនមានរចនាសម្ព័ន្ធ (ការវិនិយោគ សំដៅគ្រប់គ្រងធនធានទឹក និងធនធានពាក់ព័ន្ធឱ្យកាន់តែប្រសើរ តួយ៉ាងមានដូចជាការគ្រប់គ្រងទឹកជំនន់ នាវាចរណ៍ ជលផល និងសុខភាពបរិស្ថាន) និង ៣) គម្រោងស្តារលទ្ធភាព ដូចជាការសិក្សាស្រាវជ្រាវ និងប្រធានការជម្រុញ ការអភិវឌ្ឍ និងការគ្រប់គ្រងលើការអនុវត្តកាន់តែប្រសើរ និងអភិបាលកិច្ចល្អ។

គម្រោងហេដ្ឋារចនាសម្ព័ន្ធ គឺជាគម្រោងថ្នាក់ជាតិចំបង ដែលជាប់ទាក់ទងនឹងអន្តរព្រំដែន ចំណែកគម្រោងហេដ្ឋារចនាសម្ព័ន្ធ គឺជាគម្រោងស្តារលទ្ធភាព គឺជាគម្រោងដែលមានសារជាតិដើមចំបងផ្តោតលើអាងជាទូទៅទូលំទូលាយ។ គម្រោងដែលមិនមានរចនាសម្ព័ន្ធ និងគម្រោងស្តារលទ្ធភាពនឹងត្រូវកំណត់អត្តសញ្ញាណក្នុងឆ្នាំ២០១១ ក្នុងអំឡុងពេលធ្វើផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ (ជំពូក៥) នៅថ្នាក់ជាតិ និងថ្នាក់តំបន់។

**យុទ្ធសាស្ត្រនេះគឺជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់ពេល ២ឆ្នាំ ជាមួយស្ថាប័នថ្នាក់ជាតិ ថ្នាក់ខេត្ត អង្គការអាងទន្លេ តំណាងសហគមន៍ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នសិក្សា ដៃគូអភិវឌ្ឍន៍ ដៃគូសន្ទនា និងភាគីផ្សេងៗទៀត។**

**អ្នកពាក់ព័ន្ធនិងដំណើរការចូលរួមៈ**

យុទ្ធសាស្ត្រនេះគឺជាលទ្ធផលនៃដំណើរការពិគ្រោះយោបល់ពេល២ឆ្នាំ ជាមួយស្ថាប័នថ្នាក់ជាតិ ថ្នាក់ខេត្ត អង្គការអាងទន្លេ តំណាងសហគមន៍ អង្គការក្រៅរដ្ឋាភិបាល ស្ថាប័នសិក្សា ដៃគូអភិវឌ្ឍន៍ ដៃគូសន្ទនា និងភាគីផ្សេងៗទៀត។ ដើម្បីធានាតម្លាភាព គ្រប់ឯកសារដែលពាក់ព័ន្ធទាំងអស់ ត្រូវបានដាក់លើវេបសាយរបស់គណៈកម្មការទន្លេមេគង្គ។ ការរៀបចំយុទ្ធសាស្ត្រដែលរួមមានទាំងសេណេរីយ៉ូ ការវាយតម្លៃត្រូវបានត្រួតពិនិត្យមើលដោយជំនាញការមកពីស្ថាប័នបណ្តាញពាក់ព័ន្ធថ្នាក់ជាតិ ទីប្រឹក្សាថ្នាក់ជាតិ និងគណៈកម្មការទន្លេមេគង្គ។

វេទិកាជំនាញការឯករាជ្យផ្តល់ឱ្យមានការត្រួតពិនិត្យឡើងវិញនូវការវាយតម្លៃជាមូលដ្ឋាន និងលើពង្រាងលើកទីមួយនៃយុទ្ធសាស្ត្រនេះ។ វិធីសាស្ត្រក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រនេះមាននៅក្នុងឯកសារគាំទ្រ "ធ្វើការផ្តោះទៅយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងផ្អែកតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ"។[១]



១ ឯកសារយោងអាចស្វែងរកនៅលើគេហទំព័រ www.mrcmekong.org


ចិន
មីយ៉ាន់ម៉ា
ឡាវ
ថៃ
កម្ពុជា
វៀតណាម

# ២. ផែនការនិង និន្នាការអភិវឌ្ឍន៍

## ២.១ អាងទន្លេមេគង្គ

**ទន្លេមេគង្គ:** ទន្លេនេះមានប្រវែងជិត ៤.៨០០គម ហូរពីប្រភពរបស់វានៅទីបេកាត់តាមប្រទេសចិន ភូមា ឡាវ ថៃ កម្ពុជា និងវៀតណាម តាមដីសណ្តរឆ្ពោះទៅក្នុងសមុទ្រខាងកើត ដោយហូរនាំទឹកមកចាក់ក្នុងអាងដែលមានផ្ទៃដីទំហំ៧៩៥.០០០គីឡូម៉ែត្រការេ និងមានបរិមាណធារទឹកមធ្យមប្រចាំឆ្នាំប្រហែល ៤៧៥គីឡូម៉ែត្រគូប។ ធនធានទឹកសម្រាប់មនុស្សម្នាក់ៗមានខ្ពស់ធៀបនឹងអាងទន្លេអន្តរជាតិដទៃ។ លំហូរទឹកនៅឡានកាំង អាងមេគង្គភាគខាងលើផ្តល់ទឹក១៦%នៃលំហូរមធ្យមប្រចាំឆ្នាំនៅតំបន់អាងទន្លេមេគង្គភាគខាងក្រោម[២] ប៉ុន្តែមានដល់៣០%នៃលំហូរនៅរដូវប្រាំង។

មានភាពខុសប្លែកគ្នាខ្លាំងរវាងលំហូរទឹកនៅរដូវប្រាំង និងរដូវវស្សា បណ្តាលមកពីរបបខ្យល់មូសុងនិរតីដែលបង្កើតឱ្យរដូវប្រាំង និងរដូវវស្សាមានរយៈពេលស្មើរស្មើគ្នាអថេររវាងឆ្នាំនីមួយៗមានច្រើន ហូរចាក់ពីទន្លេ ផ្ទៃដីទឹកជំនន់ និងការចាក់ផ្តើមនិងការបញ្ចប់នៃរដូវប្រាំង និងរដូវវស្សា។ ខួបនៃកម្រិតទឹកទៅតាមរដូវនៅភ្នំពេញបណ្តាលមកពីលំហូរទឹកដ៏ច្រើនហូរបញ្ច្រាសគ្នាទៅ និងមកកាន់បឹងធំតាមរយៈទន្លេសាបទាក់ទងនឹងជំនន់ និងការរាំងស្ងួតដែលធ្វើឱ្យអេកូឡូស៊ីសម្បូណ៌ឡើង។

មេគង្គជាទន្លេទីពីរដែលសម្បូណ៌ទៅដោយជីវចម្រុះក្នុងពិភពលោកបន្ទាប់ពីទន្លេអាម៉ាហ្សូន ហើយដែលជួយទ្រទ្រង់ដល់ការនេសាទជលផលទឹកសាបច្រើនជាងគេប្រហែល ២.៣លានតោនក្នុងមួយឆ្នាំ។

**ស្ថានភាពសេដ្ឋកិច្ចនិងសង្គម:** តាមការប៉ាន់ស្មានក្នុងឆ្នាំ២០០៧ចំនួនប្រជាជន ក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោមមានប្រហែល៦០លាននាក់ ក្នុងនេះ៩០%នៃចំនួនប្រជាជនកម្ពុជា (១៣លាន) ៩៧%នៃចំនួនប្រជាជនឡាវ (៥.៩លាន) ៣៩%នៃចំនួនប្រជាជនថៃ (២៣លាន) និង ២០%នៃចំនួនប្រជាជនវៀតណាម (១៧លានក្នុងដីសណ្តរ និង៣លាននៅខ្ពង់រាបកណ្តាល) រស់នៅក្នុងអាងនេះ។កំណើនប្រជាជនក្នុងអាងនេះមានពី១-២% នៅថៃ វៀតណាម និងកម្ពុជា និង២-៣%នៅឡាវ។ ទោះបីនិន្នាការនគរូបនីយកម្ម កើតមាននៅបណ្តាប្រទេសក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោមក៏ដោយ ក៏៨៥%នៃចំនួនប្រជាជនក្នុងអាងនេះរស់នៅជនបទ។

**ជីវភាពរស់នៅ និងសន្តិសុខស្បៀងនៃប្រជាជនភាគ ច្រើនរស់នៅជនបទមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រព័ន្ធទន្លេនេះ។**

ជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់ប្រជាជនភាគច្រើនរស់នៅជនបទមានទំនាក់ទំនងជិតស្និទ្ធនឹងប្រព័ន្ធទន្លេនេះដែលជាង៦០%នៃសកម្មភាពសេដ្ឋកិច្ចពាក់ព័ន្ធនឹងទឹក និងមានផលប៉ះពាល់ដល់ទឹក និងគុណភាពវា។ ប្រជាជនក្រីក្ររាប់លាននាក់ ពុំនាក់អាស្រ័យនឹងការនេសាទ

២ រូបភាពនេះគឺប្រហែលជា ៣០ ភាគរយដោយយោងតាមប្រទេសចិន

ជលផលសម្រាប់សន្តិសុខស្បៀង និងចំណូល។ ក្នុងពេលដែលបណ្តាប្រទេសនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម កំពុងមានការវិវឌ្ឍជឿនលឿនឆ្ពោះទៅការសម្រេចបានគោលដៅអភិវឌ្ឍសហសវត្សរ៍ ប្រហែល២៥%នៃប្រជាជនកម្ពុជា និងឡាវមានចំណូលក្រោមខ្សែបន្ទាត់ក្រីក្រ ដែលមានកម្រិតភាគរយខ្ពស់ជាងនៅក្នុងតំបន់ជនបទជាច្រើនទៀត។

សន្តិសុខស្បៀង និងកង្វះអាហាររូបត្ថម្ភ ជាប្រការដែលត្រូវជិនះយ៉ាងធំ។ ប្រហែលពាក់កណ្តាលនៃចំនួនគ្រួសារទាំងអស់ ពុំមានទឹកស្អាតបរិភោគ និងពាក់កណ្តាលនៃចំនួនគ្រួសារទាំងអស់មិនមានផ្លូវធ្វើដំណើរគ្រប់រដូវជិនះយ៉ាងនោះទេ។ បណ្តាប្រទេសនៅទូទាំងអាងទន្លេមេគង្គក្រោម ជាទូទៅតែងកើនឡើងនូវអសមភាពរវាងអ្នកទីក្រុង និងជនបទ។

## ២.២ ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកបច្ចុប្បន្ន

**ការប្រើប្រាស់ធនធានទឹក:** ការទាញយកទឹកប្រើប្រាស់ជាមធ្យមប្រចាំឆ្នាំសម្រាប់វិស័យកសិកម្ម ឧស្សាហកម្ម និងការប្រើប្រាស់ផ្សេងៗទៀតនៅតំបន់អាងទន្លេមេគង្គភាគខាងក្រោមប្រហែល៦០កោដិម៉ែត្រគូប ឬ ១២%នៃបរិមាណលំហូរមធ្យមប្រចាំឆ្នាំនៃទន្លេមេគង្គ។ បច្ចុប្បន្នមានការបង្វែរទឹកតិចតួចប៉ុណ្ណោះពីទន្លេនៅតាមខ្សែទឹកភាគខាងលើនៃដែនដីសណ្តរក្នុងប្រទេសវៀតណាម ទោះបីជាការបង្វែរចរន្តទឹកភាគខាងលើនៃអាងស្តុកទឹកដែលមានស្រាប់មានតិចជាង៥%នៃលំហូរមធ្យមប្រចាំឆ្នាំ និងដែលមិនគ្រប់គ្រាន់ដល់ការបែងចែកទឹកសម្រាប់រដូវនីមួយៗ។

ការប្រើប្រាស់ទឹកក្រោមដីក្នុងតំបន់អាងនេះមិនសូវមានច្រើនទេ លើកលែងតែនៅឦសានប្រទេសថៃ និងវៀតណាមដែលទឹកលើដីពុំសូវមានក្នុងអំឡុងរដូវប្រាំង។ សក្តានុពលក្នុងការអភិវឌ្ឍទឹកក្រោមដីដោយនិរន្តរភាព ទាមទារឱ្យមានការវាយតម្លៃដោយម៉ត់ចត់។

**វិស័យទាក់ទងនឹងទឹក:** កសិកម្មជាវិស័យមួយដែលទាក់ទងនឹងទឹកច្រើនជាងគេ ពិសេសនៅប្រទេសថៃ និងវៀតណាម ដែលផ្ទុយពីនេះកសិកម្មនៅកម្ពុជា និងឡាវ បច្ចុប្បន្នមានការអភិវឌ្ឍតិចតួចជាង។ ជារួមផ្ទៃដីកសិកម្មស្រោចស្រពនៅរដូវប្រាំង ប្រហែល១,២លានហិចតាមានតិចជាង ១០%នៃផ្ទៃដីកសិកម្មសរុប នៅតំបន់អាងទន្លេមេគង្គក្រោម (១៥លានហិចតា)។ ការពង្រីកកម្រិតប្រព័ន្ធស្រោចស្រពដែលមានបច្ចុប្បន្ននៅមានកំណត់ដោយសារតែលំហូរដែលមានរដូវប្រាំង។

លំហូរនៅរដូវចូលដល់ដីសណ្តរវៀតណាម ត្រូវបានប្រើប្រាស់យ៉ាងពេញលេញសម្រាប់គោលបំណងបរិស្ថាន សេដ្ឋកិច្ច និងសង្គមក្នុងនោះមានទាំងការទប់ស្កាត់នឹង ការចូលនូវទឹកប្រៃផងដែរ។ សក្តានុពលពេញលេញនៃវារីអគ្គិសនី នៅអាងទន្លេមេគង្គភាគខាងក្រោមត្រូវបានប៉ានស្មានថា មាន ៣០.០០០មេហ្គាវ៉ាតដែលក្នុងនេះមាន១០% បានអភិវឌ្ឍរួចមកទប់ពេលនេះ។ នាវាចរណ៍ក៏មានសារៈសំខាន់ដែរ ប៉ុន្តែនៅមិនទាន់បានអភិវឌ្ឍន៍ទូលំទូលាយដូចវិស័យគមនាគមន៍ឡើយ។

ការប្រឹងប្រែងដើម្បីកាត់បន្ថយការខូចខាតដោយសារទឹកជំនន់ធំដុំត្រូវបានអនុវត្តជាចំបង ដោយវិធានការដែលមិនមែនរចនាសម្ព័ន្ធ។ ធនធានទឹកត្រូវបានអភិវឌ្ឍន៍ក្នុងខ្នាតតូចសម្រាប់កែលំអតំបន់ដីសើម និង

វារីវប្បកម្ម។ ទេសចរណ៍ដែលទាក់ទងនឹងទន្លេមានសារៈសំខាន់សម្រាប់ផលទុនជាតិ និងការបង្កើតចំណូលប្រចាំឆ្នាំនៅមូលដ្ឋាន។

ការតាមដានបង្ហាញពីការស្តារឡើងវិញនៃទន្លេមេគង្គ ចំពោះសម្ពាធពីសកម្មភាពមនុស្សបច្ចុប្បន្ន ។

**ស្ថានភាពអាង:** ការតាមដានបង្ហាញពីការស្តារឡើងវិញនៃទន្លេចំពោះសម្ពាធពីសកម្មភាពមនុស្សបច្ចុប្បន្ន។ របបលំហូរនៃទឹកទន្លេភាគច្រើន គឺនៅរក្សាស្ថានភាពដើមរបស់ខ្លួន ទោះបីជាទំនប់វារីអគ្គិសនីនៅតាមទន្លេមេខ្លះប៉ះពាល់ដល់ក្នុងតំបន់ដីសណ្តរ និងតំបន់ផ្សេងៗទៀត ដែលមានការអភិវឌ្ឍយ៉ាងទូលំទូលាយ និងមានកម្រិតជីវជាតិខ្ពស់ គឺជាមូលហេតុសម្រាប់ការពិចារណា។ ចលនាទឹកជំនន់ ប្រចាំឆ្នាំនៃទន្លេបន្តជួយធ្វើឱ្យធនធានជលផលសំបូរ ទោះបីជាមានរបាយការណ៍ធ្លាក់ចុះនូវបរិមាណនេសាទក៏ដោយ។

ប៉ុន្តែទស្សនវិស័យសម្រាប់ព្រៃឈើនៅក្នុងតំបន់អាងនេះ ពុំសូវមានលក្ខណៈវិជ្ជមានទេ ដោយសារតែមានតម្រូវការឈើអារកើនឡើងការកាប់យកដី និងការខូចគុណភាពដី។ សត្វនៅក្នុងអាង១៤ប្រភេទជាប្រភេទជាធ្ងន់ធ្ងរជិតផុតពូជ និង១២ប្រភេទងាយផុតពូជ និង២៩ប្រភេទទៀតងាយគ្រោះត្រូវបានគំរាមគំហែងពីការអភិវឌ្ឍយ៉ាងឆាប់រហ័សដែលនឹងកែប្រែទីជម្រក និងយន្តការដែលមានសារៈសំខាន់ដល់ការថែរក្សាផលិតភាពប្រព័ន្ធអេកូឡូស៊ីឱ្យល្អ ។

ការគ្រប់គ្រងធនធានទឹកនៅអាងទនេមេគង្គភាគខាងក្រោម គឺជាបណ្តុំនៃ"ម៉ូដែលសម្របសម្រួល និងសហប្រតិបត្តិការ"នៅកម្រិតអាងដោយមានការជួយតាមរយៈ MRC និងម៉ូដែលជាតិចំនួន៤ ដែលឆ្លុះបញ្ចាំងពីអធិបតេយ្យភាពទម្លាប់ប្រព័ន្ធរដ្ឋបាលនៃប្រទេសនីមួយៗ។

**ការគ្រប់គ្រងធនធានទឹក:** ការគ្រប់គ្រងធនធានទឹកនៅទន្លេមេគង្គភាគខាងក្រោម គឺជាបណ្តុំមួយនៃ "ម៉ូឌែល សម្របសម្រួលនិងសហប្រតិបត្តិការ" នៅកម្រិតអាងដោយមានការជួយសម្រួលតាមរយៈគណៈកម្មការទន្លេមេគង្គ និងម៉ូឌែលជាតិចំនួន៤ ដែលឆ្លុះបញ្ចាំងពីអធិបតេយ្យភាពទម្លាប់ និងប្រព័ន្ធរដ្ឋបាលនៃប្រទេសនីមួយៗ។ គណៈកម្មការទន្លេមេគង្គ ដើរតួនាទីជាជនបង្គោលសម្រាប់កិច្ចសហប្រតិបត្តិការ ដើម្បីជួយឱ្យសម្រេចបានគោលដៅនៅកម្រិតអាងតាមរយៈផ្តល់ការចែករំលែកព័ត៌មាន គោលការណ៍ណែនាំបច្ចេកទេសនិងការសម្រុះសម្រួល។

ប្រទេសនីមួយៗទទួលយកនូវគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះដែលខ្លួនត្រូវការគួបផ្សំជាមួយសេចក្តីថ្លែងការណ៍ យ៉ាងច្បាស់លាស់អំពីគោលការណ៍ យ៉ាងច្បាស់លាស់អំពីគោលនយោបាយ និងយុទ្ធសាស្ត្រទឹកថ្នាក់ជាតិដោយមានការគាំទ្រតាមរយៈក្របខ័ណ្ឌនិយ័តកម្ម និងការពង្រឹងស្ថាប័ន។ ប្រការនេះកំណត់ពីការទទួលខុសត្រូវរបស់ស្ថាប័នសម្រាប់គ្រប់គ្រងធនធានទឹកដែលត្រូវបានពង្រឹងដោយទំនើបកម្មនៃច្បាប់ធនធានទឹកកំពុងដំណើរការ។ គណៈកម្មាការអង្គការអាងទន្លេសម្រាប់ការគ្រប់គ្រងធនធានទឹកដោយមានការចូលរួមនៅកម្រិតទីជម្រាល និងកម្រិតមូលដ្ឋាន។

## ២.៣ និន្នាការអភិវឌ្ឍន៍ និងបញ្ហាប្រឈម

**ការអភិវឌ្ឍជាសកល:** តំបន់នេះកំពុងមានការលូតលាស់យ៉ាងឆាប់រហ័ស និងធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក។ ការប្រែប្រួលនៃតម្លៃប្រេង និងឧស្ម័ន ដែលសង្កត់ធ្ងន់ទៅលើការបង្កើតឥន្ធនៈកកើតឡើងវិញ និងដែលមិនមែនជាប្រភេទហ្វូស៊ីល និងជាហិរញ្ញវត្ថុវិស័យឯកជនកំពុងធ្វើឱ្យមានការទាក់ទាញ និងកើនឡើងនៃកំពុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃថាមពលវារីអគ្គិសនីនៅអាងទន្លេមេគង្គភាគខាងក្រោម។ កង្វះស្បៀងក្នុងសកលលោក និងការកើនឡើងនៃតម្លៃអាចធ្វើឱ្យប្រព័ន្ធស្រោច

ស្រពកាន់តែមានផលចំណេញនៅអាងទន្លេមេគង្គភាគខាងក្រោម ស្របពេលដែលការអភិវឌ្ឍប្រព័ន្ធស្រោចស្រព កាន់អាចទាក់ទាញការវិនិយោគបរទេសឱ្យស្វះស្វែងរកការផលិតស្បៀងសំបូរបែប និងប្រកបទៅដោយប្រពលវប្បកម្ម។ ម៉្យាងដែលការប្រែប្រួលអាកាសធាតុសម្រាប់លំហូរនៃទន្លេមេគង្គបានព្យាករណ៍អំពីលំហូរទឹកនៅរដូវទឹកជំនន់មានកាន់តែខ្ពស់ និងមិនប៉ះពាល់ធ្ងន់ធ្ងរដល់លំហូរទឹករដូវប្រាំង។ ដីសណ្ដរមានផលប៉ះពាល់ខ្លាំងដោយសារការកើនកម្ពស់ទឹកសមុទ្រ។ ការធ្វើផែនការទាក់ទងនឹងទឹកចាំបាច់ត្រូវផ្សារភ្ជាប់និន្នាកាសេដ្ឋកិច្ចសកល ទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធានាបាននិរន្តរភាព។

**សមាហរណកម្មសេដ្ឋកិច្ចតំបន់:** សមាហរណកម្មគឺជានិន្នាការសំខាន់មួយនៅក្នុងមហាអនុតំបន់មេគង្គ (GMS) ប្រទេសទាំងអស់នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោមជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) និងជាហត្ថលេខីនៃកិច្ចព្រមព្រៀង ASEAN សម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងលើកស្ទួយអភិក្រមតំបន់ដល់ការអភិវឌ្ឍតាមវិស័យ។ ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ប្រទេសទាំងនេះសហការជាមួយគ្នាលើអភិក្រមតាមវិស័យ និង លើកម្មវិធីជាអាទិភាពជាមួយសកម្មភាពក្នុង វិស័យសកម្មភាពក្នុងវិស័យថាមពល ដើម្បីលើកស្ទួយការអភិវឌ្ឍខ្សែបណ្ដាញរវាងគ្នា និងការវិនិយោគវិស័យឯកជន ។

កម្មវិធីបរិស្ថានស្នូលរបស់មហាអនុតំបន់មេគង្គ កំពុងធ្វើការកែលំអការធ្វើផែនការបរិស្ថាន និងសមត្ថភាពគ្រប់គ្រងសម្រាប់វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រលើផែនការនិងយុទ្ធសាស្ត្រទៅតាមវិស័យសំដៅលើកកម្ពស់ច្រករបៀង អភិរក្សជីវចម្រុះដែលមានលក្ខណៈទន់ខ្សោយ និងការគ្រប់គ្រងបរិស្ថាន។

**មេគង្គភាគខាងលើ:** ប្រទេសចិន កំពុងបញ្ចប់រចនាសម្ព័ន្ធវារីអគ្គិសនីនៅ ទន្លេឡានឆាង ទំនប់ Manwan, Dachaoshan, Jinghong និងXiaowan ដែលបច្ចុប្បន្នកំពុងដំណើរការ និងទំនប់Nuozhadu នឹងបញ្ចប់នៅក្នុងឆ្នាំ២០១៤។ ទំនប់ Xiaowan និង Nuozhadu មានបរិមាណស្តុកប្រមាណ ៩.៨០០លានម៉ែត្រគូប និង ១២.៤០០លានម៉ែត្រគូប អាចធ្វើឱ្យការបែងចែកចរន្តទឹកហូរតាមរដូវខុសប្លែកគ្នា ពីរដូវវស្សាទៅរដូវប្រាំង និងបន្តការហូរនាំល្បាប់នៅក្នុងទន្លេមេគង្គ ដោយផ្តល់ ទាំងកាលានុវត្តភាព និងហានិភ័យដល់ប្រទេសទន្លេមេគង្គភាគខាងក្រោម។

> ទំនប់ Xiaowan និង Nuozhadu បង្កឱ្យការបែងចែកចរន្តទឹកហូរតាមរដូវខុសប្លែកគ្នាពីរដូវវស្សាទៅរដូវប្រាំង

**អាងទន្លេមេគង្គភាគខាងក្រោម -តម្រូវការ:** កំណើនសេដ្ឋកិច្ចនៅទូទាំងប្រទេសក្នុងអាងទន្លេមេគង្គត្រូវបានគេរំពឹងថានឹងមានកំណើនបន្តទៀត ដោយមានការគាំទ្រពីភាពសំបូរបែបផ្នែកសេដ្ឋកិច្ចសមាហរណកម្ម សេដ្ឋកិច្ចថ្នាក់តំបន់ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធព្រមទាំងការអភិវឌ្ឍធនធានមនុស្ស។ ប្រទេសឡាវ និងប្រទេសកម្ពុជាព្យាយាមបញ្ចប់នូវស្ថានភាពរបស់ខ្លួន ពីការអភិវឌ្ឍតិចតួចបំផុត ក្នុងខណៈដែលប្រទេសវៀតណាមកំពុងស្វះស្វែងរកនូវស្ថានភាពចំណូល មធ្យមមុនឆ្នាំ២០៣០។ កំណើនឡើងនៃចំនួនប្រជាជន និងស្តង់ដារជីវភាពរស់នៅ ព្រមទាំងកំណើនសេដ្ឋកិច្ចនឹងធ្វើឱ្យមានកំណើនតម្រូវការលើស្បៀងអាហារនិងអគ្គិសនី។ ដើម្បីដោះស្រាយភាពក្រីក្រជីវភាពរ៉ាំរ៉ៃ នៅតាមជនបទ ដែលរួមមានជីវិត និងទ្រព្យសម្បត្តិ និង បណ្តាលមកពីការបាត់បង់ផ្នែកសេដ្ឋកិច្ចផ្សេងទៀត វាជាការចាំបាច់ត្រូវដោះស្រាយ ផលបំផ្លិចបំផ្លាញដែលកើតឡើង

> រាល់បណ្តាប្រទេសនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោមមានយុទ្ធសាស្ត្រ កាត់បន្ថយភាពក្រីក្រដែលរួមមានទាំងការផ្គត់ផ្គង់ទឹកសាតសម្រាប់ផឹក និងសំរាប់ការស្រោចស្រព ការគ្រប់គ្រងទឹកជំនន់ ការផលិតថាមពលវារីអគ្គិសនី ជលផល និងការប្រើប្រាស់ទឹកទន្លេមេគង្គសម្រាប់គោលបំណងផ្សេងទៀត។

ជាទៀងទាត់នៃគ្រោះទឹកជំនន់ និងរាំងស្ងួតធ្ងន់ធ្ងរ។ រាល់បណ្តាប្រទេសនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម មានយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលរួមមានទាំងការផ្គត់ផ្គង់ទឹកសាតសម្រាប់ផឹកនិងសំរាប់ការស្រោចស្រព ការគ្រប់គ្រងទឹកជំនន់ ការផលិតថាមពលវារីអគ្គីសនី ជលផល និងការប្រើប្រាស់ទឹកទន្លេមេគង្គ សម្រាប់គោលបំណងដទៃទៀត។ ថាមពលវារីអគ្គីសនីត្រូវបានគេរំពឹងថានឹងផ្តល់ជាប្រភពសំខាន់មួយនៃផលទុន និងចំណូលបរទេស និងជួយដល់ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**អាងទន្លេមេគង្គភាគខាងក្រោម -ការអភិវឌ្ឍ:** គម្រោងថាមពលវារីអគ្គីសនីចំនួន ២៦ (>១០មេហ្គាវ៉ាត់) កំពុងសាងសង់តាមព្រែក ស្ទឹង និងទន្លេ ជាមួយទំបន់វារីអគ្គីសនីដែលមានក្នុងប្រទេសចិនបង្កើតបន្ថែមពីលើអាងស្តុកបច្ចុប្បន្នដែលមានសមត្ថភាព៣៦កោដ្ឋម៉ែត្រគូប។ ទំនប់វារីអគ្គីសនីនៅតាមប្រទេសក្នុងអាងទន្លេមេគង្គភាគខាងក្រោមត្រូវបានគ្រោងនឹងសាងសង់សម្រាប់រយៈពេល២០ឆ្នាំខាងមុខ រួមទាំងគម្រោង[៣] ចំនួន១២នៅតាមដៃទន្លេមេដែលភាគច្រើននៅក្នុងប្រទេសឡាវ។ ទំបន់នៅតាមទន្លេមេទាំងអស់ត្រូវបានចាត់ថ្នាក់ជា "ប្រភពថាមពលវារីអគ្គីសនីខ្នាតតូច"ជាមួយសកម្មភាពស្តុកទឹក និងសក្តានុពលនិយ័តកម្មមានកំណត់។ ទំនប់ជាច្រើនតាមដៃទន្លេ រួមទាំងអាងស្តុកសំខាន់ៗ អាចមានសមត្ថភាពស្តុកបន្ថែមចំណុះ ២១កោដ្ឋម៉ែត្រគូប។

មានផែនការជាច្រើនក្នុងការបង្កើតប្រព័ន្ធស្រោចស្រពនៅរដូវប្រាំងចំនួន ៥០% ទៀត (ពី១,២ ទៅ ១,៨ លានហិចតា) ក្នុងរយៈពេល ២០ឆ្នាំទៀត ក្នុងនោះគម្រោងផែនការរបស់ប្រទេសឡាវ មានពី១០០.០០០ ទៅជាង ៣០០.០០០ហិចតា។ ការពង្រីកប្រពន្ធស្រោចស្រពធំៗកំពុងត្រូវបានសិក្សានៅកម្ពុជា ដោយផ្សារភ្ជាប់ទៅនឹងការវិនិយោគក្នុង ការត្រួតពិនិត្យទឹកជំនន់នៅតាមតំបន់ដីសណ្តរកម្ពុជាដែលពុំទាន់មានការអភិវឌ្ឍ និងនៅតាមកន្លែងផ្សេងទៀត ផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍវារីអគ្គីសនី។ ការផ្ទេរទឹកនៅតាមទន្លេ ត្រូវបានប្រទេសថៃ ពិចារណាជាយូរមកហើយដើម្បីបំពេញតម្រូវការជាតិ សំដៅលប់បំបាត់នូវគ្រោះរាំងស្ងួត នៅឦសានប្រទេស។

ប្រទេសនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោម ក៏មានផែនការអភិវឌ្ឍន៍វារីវប្បកម្មជាបន្ត និងកែលំអនូវការគ្រប់គ្រងជលផល នាវាចរណ៍ គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតក៏ដូចជាការអភិវឌ្ឍទេសចរណ៍ផងដែរ។ កំណើនវារីវប្បកម្ម ត្រូវបានព្យាករណ៍ថាមានចំនួនទ្វេដងដល់ទៅ៤លានតោនក្នុងរយៈពេល ២០ឆ្នាំទៀត។ ការអភិវឌ្ឍក្នុងកម្រិតនេះនឹងផ្តល់ទាំង កាលានុវត្តភាពធំធេងនិងហានិភ័យខ្ពស់។ និងដើម្បីចែកផលប្រយោជន៍ទូទាំងក្រុមប្រជាជននៅក្នុងអាងនេះ។

**ការវិនិយោគលើវិស័យឯកជន:** មានការកើនឡើងនូវកាលានុវត្តភាពសម្រាប់វិស័យឯកជន និង"ក្រុមហ៊ុនបរទេសរដ្ឋគ្រប់គ្រង" ក្នុងការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធ ដូចជាវារីអគ្គីសនី នាវាចរណ៍ ប្រព័ន្ធស្រោចស្រពខ្នាតធំ ជលផល និងឧស្សាហកម្ម (រ៉ែ ព្រៃ និងទេសចរណ៍ )។ ភាគច្រើននៅក្នុងវិស័យ ទាំងនេះការវិនិយោគពីក្រុមហ៊ុនឯកជនបច្ចុប្បន្នមានលើវិស័យសាធារណៈ។ ប្រៀបធៀប

---

៣ រួមបញ្ចូលទំនប់ចំនួន ១០ កាត់តាមទន្លេ (ចំនួន ៨មាននៅ ក្នុង ប្រទេសឡាវ ចំនួន២ទៀតនៅតាម ទន្លេមេគង្គ និង ២ផ្សេងទៀត មាននៅ ក្នុង ប្រទេស កម្ពុជា ) ទំនប់កំពុងសាងសង់មានចំនួន ១ (ដូនសាហុង) និងគម្រោងសារឡើងវិញមានចំនួន ១(ថាខុង ) នៅ ក្នុង ប្រទេសឡាវ

ការអភិវឌ្ឍវិស័យសាធារណៈ ការអភិវឌ្ឍពីវិស័យឯកជនមានកាលានុវត្តភាពច្រើនជាងជាមួយវដ្តនៃការធ្វើផែនការរយៈពេលខ្លី និងដំណើរការវាយតម្លៃ។

ក្នុងករណីមានការអញ្ជើញចូលរួមពីវិស័យឯកជនចាំបាច់ត្រូវមានការបើកទូលាយចំពោះការចូលរួម ពិនិត្យពិច័យពីសាធារណៈ និងគិតគូទៅដល់កង្វល់របស់សង្គមស៊ីវិល។ ប្រការនេះទាមទារឱ្យមានប្រព័ន្ធ និយ័តកម្មមួយប្រសិទ្ធភាព រួមទាំងការជម្រុញដំណើរការផ្លូវច្បាប់ និងបទបញ្ញានានាព្រមទាំងសកម្មភាព អនុវត្តផ្លូវច្បាប់ក៏ដូចជាភាពខ្លាំង និងអំណាចដែលផ្តល់ជូនដល់ស្ថាប័នគ្រប់គ្រងធនធានទឹក។

ក្នុងករណីមានការអញ្ជើញចូលរួមពីវិស័យឯកជន ចាំបាច់ត្រូវមានការរួមការ បើកទូលំទូលាយចំពោះការចូលរួមពិនិត្យពិច័យពីសាធារណៈ និងគិតគូដល់កង្វល់របស់សង្គមស៊ីវិល។



# ៣. កាលានុវត្តភាព អភិវឌ្ឍន៍ និងហានិភ័យ

## ៣.១ ការវាយតម្លៃជាមូលដ្ឋាន

**ការសិក្សា និងការវាយតម្លៃសេណារីយ៉ូ:** យុទ្ធសាស្រ្តនេះបានបង្ហាញតាមរយៈការវាយតម្លៃចំបងៗរួមទាំងការវាយតម្លៃលើសេណារីយ៉ូអភិវឌ្ឍន៍ធនធានទឹកអាង ដោយគ្របដណ្តប់លើគ្រប់ផែនការអភិវឌ្ឍធនធានទឹកថ្នាក់ជាតិ (មើលផ្នែក១.៣) និងការសិក្សាផ្សេងទៀត[៤]។ ការវាយតម្លៃសេណារីយ៉ូនេះឆ្លើយតបនឹងផលប៉ះពាល់រួមសរុបបន្តគ្នាទៅលើផ្នែក សេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ការអភិវឌ្ឍរយៈពេល ២០ឆ្នាំ និង៥០ឆ្នាំខាងមុខត្រូវបានវាយតម្លៃជាមួយលើសក្តានុពលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការវាយតម្លៃទៅលើសេណារីយ៉ូនេះបាន បង្កើតនូវអភិក្រមដោយមានការចូលរួមថ្មីមួយ តាមរយៈការប្រើប្រាស់នូវលក្ខណៈវិនិច្ឆ័យចំនួន៤២ ដើម្បីវាយតម្លៃលើសេណារីយ៉ូនីមួយៗ ក្នុងនោះលើកម្មវត្ថុសេដ្ឋកិច្ច បរិស្ថាន សង្គម និងសមធម៌ចំនួន១៣។

**ការវាយតម្លៃលើសេណារីយ៉ូនេះ បានបង្កើតនូវអភិក្រម ដោយមានការចូលរួមថ្មីមួយ តាមរយៈការប្រើប្រាស់លក្ខណៈវិនិច្ឆ័យចំនួន៤២ ក្នុងការការវាយតម្លៃលើសេណារីយ៉ូនីមួយៗ ក្នុងនោះលើកម្មវត្ថុសេដ្ឋកិច្ច បរិស្ថាន សង្គម និងសមធម៌ចំនួន១៣។**

អភិក្រមនេះ បង្ហាញអំពីតម្រូវការសម្រាប់កម្មវត្ថុផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច ចំពោះអាងយ៉ាងច្បាស់ព្រមទាំង សូចនាករមូលដ្ឋានសម្រាប់ការវាយតម្លៃលើសេណារីយ៉ូនាពេលអនាគត។ ការបង្កើតកម្មវត្ថុនេះ គឺជាអាទិភាពយុទ្ធសាស្រ្តមួយ (ផ្នែក៤.៣ខាងក្រោម) ។ កត្តានេះត្រូវបានបំពេញតាមរយៈការវិភាគកាន់តែស៊ីជម្រៅមួយនៃកាលានុវត្តភាពអភិវឌ្ឍន៍អន្តរវិស័យ និងដែលទាក់ទងទៅនឹងថាមពលទាំងហានិភ័យនៃគម្រោងសំណើនៃទន្លេនៅតំបន់អាងទន្លេមេគង្គភាគខាងក្រោម និងការសិក្សាពាក់ព័ន្ធដទៃទៀត។ វាផ្តល់ការវិភាគអំពីបញ្ហាអាងដែលនឹងត្រូវពិចារណានៅពេលដែលគម្រោងនីមួយៗ នឹងត្រូវបានលើមកពិភាក្សាតាមរយៈបណ្តាប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ដែលជាផ្នែកមួយនៃនីតិវិធីសម្រាប់ការជូនដំណឹងជាលាយលក្ខណ៍អក្សរការពិគ្រោះយោបលជាមុន និងកិច្ចព្រមព្រៀង (PNPCA) ។

**ទិន្នន័យ និងការសន្មត់:** ការវាយតម្លៃនេះត្រូវការទិន្នន័យផ្សេងៗ មានពីកាតាឡុកមេរបស់គណៈកម្មការទន្លេមេគង្គ ឬដោយមានការផ្តល់ពីបណ្តាប្រទេសនៅក្នុងអាងទន្លេមេគង្គក្រោម[៥]។ ជាមួយទិន្នន័យ និងព័ត៌មានដ៏មានកំណត់ការសន្មត់ត្រូវបានធ្វើក្នុងទិដ្ឋភាពវាយតម្លៃសេណារីយ៉ូសំខាន់បំផុត គឺ (1) គម្រោងថាមពលវារីអគ្គិសនី ត្រូវបានដំណើរការដើម្បីបង្កើនផលិតកម្មថាមពលអគ្គិសនីឱ្យបានអតិបរមាជាមួយ

---

៤ ព័ត៌មានលំអិត គឺមាននៅក្នុងកម្មវិធីរបស់គណៈកម្មការទន្លេមេគង្គដែលមាននៅក្នុងគេហទំព័រ

៥ ការវាយវាយតម្លៃបែបជលសាស្រ្ត ដោយប្រើប្រាស់ ទិន្នន័យជាសេរីពីឆ្នាំ ១៩៨៦ដល់២០០០ជាមូលដ្ឋានដោយមានការយល់ស្របរបស់គណៈកម្មការទន្លេមេគង្គ។ ទិន្នន័យលំហូរ ទន្លេមេគង្គ នៅឆ្នាំ ២០០១ដល់២០០៩ស្រូវបានប្រើប្រាស់សំរាប់ការផ្ទៀងផ្ទាត់ម៉ូដែល។ ចំនែកឯកការវាយតម្លៃផលប៉ះពាល់ផ្នែក សេដ្ឋកិច្ច សង្គម និងបរិស្ថាន ប្រើប្រាស់ ទិន្នន័យនៅឆ្នាំ ២០០៨-២០០៩

ការបម្រែបម្រួលនៃទិន្នន័យលំហូរគន្លងមក និងទំនប់នានាដែលបានស្នើឡើងនៅតាមទន្លេមេនៃតំបន់អាងទន្លេមេគង្គភាគខាងក្រោមត្រូវបានដំណើរការជាទំបន់រក្សាលំហូរធម្មជាតិ (មិនមែនជាប្រភេទទំនប់អាងស្តុកទឹក) (២) លក្ខណៈសម្គាល់សង្គមចំពោះអ្នកដែលងាយរងគ្រោះ រស់នៅសហគមន៍រងផលប៉ះពាល់ក្នុងឆ្នាំ២០៣០ ត្រូវបានសន្មត់ថាជាប្រភេទអ្នកដែលមាននៅក្នុងឆ្នាំ២០០៨-២០០៩ និង(៣) ផលប៉ះពាល់ដែលបង្កឡើងពីការអភិវឌ្ឍផ្សេងៗ ដែលមិនទាក់ទងនឹងទឹក ដូចជាផ្លូវថ្នល់និងកិច្ចការនគរូបនីកម្មមិនបានគិតបញ្ចូលទេ។

ទិន្នន័យដែលមានកំណត់ និងការសន្មត់ទាំងនេះ គឺជារឿងធម្មតាសម្រាប់ការងារសិក្សាធ្វើផែនការអាង "ទស្សនវិស័យអនាគត"។ ក្នុងករណីខ្លះផលប៉ះពាល់មិនអាចគណនាចំនួនឱ្យច្បាស់លាស់បាននោះទេ ចំនែកទិសដៅ និងទំហំនៃការប្រែប្រួលមានភាពច្បាស់លាស់បានការជួយឱ្យអាចធ្វើការពិភាក្សាបានក្នុងចំណោមវិស័យនិងរវាងប្រទេសថាតើការគ្រប់គ្រងធនធានអាចដំណើរការទៅមុខបែបណា។

## ៣.២ កាលានុវត្តភាព និងហានិភ័យនៃការអភិវឌ្ឍធនធានទឹក

បណ្តាប្រទេសនៅអាងទន្លេមេគង្គក្រោម បានពិគ្រោះយោបល់យ៉ាងទូលំទូលាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់ទៅលើលទ្ធផលនៃការវាយតម្លៃសេណារីយ៉ូ និងការសិក្សាដែលពាក់ព័ន្ធផ្សេងៗទៀត ដើម្បីស្វែងយល់ដឹងរួមអំពីកាលានុវត្តនិងហានិភ័យផ្សេងៗនៃការអភិវឌ្ឍធនធានទឹក និងវិធីក្នុងការចាប់យកកាលានុវត្តភាពឆ្ពោះទៅដំណាក់កាលជាបន្ត និងដើម្បីផ្តោតលើហានិភ័យទាំងនេះ។

**បណ្តាប្រទេសនៅក្នុងអាងទន្លេមេគង្គភាគខាងក្រោមបានពិគ្រោះយោបល់យ៉ាងទូលំទូលាយនៅថ្នាក់ជាតិ និងថ្នាក់តំបន់លើលទ្ធផលនៃការវាយតម្លៃសេណារីយ៉ូ និងការសិក្សាដែលពាក់ព័ន្ធផ្សេងៗទៀត ដើម្បីស្វែងយល់ពីកម្រិតនៃកំណើនផលប៉ះពាល់ជាបន្ត ។**

**ការអភិវឌ្ឍដែលកំពុងដំណើរការ ជាពិសេសវារីអគ្គីសនី (មុនឆ្នាំ២០១៥):**
ទំបន់ស្តុបទឹកដ៏ធំនៅទន្លេឡាងឆាង (ឡានចាង) និងទំនប់វារីអគ្គិសនីដែលមានចំនួន២៦ ឬដែលបានគ្រោងនៅតាមដៃទន្លេ ក្នុងអាងទន្លេមេគង្គភាគខាងក្រោម ប្រសិនបើដំណើរការដូចដែលរំពឹងទុកចំពោះការផលិតថាមពលនោះវានឹងកាត់បន្ថយបរិមាណលំហូរនៅរដូវវស្សា ហើយនិងបង្កើនបរិមាណវិញនៅរដូវប្រាំង ដោយផ្លាស់ប្តូរចរន្តលំហូរទឹកទន្លេយ៉ាងច្រើន ដែលជាក់ស្តែងមាននៅតំបន់ខ្សែទឹកលើក្រុងវៀងច័ន្ទ។ទឹកក្នុងរដូវប្រាំងបានគ្រប់គ្រាន់ទៅតាមការប្រើប្រាស់ទឹករបស់ប្រទេសនៅអាងទន្លេមេគង្គភាគខាងក្រោម តាមការព្យាករណ៍ក្នុងផែនការជាតិរយៈពេល២០ឆ្នាំ ដោយមិនល្មើសឬប្រាសចាកពីរបបលំហូរមូលដ្ឋានឡើយ។ ទោះបីយ៉ាងណាក៏ដោយក៏មានហានិភ័យមួយដែលទំនប់ស្តុកទឹកបញ្ចោញទឹកមិនបានតាមការរំពឹងទុកដែរ ការបញ្ចោញទឹកលើសពីតម្រូវការអាចបង្កឱ្យទឹកជំនន់កើនឡើងខ្ពស់ និងកាត់បន្ថយដល់លំហូរទឹកនៅរដូវប្រាំង។

ផលប្រយោជន៍សេដ្ឋកិច្ចដែលរំពឹងថាបានពីការអភិវឌ្ឍវារីអគ្គិសនី គឺរួមទាំងការកាត់បន្ថយនូវ ការបំផ្លិចបំផ្លាញដោយទឹកជំនន់ កាត់បន្ថយការហូរចូលនូវទឹកប្រៃ និងបង្កើនធនធានជលផលនៅក្នុងអាងស្តុក។ កាលានុវត្តភាពការងារ (៣៧០.០០០ការងារថ្មីត្រូវបានប៉ាន់ស្មាន) នឹងមានជាពិសេសក្នុងវិស័យវារីអគ្គិសនីនិងវិស័យជលផល។

ប៉ុន្តែការប្រែប្រួលលំហូរទឹកដែលមិនហូរត្រឡប់វិញ និងដែលមិនអាចជៀសបាននឹងបង្កនូវផលប៉ះពាល់

រួមទាំងការកាត់បន្ថយតំបន់ដីសើម កាត់បន្ថយលំហូរបញ្ច្រាសទៅក្នុងទន្លេសាប និងកាត់បន្ថយ ការដឹកជញ្ជូនដីល្បាប់ដែលការបង្កឱ្យមានការហូរច្រោះដីច្រាំងទន្លេ និងបង្កើតជាក្រហូង ឬស្នាមប្រេះបាតទន្លេដែលប៉ះពាល់ដល់ដំណើរបង្កើតទ្រង់ទ្រាយដីសណ្តរ។ ការថយចុះនូវដីល្បាប់នឹងកាត់បន្ថយដល់ផលិតភាពកសិកម្មនិងតំបន់ដីសើម និងកំទេចកំណ និងជីវជាតិពាក់ព័ន្ធនានានឹងកាត់បន្ថយរហូតដល់ ៧% ដែលជាលទ្ធផលនៃការសាងសង់ទំនប់វារីអគ្គិសនីនៅតាមដៃទន្លេក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោមដោយឡែក ចំណុចពិចារណាផ្នែកបរិស្ថានចំនួន២ នឹងត្រូវរងផលប៉ះពាលយ៉ាងខ្លាំង និងហានិភ័យនឹងកើតមានចំពោះជីវភាពរស់នៅរបស់ប្រជាជនរាប់លានដែលងាយរងគ្រោះ។

យុទ្ធសាស្រ្តនេះទទួលស្គាថាការប្រែប្រួលជាប្រការជៀសមិនផុតដែលជាលទ្ធផលនៃការធ្វើសេចក្តីសម្រេចកន្លងមកហើយ ដែលជាតម្រូវការបន្ទាន់មួយសម្រាប់ធ្វើកិច្ចសហការគ្នា ដើម្បីចាប់យកកាលានុវត្តភាព និងផ្តោតលើផលប៉ះពាល់ដោយការ អភិវឌ្ឍដែលកើតមាន។ យុទ្ធសាស្រ្តនេះផ្តល់ការយកចិត្តទុកដាក់បន្ទាន់លើការកំណត់អត្តសញ្ញាណផលប៉ះពាល់លំអិត និងលើវិធានការក្នុងការចែករំលែកផលប្រយោជន៍ និងដើម្បីសម្របសម្រួលរវាងបណ្តាប្រទេសនៅក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម លើវប្រតិបត្តិការទំនប់នៅតាមដៃទន្លេ និងកិច្ចសម្របសម្រួលជាមួយប្រទេសចិន លើប្រតិបត្តិការទំនប់នៅ ឡាងឆាង (ឡានចានង)ដើម្បី: ធានាឱ្យមានភាពប្រាកដប្រជា និងសន្តិសុខលំហូរទឹកនៅរដូវប្រាំង នៅអាងទន្លេមេគង្គភាគខាងក្រោម ដើម្បីកាត់បន្ថយកម្រិតខ្ពស់បំផុតទឹកជំនន់ និងកាត់បន្ថយឱ្យានអប្បរមានូវការបាត់បង់តំបន់ដីសើម និងល្បាប់ និងការផ្គត់ផ្គង់ជីវជាតិ។

**ការពង្រីកវិសាលភាពកសិកម្មដោយប្រព័ន្ធស្រោចស្រព និងវារីអគ្គិសនីតាមដៃទន្លេ (មុនឆ្នាំ ២០៣០):** ផែនការរយៈពេល ២០ឆ្នាំ នៅអាងទន្លេមេគង្គក្រោម សម្រាប់ការអភិចឌ្ឍវារីអគ្គិសនី នៅតាមទន្លេ និងការពង្រីកវិសាលភាពកសិកម្មដោយប្រព័ន្ធស្រោចស្រពរួមទាំងការពង្រីកប្រព័ន្ធធារាសាស្រ្តដីសណ្តរនៅប្រទេសកម្ពុជា និងការបង្វែចរន្តទឹកនៅភូមិភាគឦសានប្រទេសថៃ(ផ្នែក២.៣) ផងនោះ នឹងបង្កឱ្យមានការផ្លាស់ប្តូរដល់របបលំហូរទឹកដែលរបបលំហូរទឹក ដែលបណ្តាលមកពីការអភិវឌ្ឍប្រព័ន្ធស្រោចស្រពដ៏ច្រើន និងតម្រូវការប្រើប្រាស់ទឹកផ្សេងទៀត ដែលភាគច្រើននឹងរក្សាតុល្យភាពសក្តានុពលកំណើននៅរដូវប្រាំង ដែលបញ្ជោញដោយគម្រោងថាមពលវារីអគ្គិសនីថ្មីៗនៅតាមដៃទន្លេ។

ឧទាហរណ៍. លំហូរទឹកក្នុងរដូវប្រាំងនៅខេត្តក្រចេះ នឹងមានជាមធ្យម ២៨% ខ្ពស់ជាងចំណុចមូលដ្ឋាន ប៉ុន្តែមានតែ៦% ប៉ុណ្ណោះកើនឡើងពីបម្រែបម្រួលដែលមានច្រើន (ប្រហែល ៨កោដ្ឋដុល្លាសហរដ្ឋតម្លៃសុទ្ធបច្ចុប្បន្ន (NPV) បន្ថែមពីលើផលប្រយោជន៍ពីការអភិវឌ្ឍដែលកំពុងដំណើរការ) ជាពិសេសពីវារីអគ្គិសនីតាមដៃទន្លេ និងពីប្រព័ន្ធស្រោចស្រព។ ប្រតិបត្តិការ និងការសាងសង់វារីអគ្គិសនីប្រព័ន្ធស្រោចស្រព និងជលផលអាចនឹងបង្កើតការងារថ្មីចំនួន ៦៥០.០០០។ ការពង្រីកប្រព័ន្ធស្រោចស្រពក៏ផ្តល់កាលានុវត្តភាពសម្រាប់ជលផលតាមវាលស្រែផងដែរ។

ការកើនឡើងនូវផលប៉ះពាល់បរិស្ថាន ជាមូលដ្ឋានកើតមកពីទំនប់ដែលគេនឹងសាងសង់នៅតាមដៃទន្លេចំនួន៣០ នៅប្រទេសឡាវ និងកម្ពុជាបង្កើតជាឧបករណ៍ដល់ការធ្វើបម្លាស់ទីត្រី និងបង្កើនគំនរល្បាប់ដែលនឹងប៉ះពាល់ដល់ផលិតភាពតំបន់ដីសើម និងដល់ដំណើរការបង្កើតទ្រង់ទ្រាយដីសណ្តរ។ ផលប៉ះពាល់នេះមានទាំងការថយចុះជាបន្តនូវការនេសាទជលផលពី ៧% ដោយសារការអភិវឌ្ឍដែលកំពុងមានបច្ចុប្បន្នដល់១០% ក្នុងអំឡុងពេល ២០ឆ្នាំ និងការកើនឡើងនូវផលប៉ះពាល់ខ្លាំងផលផ្នែកបរិស្ថានពី ២ ទៅ ៥កន្លែង និងការកើនឡើងនូវ ហានិភ័យដល់ជីវភាពរស់នៅរបស់ប្រជាជនពី ៤០០.០០០ ទៅ ១.៤ លាននាក់។

យុទ្ធសាស្ត្រនេះទទួលស្គាល់នូវសក្តានុពលសម្រាប់ការពង្រីកវិសាលភាពកសិកម្មដោយប្រព័ន្ធស្រោចស្រប និងការប្រើប្រាស់ផ្សេងទៀត ក្រៅពីការអភិវឌ្ឍដែលកំពុងដំណើរការបច្ចុប្បន្ន និងតម្រូវការក្នុងការការពារលំហូរមូលដ្ឋាន នៅប្រាំងដើម្បីរក្សាបាននូវកម្មវត្ថុផ្នែកផ្នែកបរិស្ថាន និងសង្គម។ ការការពារលំហូរមូលដ្ឋាននៅរដូវប្រាំងនេះអាច នឹងសម្រេចបានតាមរយៈការអនុវត្តនិតិវិធីគណៈកម្មការទន្លេមេគង្គ (PMFM, PWQ, PNPCA) ជាពិសេសសម្រាប់ការបង្វែរទឹកនៅទន្លេ។

យុទ្ធសាស្ត្រនេះក៏ទទួលស្គាល់នូវសក្តានុពលសម្រាប់ការអភិវឌ្ឍវារីអគ្គិសនីជាបន្តផងដែរនៅក្នុងអាងតាមដៃទន្លេនៅប្រទេសឡាវ និងកម្ពុជាដែលអាចផ្តល់នូវជម្រើសដល់ទំនប់តាមទន្លេនៅកម្ពុជាសម្រាប់ ធានាដល់ថាមពលរបស់ប្រទេសនេះ។ ប្រការនេះតម្រូវឱ្យមានការជូនដំណឹងជាលាយលក្សណ៍អក្សរជាមុនដើម្បីអាចធ្វើការ វិភាគទៅលើវិធានការកាត់បន្ថយផលប៉ះពាល់ការត្រៀមរៀបចំចែករំលែកផលប្រយោជន៍ និងការថ្លឹងថ្លែងពិចារណានានា។

យុទ្ធសាស្ត្រនេះផ្តល់អាទិភាពដល់ការសិក្សា និងការធ្វើសកម្មភាព ដែលជួយណែនាំ និងគាំទ្រដល់ការពង្រីកប្រព័ន្ធស្រោចស្រពចីរភាព ដល់ការអភិវឌ្ឍវារីអគ្គិសនីដោយចីរភាពតាមដៃទន្លេ និងការរៀបចំសក្តានុពលក្នុងការទូទាត់។

**ការអភិវឌ្ឍទំនប់តាមទន្លេមេ:** សំណើគម្រោងវារីអគ្គិសនីចំនួន១២ ដែលជាប្រភេទទំបន់វារីអគ្គិសនី នៅតាមទន្លេមេដែលមានបរិមាណស្តុកតិច ដូច្នេះការប្រែប្រួលកំណើនលំហូរនៅកម្រិតអន្តរព្រំដែនទឹក នឹងមានសារសំខាន់។ ប៉ុន្មានផលប្រយោជន៍សេដ្ឋកិច្ចសរុប មានភាពមិនច្បាស់លាស់ ដោយសារតែទិន្នន័យ និងការវិភាគប្រព័ន្ធអាងទន្លេមេគង្គដែលស្មុគ្រស្មាញមិនគ្រប់គ្រាន់។ គម្រោង ទាំងនេះអាចមានផលប្រយោជន៍ច្រើនជាមួយទំនប់ចំនួន១១ នៅតាមទន្លេមេ (មិនគិតគម្រោងបង្វែរទឹកនៅ Thakho) ដោយបង្កើតចំណូលតម្លៃសុទ្ធបច្ចុប្បន្ន (NPV)ចំនួន១៥កោដ្ឋដុល្លាសហរដ្ឋ ដែលទទួលបានផលប្រយោជន៍ ២.៥ដងនៃទំនប់វារីអគ្គិសនីចំនួន៣០ ដែលមានផែនការនៅអាងទន្លេមេគង្គភាគខាងក្រោម។ ការងារថ្មីប្រហែល ៤០០.០០០ អាចនឹងត្រូវបានបង្កើតក្នុងដំណាក់កាលសាងសង់ និងប្រតិបត្តិការ។ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់អាចធ្លាក់ចុះដល់ ៥០លានតោននៃឧស្ម័នកាបូនិច ($MtonsCO_2$) ក្នុងមួយឆ្នាំនៅមុនឆ្នាំ២០៣០។

ប៉ុន្តែផលប៉ះពាល់លើផ្នែកបរិស្ថាន និងសង្គមអាចនឹងមានកំរិតខ្ពស់ៈ ដូចជាង ៦០% នៃទន្លេដែលសិប្បូរជីវចម្រុះ (រួមទាំងថ្លុកជ្រៅៗ ជួរទឹក និងឆ្នេរខ្សាច់) រវាងខេត្តក្រចេះ និងហួសៃ (Houei Xai) នឹងបាត់បង់។ ផលវិបាកផ្សេងទៀតការប៉ះពាល់បរិស្ថានធ្ងន់ធ្ងរចំនួន៩កន្លែង។ ហើយភាគច្រើននៅកម្ពុជា (ទន្លេសាបអាងនៃទន្លេសេសាន សេកុង និងស្រែពក (3Sbasin) ហើយនិងទន្លេមេនៃទន្លេមេគង្គ) ប្រភេទសត្វផុតពូជសំខាន់ៗ២ ក្នុងចំណោម ៤ប្រភេទអាចផុតពូជ (ត្រីរាជ (Giant Catfish) និងផ្សោតអ៊ីរ៉ាវ៉ាឌី (Irrawaddy) និងរបាំងដែលនៅក្បែរកន្លែងបម្លាស់ទីត្រីតាមបណ្តោយចរន្តទឹកសំខាន់ៗ លើកលែងតែមានបំពាក់មធ្យោបាយសម្រួលដល់ចលនាបម្លាស់ទីវា។ កត្តានេះនឹងកាត់បន្ថយនូវបរិមាណនេសាទជលផលនៅ ក្នុងអាងនេះដល់ ១៥% ដែលជារួមបរិមាណនេសាទនេះធ្លាប់ចុះដល់២៥% ធៀបទៅនឹងចំណុចគោល។

ទំនប់ទាំងនេះក៏នឹងបង្កឱ្យមានកំណរល្បាប់ និងជីវជាតិនានាថយចុះផងដែរ។ ផលប៉ះពាល់កើនឡើងជាមួយ នឹងបរិមាណទីតាំងទំនប់នៅខ្សែទឹកខាងក្រោមកើនឡើងដោយបណ្តាលមកពីរបាំង និងទឹកទំនប់ និងអាងស្តុកតូចៗដែលមានចំនួនកើនឡើង។

យុទ្ធសាស្ត្រនេះទទួលស្គាល់នូវសក្តានុពលផលចំណេញសេដ្ឋកិច្ចនិងហរិញ្ញវត្ថុខ្ពស់ ពីគម្រោងនៅតាមទន្លេមេនៃទន្លេមេគង្គ ដែលបានលើកឡើងទាក់ទងទៅនឹងសេចក្តីត្រូវការវិស័យអគ្គិសនី និងការបង្កើតចំណូលសម្រាប់ការអភិវឌ្ឍ។ ទន្ទឹមនេះយុទ្ធសាស្ត្រ នេះទទួលស្គាល់ដែរថាភាពមិនប្រាកដប្រជានៃគម្រោងសំណើចំនួន១២ ទាក់ទងនឹងទន្លេមេនៅអាងទន្លេមេគង្គក្រោម មានទំហំធំ និងកំណើន បន្ថែមផលប៉ះពាល់អវិជ្ជមានរបស់វាអាចធ្ងន់ធ្ងរ។ យុទ្ធសាស្ត្រនេះផ្តល់អាទិភាពបចំពោះការអភិវឌ្ឍលើមូលដ្ឋាន ចំណេះដឹងនេះ ក្នុងនោះមានកម្រិត និង ហានិភ័យ និងលទ្ធភាពដែលអាចជៀសវាងបាន ការកាត់បន្ថយផលប៉ះពាល់ អវិជ្ជមាននិងផលប្រយោជន៍ ក៏ដូចជាជម្រើសក្នុងការទន្លេយកហានិភ័យរួម។ ក្របខ័ណ្ឌចាំបាច់ត្រូវតែបង្កើតឡើងដើម្បីធានាថា ហានិភ័យទាំងនេះអាចត្រូវបានកាត់បន្ថយដល់អប្បបរមាប្រកបដោយប្រសិទ្ធភាព រីឯការវាយតម្លៃអន្តរព្រំដែនតាមរយៈនិតីវិធីសម្រាប់ការជូនដំណឹងជាលាយលក្សណ៍អក្សរ ការពិគ្រោះយោបល់ជាមុននឹងកិច្ចព្រមព្រៀង (PNPCA) ត្រូវបានបញ្ចាប់មុនពេលការធ្វើសេចក្តីសម្រេចសាងសង់គម្រោងត្រូវ។ យុទ្ធសាស្ត្រនេះទទួលស្គាល់សក្តានុពលនៃផលប៉ះពាល់សំខាន់ៗ នៃទំនប់ដែលបានស្នើឡើង និងវិធីសាស្ត្រប្រុងប្រយ័ត្នមួយត្រូវអនុវត្តសម្រាប់ការពិចារណាជាបន្ត។

**ការអភិវឌ្ឍរយៈពេលវែង (ចុងឆ្នាំ ២០៦០):** ការវាយតម្លៃសេណារីយ៉ូ ផ្តល់នូវកាលានុវត្តភាព និងហានិភ័យនៃកាអភិវឌ្ឍធនធានទឹក ក្នុងរយៈពេល៥០ឆ្នាំ។ សក្តានុពលស្តុកនៅតាមដៃទន្លេ មានគ្រប់គ្រាន់សម្រាប់ករណីដែលមានការកើនឡើងខ្ពស់ ក្នុងការប្រើប្រាស់ទឹកដោយមិនចាំបាច់កាត់បន្ថយលំហូរមូលដ្ឋានក្នុងរដូវប្រាំង។

ប៉ុន្តែការអភិវឌ្ឍទាំងនេះ អាចមានផលប៉ះពាល់ចំបងលើប្រព័ន្ធអេកូឡូស៊ី និងការរៀបចំសង្គម ដូច្នេះហើយទាមទារអោយមានចំណាត់ការដោយប្រុងប្រយ័ត្នក្នុងល្បឿនមួយដែលអាចនិយាយបានថា ចំណេះ

ដឹងនាំមុខសកម្មភាព (គិតមុនគូ) ។ នៅពេលដែលវិធានការទប់ស្កាត់ទឹកជំនន់ ដែលបានគ្រោងរួចនៅតំបន់ដីសណ្តរនឹងបង្កឱ្យមានផលប៉ះពាល់ដល់អន្តរព្រំដែនតិចតួចផលប៉ះពាល់ទាំងនេះអាចមានធ្ងន់ធ្ងរ រយៈពេលវែងប្រសិនបើភាគច្រើននៃតំបន់លិចទឹកបច្ចុប្បន្នត្រូវបានផ្តល់កិច្ចការពារពេញមួយឆ្នាំ។

ប្រការនេះ នឹងជាបញ្ហាប្រឈមចំបងរារាំងដល់ការគ្រប់គ្រងបញ្ហាកំណើននៃទឹកជំនន់ និងការគ្រប់គ្រងការហូរចូលនៃទឹកសមុទ្រ ក៏ដូចជាការអភិវឌ្ឍដីជាបន្តទៀតនៅក្នុងតំបន់ដីសណ្តរកម្ពុជា និងវៀតណាម រួមទាំងវាលទំនាបលិចទឹកទន្លេសាប។ ស្របពេលដែលបញ្ហាទាំងនេះហួសពីវិសាលភាពនៃរយៈពេលធ្វើផែនការ បច្ចុប្បន្នការសិក្សាអំពីក្របខ័ណ្ឌនៃជម្រើសគ្រប់គ្រងទឹកជំនន់រយៈពេលវែងសម្រាប់ដីសណ្តរមេគង្គត្រូវបានគ្រោងរួចហើយ ដើម្បីជូនដំណឹងជាបន្តបន្ទាប់អំពីដំណើរការធ្វើផែនការអាង។

> យុទ្ធសាស្ត្រនេះរួមបញ្ចូលទាំងការសិក្សាពហុវិស័យនៅទូទាំងអាងទន្លេមេគង្គអំពីជម្រើសគ្រប់គ្រងទឹកជំនន់រយៈពេលវែងនៃដីសណ្តរមេគង្គដើម្បីឆ្លើយតបនឹងកំណើនសម្ពាធពីផែនការអភិវឌ្ឍន៍នៅតំបន់ខ្សែទឹកខាងលើ ការអភិវឌ្ឍដីនៅតំបន់ដីសណ្តរមម្រែបបម្រួលរូបសាស្ត្រ និងការប្រែប្រួលអាកាសធាតុ(ជាពិសេសការកើនឡើងនៃកម្ពស់ទឹកសមុទ្រ)។

**ការប្រែប្រួលអាកាសធាតុ:** ការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុគឺផ្អែលតាមតម្លៃ ព្យាករណ៍មធ្យម (សេណារីយ៉ូ B២)នៃវេទិកាអន្តររដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ។ ការព្យាករណ៍កំណើនកម្ពស់ទឹកសមុទ្រ ១៧ សម មុនឆ្នាំ២០៣០ និង៣០សម មុនឆ្នាំ២០៦០បានមកពីសេណារីយ៉ូការប្រែប្រួលអាកាសធាតុ និងការកើនឡើង នៃកម្ពស់ទឹកសមុទ្រសម្រាប់ប្រទេសវៀតណាម ដែលរៀបចំឡើងដោយក្រសួងធនធានធម្មជាតិ និងបរិស្ថាន(MONRE)។ លក្ខខណ្ឌអថេរកាន់តែច្រើន និងបរិមាណលំហៀរកើនឡើងនៅក្នុងអាងនេះត្រូវបានបង្ហាញសម្រាប់រយៈពេលវែង។

ក្នុងរយៈពេល ២០ឆ្នាំទៀត ការប្រែប្រួលអាកាសធាតុអាចធ្វើអោយកើនឡើងនូវភាពប្រែប្រួលប្រចាំឆ្នាំនៃលំហូរទឹករដូវវស្សា និងរដូវប្រាំងជាមធ្យមប្រចាំឆ្នាំនៃលំហូរទឹករដូវវស្សា និងរដូវប្រាំងជា មធ្យមប្រចាំឆ្នាំកាន់តែច្រើនក៏ដូចជាភាពញឹកញាប់ និងភាពធ្ងន់ធ្ងរនៃគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត ប៉ុន្តែអាចនឹងបន្ថយកំរិតទឹកជំនន់ (និងតំបន់ដីសើម)។ ការប្រែប្រួលនេះអាចបណ្តាលមកពីការអភិវឌ្ឍដែលកំពុងធ្វើដំណើរការ។ ក្នុងរយៈពេលវែងការកើនឡើងជាមធ្យមនៃលំហូរទឹកជំនន់ អាចថ្លឹងថ្លែងតាមរយៈការបង្កើនស្តុកនៅតាមដៃទន្លេ។ ប៉ុន្តែអថេរនេះសម្រាប់ការព្យាករណ៍ផលប៉ះពាល់រយៈពេលយូរអំពីការប្រែប្រួលអាកាសធាតុលើពិភពលោកអាចមានខ្ពស់។

ចាំបាច់ត្រូវធ្វើការសិក្សាឱ្យបានម៉ត់ទៅលើនិន្នាកា និងរាល់ប្រភេទនៃការប្រែប្រួលអាកាសធាតុ រួមទាំងព្រឹត្តការណ៍ធំៗ និងផលប៉ះពាល់ទៅប្រព័ន្ធអេកូឡូស៊ី និងការធ្វើកសិកម្មការសិក្សាទៅលើវិធានការអនុវត្ត ដើម្បីប្រយុទ្ធនឹងគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ខ្លាំងហើយនិងការសិក្សាទៅលើការគំរាមកំហែងពី ការកើនឡើងនៃកម្ពស់ទឹកសមុទ្រ និងកំណើនទឹកជំនន់បម្រែបម្រួលលក្ខណៈភូគព្ភរូបសាស្ត្រតំបន់ដីសណ្តរ និងសម្ពាធពីការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា និងវៀតណាម។

យុទ្ធសាស្ត្រនេះ ដាក់បញ្ចូលការវិភាគទៅលើផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលជាវិធានការមួយឆ្លើយតប ទៅនឹងកំណើនហានិភ័យនៃគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតនិងនៃជម្រើសសម្រាប់ការផ្តោតយកចិត្តទុកដាក់លើ ផលប៉ះពាល់ធំដុំនៃការកើនឡើងកម្ពស់ទឹកសមុទ្រលើដីសណ្តរដែលជាផ្នែកមួយនៃជម្រើស ក្នុងការគ្រប់គ្រងដីសណ្តររយៈពេលវែង។

**ការបែងចែកផលប្រយោជន៍ និងហានិភ័យ:** សក្តានុពលផលប្រយោជន៍ និងហានិភ័យនៃការអភិវឌ្ឍ ដែលមានបច្ចុប្បន្នត្រូវបានកំណត់យ៉ាងច្បាស់ តាមរយៈការប្រែប្រួលលំហូរបណ្តាលមកពីការអភិវឌ្ឍវារីអគ្គិសនីនៅអាងទន្លេមេគង្គលើឡានឆាង (ឡានចាណង)។ បណ្តាប្រទេសនៅអាងទន្លេមេគង្គភាគខាងក្រោមទទួលបានទាំងផលប្រយោជន៍ទាំងផលប៉ះពាល់អវិជ្ជមាន។

ក្នុងរយៈពេលពេល២០ទៀតដោយមិនគិតបញ្ចូលសំណើរស្តីពីទំនប់វារីអគ្គិសនីតាមទន្លេមេគង្គភាគខាងក្រោមប្រទេសទាំងអស់អាចទទួលបានផលប្រយោជន៍ពីការធ្វើជំនួញថាមពលក្នុងតំបន់ផលប្រយោជន៍ពីការពង្រីកប្រព័ន្ធស្រោចស្រព និងការកាត់បន្ថយពីការខូចខាតដោយទឹកជំនន់។ បើវៀតណាម ហើយដែលផលប៉ះពាល់ដែលកើនឡើងទៅនឹងអ្វីដែលមាន និងដែលកំពុងអភិវឌ្ឍ គឺមានទំនាក់ទំនងចំបងជាមួយនឹងទំនប់ចំនួន៣០បន្ថែម តាមដៃទន្លេនៅប្រទេសឡាវ កម្ពុជា និងវៀតណាម ហើយដែលផលប៉ះពាល់ទាំងនេះភាគច្រើនកើតមាននៅតាមបណ្តាប្រទេសទាំងនេះ។

ជាមួយសំណើទំនប់វារីអគ្គិសនីនៅតាមទន្លេមេគង្គក្រោម បណ្តាប្រទេសទាំងអស់នៅអាងទន្លេមេគង្គភាគខាងក្រោម អាចទទួលបានផលប្រយោជន៍ពីវារីអគ្គិសនីនេះ។ កំណើនផលប៉ះពាល់មានមិនស្មើគ្នាទេពីកន្លែងមួយទៅមួយទៀត។ ប្រទេសកម្ពុជា និងវៀតណាមអាចជាប្រទេសដែល ទទួលរងផលប៉ះពាល់ច្រើនជាងគេពីហានិភ័យទាំងនេះរួមទាំងការធ្លាក់ចុះនៃនេសាទជលផល និងការប្រែប្រួលចំពោះការហូរនាំដីល្បាប់។

កាលានុវត្តភាពសម្រាប់កសិកម្មដោយប្រព័ន្ធស្រោចស្រព ការអភិវឌ្ឍជលផលការបំផ្លិតបំផ្លាញដោយសារកំរិតទឹកជំនន់ថយចុះ ការធ្វើពាណិជ្ជកម្មតាមទន្លេកើនឡើង និងវិស័យទេសចរណ៍កាន់តែជឿនលឿនថែមទៀត។

ការគ្រប់គ្រងអាងទន្លេមេគង្គដែលស្របជាមួយគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះនឹងតម្រូវឱ្យប្រទេសនៅតំបន់ពាមផ្តោតការយកចិត្តទុកដាក់បញ្ហាឆ្លងដែន ដែលទាមទារឱ្យមានការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការរវាងប្រទេសរឹងមាំ។

យុទ្ធសាស្ត្រនេះទទួលស្គាល់ថាការបែងចែកផលប្រយោជន៍និងហានិភ័យពីការអភិវឌ្ឍធនធានទឹកបច្ចុប្បន្ន និងអនាគតមិនស្មើគ្នា ទាមទារឱ្យប្រទេសទាំងនេះបង្កើតជម្រើសចែករំលែកការចំណាយ និងផលប្រយោជន៍សម្រាប់ការអភិវឌ្ឍអាង ដើម្បីនឹងទទួលបានផលប្រយោជន៍ទាំងសងខាង។



# ៤. យុទ្ធសាស្រ្ត អភិវឌ្ឍន៍អាង

យុទ្ធសាស្រ្តសម្រាប់អភិវឌ្ឍន៍នេះ ដាក់ចេញនូវការចាប់ផ្តើមកំណត់អត្តសញ្ញាណនៃក្របខ័ណ្ឌកាលានុវត្ត អភិវឌ្ឍ (DOS, ផ្នែក៤.១) អាទិភាពយុទ្ធសាស្រ្តសម្រាប់ទាំងការអភិវឌ្ឍអាង និងការគ្រប់គ្រងអាង (ផ្នែក៤.២ និងផ្នែក៤.៣) និងគោលការណ៍ណែនាំតាមវិស័យ ដែលត្រូវបានកំណត់អត្តសញ្ញាណ ដើម្បីគាំទ្រការអនុវត្តអាទិភាពជាយុទ្ធសាស្រ្ត (ផ្នែក៤.៤)។

អាទិភាពយុទ្ធសាស្រ្តសម្រាប់ការអភិវឌ្ឍអាង និងការគ្រប់គ្រងអាងនឹងប្រែក្លាយកាលានុវត្តភាពទៅជា ការអនុវត្ត និងការអភិវឌ្ឍដោយចីរភាព។ យុទ្ធសាស្រ្តនេះស្វែងរកការធ្វើអោយប្រសើរឡើងក្របខ័ណ្ឌ កាលានុវត្តភាពអភិវឌ្ឍន៍(ផ្នែក១.៣)។ អាទិភាពយុទ្ធសាស្រ្តទាំងនេះត្រូវបំពេញបន្ថែមអោយគ្នាទៅវិញ ទៅមក ដែលក្នុងនោះ អាទិភាពសំរាប់ការគ្រប់គ្រងអាងណែនាំ និងផ្តល់ការគាំទ្រសម្រាប់ការអភិវឌ្ឍ អាង តាមរយៈការការពារមូលដ្ឋានធនធានធម្មជាតិតាមរយៈការពង្រឹងដំណើរការគ្រប់គ្រងអាង ហើយ និងតាមរយៈការអភិវឌ្ឍ ក៏ដូចជាការកសាងសមត្ថភាពស្ថាប័នដែលពាក់ព័ន្ធ។

ការចាប់ផ្តើមអាទិភាពយុទ្ធសាស្រ្ត និងក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍(DOS) នឹងត្រូវធ្វើបច្ចុប្បន្នភាព មុនឆ្នាំ២០១៥។

## ៤.១ យុទ្ធសាស្រ្តអភិវឌ្ឍន៍អាង

យុទ្ធសាស្រ្តនេះទទួលស្គាល់ថាមានសក្តានុពល ដែលអាចពិចារណាសម្រាប់ការអភិវឌ្ឍធនធានទឹកទន្លេមេគង្គ ប៉ុន្តែក៏មានភាពមិនប្រាកដប្រជា និងហានិភ័យ។

យុទ្ធសាស្រ្តនេះទទួលស្គាល់ថាមានសក្តានុពល ដែលអាចសម្រាប់ការអភិវឌ្ឍធនធាន ទឹកទន្លេមេគង្គ។ ជាពិសេស ប្រទេសនៅតាមអាងទន្លេមេគង្គទទួលស្គាល់ការកើត ឡើងនៃកាលានុវត្តភាពអភិវឌ្ឍន៍ធនធានទឹកសំខាន់ទាំង៣ ដែលកាលានុវត្តភាព នីមួយៗពាក់ព័ន្ធនឹងប្រភេទរបស់ខ្លួន និងកម្រិតនៃភាពមិនប្រាកដប្រជា និងហានិភ័យ ដែលចាំបាច់ត្រូវមានការគ្រប់គ្រង និងការកាត់បន្ថយផលប៉ះពាល់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ដែលពាក់ព័ន្ធ តាមរយៈកិច្ចសហប្រតិបត្តិការនៅកម្រិតអន្តរព្រំប្រទល់។

### ការអភិវឌ្ឍវារីអគ្គិសនីតាមដៃទន្លេ

មានសក្តានុពលដែលអាចពិចារណាបានសម្រាប់ការអភិវឌ្ឍវារីអគ្គិសនីតាមដៃទន្លេនៅអាងទន្លេមេគង្គ ភាគខាងក្រោម (LMB) ជាពិសេសនៅប្រទេសឡាវ និងកម្ពុជាដូចជាសម្រាប់ការកែលំអ ប្រតិបត្តិការ

គម្រោងវារីអគ្គិសនីដែលកំពុងដំណើរការ។ ការប្រើប្រាស់កាលានុវត្តនេះទាមទារឱ្យផ្តោតលើនិរន្តរភាពទាំងនៅកម្រិតគម្រោង និងកម្រិតអន្តរព្រំប្រទល់ហេតុនេះសក្តានុពលផលប៉ះពាល់នៅអន្តរព្រំប្រទល់ត្រូវកំណត់អត្តសញ្ញាណ និងកាត់បន្ថយគ្រោះថ្នាក់ដោយមានការចូលរួមតាមរយៈការប្រើប្រាស់ ក្របខ័ណ្ឌការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអន្តរព្រំប្រទល់ (TbEIA) របស់គណៈកម្មការទន្លេមេគង្គ។

### ការពង្រីកកសិកម្មដោយប្រព័ន្ធស្រោចស្រព

នៅពេលដែលមានប្រតិបត្តិការដោយមានការសម្របសម្រួលនៅតំបន់វារីអគ្គិសនីនៅឡាន (ឡានចានង) នៃអាងទន្លេមេគង្គភាគខាងលើ និងនៅអាងទន្លេមេគង្គភាគខាងក្រោមនោះនឹងមានកាលានុវត្តភាពមួយសម្រាប់បង្កើនលំហូរសំរាប់ប្រើនៅរដូវប្រាំងដោយមិនប៉ះពាល់ដល់លំហូរមូលដ្ឋានគ្រឹះសំរាប់ពង្រីកប្រព័ន្ធស្រោចស្រពក្នុងនោះមានទាំងដីសណ្តរនៅប្រទេសកម្ពុជា និងប្រព័ន្ធបង្វែរទឹកដែលអាចធ្វើទៅបាននៅភាគឦសានប្រទេសថៃ និងដើម្បីទប់ទល់នឹងការហូរចូលនូវទឹកសមុទ្រមកដីសណ្តរនៅប្រទេសវៀតណាម។ ប្រការនេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាមួយប្រទេសចិន និងការអនុវត្តយ៉ាងម៉ត់ចត់នៃនិតិវិធីសំរាប់ត្រួតពិនិត្យការប្រើប្រាស់ទឹក (PWUM) និតិវិធីសំរាប់ការរក្សាលំហូរនៅលើទន្លេមេ (PMFM) និតិវិធីសំរាប់គុណភាពទឹក (PWQ) និងធានាការវាយតម្លៃអន្តរព្រំប្រទល់នៃការប្រើប្រាស់ទឹក (តាមរយៈនិតិវិធីសំរាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) តាមដែលអាចធ្វើទៅបាន)។

### ការអភិវឌ្ឍវារីអគ្គិសនីតាមទន្លេមេ

មានកាលានុវត្តភាពមួយដើម្បីធ្វើការពិចារណាលើវារីអគ្គិសនីនៅតាមទន្លេមេប្រសិនបើភាពមិនប្រាកដប្រជាចំបងៗ និងហានិភ័យដែលទាក់ទងនឹងទំនប់តាមទន្លេត្រូវបានដោះស្រាយពេញលេញ ហើយប្រសិនបើកាលានុវត្តភាពនេះត្រូវបានផ្តល់សម្រាប់ប្រទេសជាសមាជិកដើម្បីធ្វើការពិចារណា និងដោះស្រាយផលប៉ះពាល់នៅអន្តរព្រំប្រទល់រួមគ្នាលើគម្រោងដែលបានស្នើឡើង (តាមរយៈនិតិវិធីសំរាប់ការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA)។

### កាលានុវត្តភាពផ្សេងទៀត

កាលានុវត្តភាពដែលទាក់ទងនឹងទឹក មានដូចជា ជលផលនាវាចរណ៍ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួតការគ្រប់គ្រងទីជម្រាលការគ្រប់គ្រងទេសចរណ៍ និងបរិស្ថានក្នុងនេះមានទាំងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីក៏ដូចជាកាលានុវត្តភាពក្រៅពីវិស័យទឹកផងដែរ (ឧទាហរណ៍ ជម្រើសនៃការផលិតថាមពលផ្សេងទៀត)មានសក្តានុពល ដែលអាចពិចារណាបានហើយនឹងត្រូវបានកំណត់អត្តសញ្ញាណដោយមានការជួយសម្រួលដើម្បីការអភិវឌ្ឍអាងដោយចីរភាព។

> **យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់លើតម្រូវការសម្រាប់វិស័យទាក់ទង ទឹកសំដៅរៀបចំយុទ្ធសាស្ត្រនិងការកំណត់អត្តសញ្ញាណកម្ម នៃកាលានុវត្តភាពជាបន្តដែលអាចផ្តល់ប្តូរបានក្រៅពីវិស័យទឹក។**

យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់លើតម្រូវការសម្រាប់វិស័យទាក់ទងទឹកសំដៅរៀបចំយុទ្ធសាស្ត្រ និងបន្តកំណត់អត្តសញ្ញាណនៃកាលានុវត្តភាពផ្សេងទៀតក្រៅពីវិស័យទឹក។

អាទិភាពយុទ្ធសាស្ត្រសម្រាប់ភាពការអភិវឌ្ឍ និងការគ្រប់គ្រង និងនាំកាលានុវត្តភាពការអភិវឌ្ឍ ដែលបានកំណត់ អត្តសញ្ញាណ ដើម្បីអនុវត្ត និងអភិវឌ្ឍន៍ ដោយចីរភាព។

## ៤.២ អាទិភាពយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍អាង

### ១.ផ្តោតលើកាលានុវត្តភាព និងវិបាកនៃការអភិវឌ្ឍ កំពុងដំណើរការរួមទាំងការអភិវឌ្ឍនៅអាងទន្លេមេគង្គភាគខាងលើឡានឆាង

សកម្មភាពដែលនឹងត្រូវអនុវត្តនៅក្នុងតំបន់ទាំង៤ ដើម្បីទទួលបានផលប្រយោជន៍ល្អ និងដើម្បីគ្រប់គ្រងហានិភ័យនៃគម្រោងដែលត្រូវធ្វើបច្ចុប្បន្ន:

- **ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយប្រទេសចិន សម្រាប់ប្រតិបត្តិការសម្របសម្រួលលើទំនប់វារីអគ្គិសនីនៅឡានឆាង (ឡានចានង) សំដៅធានាផលប្រយោជន៍ការកើនឡើងលំហូរនៅរដូវប្រាំង ផ្តោតលើបញ្ហាការហូរនាំល្បាប់ និងផ្តល់ការប្រកាសជូនដំណឹងជាមុន។** ការប្រើប្រាស់ទឹកនៅអាងទន្លេមេគង្គភាគខាងក្រោមនាពេលអនាគតនឹងក្លាយជាមុខងារមួយនៃលំហូរទឹកនៅរដូវប្រាំងពីទំនប់វារីអគ្គីសនីនៅឡានឆាង (ឡានចានង) និងបទបញ្ញត្តិប្រតិបត្តិការទំនប់វារីអគ្គិសនីគឺ ជាព័ត៌មានដែលមានប្រយោជន៍ចំពោះការធ្វើផែនការនៅអាងទន្លេមេគង្គក្រោម។ ប្រការនេះតម្រូវឱ្យមានកិច្ចព្រមព្រៀងថ្មីមួយ ដោយប្រើប្រាស់បទពិសោធន៍នៃអនុស្សារណៈយោគយល់គ្នា ដែលមានស្រាប់រវាងប្រទេសចិន និងគណៈកម្មការទន្លេមេគង្គរួមទាំងប្រព័ន្ធត្រួតពិនិត្យធារាសាស្ត្រ ដែលកាន់តែមានលក្ខណៈសមាហរណកម្ម។ ប្រការនេះអាចពង្រឹងការប្តេជ្ញាទៅវិញទៅមក ចំពោះការអភិវឌ្ឍអាងដោយចីរភាពជម្រុញការចែករំលែកផលប្រយោជន៍ និងជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានទន្ទឹមមានការទទួលស្គាល់នូវសិទ្ធិអធិបតេយ្យភាព។

- **ពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសនៅតាមអាងទន្លេមេគង្គភាគខាងក្រោមស្តីពីប្រតិបត្តិការលើទំនប់តាមដៃទន្លេ** ប្រតិបត្តិការដោយមានការសម្របសម្រួលលើទំនប់តាមដៃទន្លេនឹងត្រូវបានជួយសម្រួលតាមរយៈកែលំអការអនុវត្តនិតិវិធីរបស់គណៈកម្មការទន្លេមេគង្គ សំដៅធានាលំហូររទឹកនៅរដូវប្រាំងប្រចាំឆ្នាំដែលអាចទុកចិត្តបាន។

- **ឈានដល់កិច្ចព្រមព្រៀងសំដៅការពារលំហូរទឹកមូលដ្ឋាននៅរដូវប្រាំងនៅតាមទន្លេមេនៃទន្លេមេគង្គ** របបលំហូរទឹកមូលដ្ឋានពីឆ្នាំ១៩៨៦-២០០០ ដូចដែលមានបង្ហាញនៅក្នុងក្របខ័ណ្ឌទ្រទ្រង់ការធ្វើសេចក្តីសម្រេចរបស់គណៈកម្មការទន្លេមេគង្គត្រូវបានចាត់ទុកថាមានលក្ខណៈជិតទៅនឹងស្ថានភាពដើមរបស់វា។ ការការពាររបបលំហូរនេះចាំបាច់ ត្រូវសម្រេចតាមតម្រូវការសំខាន់ផ្នែកសង្គម និងបរិស្ថាន។ នីតិវិធីសម្រាប់ការរក្សាលំហូរនៅលើទន្លេមេផ្តល់ទាំងយន្តការដើម្បីធានាថា លំហូរមូលដ្ឋាន ត្រូវរក្សានៅតាមចំណុចសំខាន់ៗចំនួន១២ នៅតាមបណ្តោយទន្លេមេ និងមូលដ្ឋានគ្រឹះក្នុងការព្រមព្រៀងលើការប្រើប្រាស់ទឹកជាបន្ត។ គួរផ្សំជាមួយការរក្សាស្តង់ដារគុណភាពទឹកតាមរយៈ និតិវិធីសម្រាប់គុណភាពទឹក ប្រការនេះជួយក្នុងការរក្សាមុខងារដើមរបស់ទន្លេនេះ និង

លំហូរនៅរដូវប្រាំងតាមធម្មជាតិ និងត្រូវបានការពារ និងស្តង់ដារគុណភាពទឹកត្រូវបានថែរក្សា

- **គ្រប់គ្រងហានិភ័យនៃគម្រោង** ដែលបង្រុមធ្វើស្ថាប័នជាតិ អង្គការអាងទន្លេ (RBOs) សហគមន៍ និង អ្នកអភិវឌ្ឍន៍គម្រោង ចាំបាច់ត្រូវសហការទៅលើការតាក់តែង និងប្រតិបត្តិការគម្រោងទំនប់តាមដៃទន្លេ ដើម្បីកាត់បន្ថយ កំណល្បាប់ និងកំណកចុះនៃជីវជាតិ និងការរាំងស្ទះដល់បម្លាស់ទីត្រី និងឈានដល់កិច្ចព្រមព្រៀងលើវិធានការគ្រប់គ្រង សម្រាប់សារៈសំខាន់តំបន់ដើម (ចេញពីទស្សនវិស័យ ប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅ)។ ការស្វែងរកកាលានុវត្តភាពនឹងត្រូវធ្វើឡើងដើម្បីផ្តោតលើបច្ច័យសង្គមដែលជាប់ទាក់ទងនឹងការអភិវឌ្ឍធនធានទឹកដែលកំពុងដំណើរការ តាមរយៈការកាត់បន្ថយភាពក្រីក្រនៅថ្នាក់ជាតិ និងសកម្មភាពនៃការអភិវឌ្ឍដទៃផ្សេងទៀត។

## ២. ពង្រីក និងកំណត់អត្តសញ្ញាណកសិកម្មដោយប្រព័ន្ធស្រោចស្រពសម្រាប់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ

ការពង្រីកប្រព័ន្ធស្រោចស្រព និងប្រពលភាពរបស់វាដែលបច្ចុប្បន្នស្ថិតក្រោមការពិចារណានឹងបង្កើនផលិតកម្មកសិកម្ម សន្តិសុខស្បៀង ការងារនិងចំណូលពីស្រែចំការ ។ សកម្មភាពកំណត់អត្តសញ្ញាណគម្រោងនឹងមានអត្ថប្រយោជន៍ចំពោះការទាក់ទាញវិនិយោគ។ នៅតំបន់ជាច្រើនមានក្របខ័ណ្ឌសម្រាប់បង្កើនទិន្នផលកសិកម្ម និងបង្កើតចំណូលពីកសិដ្ឋានបានកាន់តែច្រើនតាមរយៈការកែលំអអថេរនានា និងការអនុវត្តកសិកម្ម។ ទិន្នផលកសិកម្មប្រែប្រួលពី ២០០-៤០០% នៅទូទាំងអាងតាមរយៈការបង្ហាញសក្តានុពលដែលអាចពិចារណាបានសម្រាប់ប្រពលវប្បកម្មកសិកម្ម។ ប៉ុន្តែការពង្រីកប្រព័ន្ធស្រោចស្រពវានឹងមិនមែនជាដំណោះស្រាយមួយសំរាប់គ្រោះរាំងស្ងួតដែលកាន់តែកើតឡើងញឹកញាប់ និងច្រើនឡើងចំពោះតំបន់ដែលមានភ្លៀងធ្លាក់តិចតួច ដែលតម្រូវឱ្យមានការស្រោចស្រពច្រើននោះទេ។

យុទ្ធសាស្ត្រកាត់បន្ថយគ្រោះរាំងស្ងួតត្រូវការចាំបាច់សម្រាប់តំបន់ដែលពុំទាក់អាស្រ័យនឹងទឹកភ្លៀង។ នៅតាមតំបន់ខ្វះទឹកក្រោមដីគឺជាដំណោះស្រាយមួយ។គោលការណ៍ណែនាំនឹងត្រូវបានរៀបចំឡើងសម្រាប់ការអភិវឌ្ឍគម្រោងប្រព័ន្ធស្រោចស្រពដែលទាក់ទងនឹងមច្ឆាផងដែរ (ជលផលស្រះតាមវាលស្រែ ឬប្រឡាយ ឬស្ទឹងដែលអាចជួយដល់ការនេសាទជលផលនិងអាចបង្កើតចំណូលជូនកសិករ) បានសម្រាប់ការលើកស្ទួយការធ្វើសមារណកម្មគ្រប់គ្រងថ្នាំកំចាត់កត្តាចង្រៃ សំដៅកាត់បន្ថយហានិភ័យគុណភាពទឹក និងកែលំអការគ្រប់គ្រងប្រព័ន្ធស្រោចស្រព។
យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់លើតម្រូវការ សម្រាប់ជម្រើសវាយតម្លៃការអភិវឌ្ឍវារីអគ្គិសនីតាមដៃទន្លេ

## ៣. បង្កើននិរន្តរភាពនៃការអភិវឌ្ឍវារីអគ្គិសនីឱ្យកាន់តែប្រសើរ

ដោយចីរភាពតាមរយៈការផ្តោតលើហានិភ័យវារីអគ្គិសនីតាមទន្លេមេនិងការវាយតម្លៃទៅលើជម្រើសថាមពលដទៃទៀតសំរាប់វារីអគ្គិសនីតាមទន្លេមេ។

**យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់លើតម្រូវការសម្រាប់ជម្រើសវាយតម្លៃការអភិវឌ្ឍវារីអគ្គិសនីតាមដៃទន្លេដោយចីរភាពតាមរយៈការផ្តោតលើហានិភ័យវារីអគ្គិសនីតាមទន្លេមេ និងការវាយតម្លៃទៅលើជម្រើសថាមពលដទៃទៀតចំពោះវារីអគ្គិសនីតាមទន្លេមេ។**

- **ឆ្ពោះទៅការអភិវឌ្ឍវារីអគ្គិសនីតាមដៃទន្លេដោយចីរភាព** ប្រការនេះរួមមាន:
  - ❒ ការកំណត់អត្តសញ្ញាណថ្នាក់ក្រោមអាងដែលមានសារៈសំខាន់ផ្នែកអេកូឡូស៊ីត្រូវការពារ និងដែលវារីអគ្គិសនីអាចត្រូវបានអភិវឌ្ឍនៅទីនោះដោយមានផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមមានកំណត់
  - ❒ ការវាយតម្លៃគម្រោងវារីអគ្គិសនីដោយប្រើទស្សនវិស័យពហុគោលបំណង ដើម្បីបង្កើនផលប្រយោជន៍សេដ្ឋកិច្ចរួម និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើការប្រើប្រាស់ផ្សេងទៀត
  - ❒ កាត់បន្ថយផលប៉ះពាល់អវិជ្ជមានពីវារីអគ្គិសនី ដូចជាតាមរយៈធ្វើនិយ័តកម្មអាងស្តុកនៅខ្សែទឹកខាងក្រោមឡើងវិញ កម្រិតទឹកហូរចូលចម្រុះឬការបំពាក់ឧបករណ៍បញ្ចូលខ្យល់សម្រាប់ គ្រប់គ្រងគុណភាពទឹក សីតុណ្ហភាពច្រកបង្ហាស់ទីរបស់ត្រី និងកាត់បន្ថយការធ្វើឱ្យមានដំណកដីល្បាប់ឱ្យដល់អប្បបរមា
  - ❒ បង្កើតផែនការគ្រប់គ្រងសម្រាប់ចំណុចប៉ះពាល់បរិស្ថាបធ្ងន់ធ្ងរ ដោយសារបម្រែបម្រួលរបបលំហូរទឹក និង
  - ❒ ធ្វើការវាយតម្លៃលើជម្រើសនៃការចែករំលែកផលប្រយោជន៍ ដូចជាការគ្រប់គ្រង និងអភិវឌ្ឍន៍ទីជម្រាលដែលមានផលប្រយោជន៍ដល់ការបង្កើតវារីអគ្គិសនី និងដែលទទួលបានមូលនិធិចំណូលពីវារីអគ្គិសនី

- **ផ្តោតការពិចារណាលើភាពមិនច្បាស់លាស់ និងហ ានិភ័យនៃទំនប់តាមទន្លេមេដែលអាចកើតមាន** ប្រការនេះរួមមាន: ការទទួលបានចំណេះដឹងសំខាន់ក្នុងការបន្ថយភាពមិនច្បាស់លាស់ឱ្យនៅសល់តិចបំផុត ការកំណត់ជម្រើសកាត់បន្ថយហានិភ័យ ការពង្រឹងដំណើរការនៃនីតិវិធីសំរាប់ ការជូនដំណឹងការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) ការអនុវត្តគោលការណ៍តាក់តែងគម្រោងសម្រាប់ទំនប់តាមទន្លេមេ និងការអភិវឌ្ឍការណែនាំជាក់លាក់សម្រាប់ទំនប់តាមទន្លេមេ និងផលប៉ះពាល់សំណឹកដែលទាំងអស់នេះសំដៅបំពេញបន្ថែមឱ្យការសិក្សាទៅលើគម្រោងជាក់លាក់ ដូចជាការសិក្សាពីលទ្ធភាពគម្រោងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIAs) និងការវាយតម្លៃហេតុប៉ះពាល់សង្គម(SIAs) ។

■ **វាយតម្លៃជម្រើសថាមពលផ្សេងៗ រួមទាំងជម្រើសវារីអគ្គិសនីតាមទន្លេមេ** ជម្រុញការវាយតម្លៃលើផលប្រយោជន៍ និងផលប៉ះពាល់ពីទំនប់វារីអគ្គិសនីតាមទន្លេក្នុងបរិបទនៃការវាយតម្លៃជម្រើសថាមពល ដោយទូលំទូលាយ និងយុទ្ធសាស្ត្រថាមពលនៅថ្នាក់ជាតិ និង ថ្នាក់តំបន់។

## ៤. ទទួលចំណេះដឹងសំខាន់ៗសំរាប់ការវិភាគលើភាពមិនច្បាស់លាស់ និងកាត់បន្ថយហានិភ័យនៃកាលានុវត្តភាពការអភិវឌ្ឍ

ភាពមិនច្បាស់លាស់និងហានិភ័យដែលជាប់ទាក់នឹង កាលានុវត្តភាពអភិវឌ្ឍន៍អាង រួមទាំងភាពមិន ច្បាស់លាស់អំពីការប្រែប្រួលអាកាសធាតុ តម្រូវឱ្យមានការអនុវត្ត អោយបានឆាប់នូវការសិក្សា សំខាន់ជាយុទ្ធសាស្ត្រៗជាច្រើន ដើម្បីបំពេញគម្លាតចំណេះដឹង និងដើម្បីបង្កើតវិធានការកាត់ បន្ថយហានិភ័យចាំបាច់សម្រាប់កាលានុវត្តភាពសំដៅឆ្ពោះដំណាក់កាលបន្ទាប់នៃការសិក្សាឬការវាយតម្លៃលើអន្តរព្រំប្រទល់ដែលតម្រូវឱ្យធ្វើ។ បញ្ជីនៃការសិក្សាទាំងនេះមាននៅក្នុងផ្នែក ៤.៤ ខាងក្រោម។ ការវិភាគបន្ទាន់នឹងត្រូវធ្វើទៅលើ:

> **សំខាន់នៃការសិក្សានិងត្រូវបានធ្វើឡើង ដើម្បីដោះស្រាយភាពមិនទៀងទាត់ និងហានិភ័យនៃកាលានុវត្តភាពអភិវឌ្ឍន៍អាង**

■ **កំណកល្បាប់ និងជីវជាតិ និងវិបាកនៃហានិភ័យរបស់វា** ព្យាករណ៍ការផ្លាស់ប្តូរនៃការហូរនាំល្បាប់ពីការអភិវឌ្ឍធនធានទឹកដែលកំពុងដំណើរការ និងដែលគ្រោងធ្វើ។ វិភាគផលប៉ះពាល់នៃបម្លាស់ប្តូរទាំងនេះទៅលើស្នាមប្រេះនៅបាតទន្លេ។ សំណឹកហូរច្រោះច្រាំងទន្លេ គុណភាពទឹក កំណកល្បាប់នៅវាលទំនាបលិចទឹក ផលិតភាពជលផលដីកសិកម្ម និងតំបន់ដីសើមដំណើរការរៀបចំទ្រង់ទ្រាយដីសណ្តរ និងចលនាកំណកចូលទៅសមុទ្រ។ កំណត់វិធានការបញ្ចៀស កាត់បន្ថយ និងពង្រឹង។

■ **ការធ្លាក់ចុះនៃនេសាទជលផល និងបច្ច័យសង្គមនិងកំណត់** គន្លងបម្លាស់ទីរបស់ត្រីផលប៉ះពាល់ ដោយសម្រាស់ធម្មជាតិ និងសម្រាស់ធ្វើដោយមនុស្សដែលមាន និងភស្តុតាងនៃការបន្សាំ ផលិតភាពត្រី និងសុខភាពស្ថិតក្រោមគំនាបអភិវឌ្ឍន៍ និងបច្ច័យសង្គមដែលជាប់ទាក់ទងព្រមទាំងជម្រើសបច្ចេកវិទ្យាសម្រាប់ច្រកត្រីឆ្លងកាត់ និងតួនាទីសំខាន់នៃផលិតកម្ម ជលផល (ស្រែស្រះ វារីវប្បកម្ម និងអាងស្តុកទឹក) និងការថ្លឹងថ្លែងនូវការបាត់បង់នៃសាទជលផល (រួមទាំងប្រភេទសំខាន់ៗនានា) ដោយសារការអភិវឌ្ឍទឹក។

■ **បម្រែបម្រួលជីវចម្រុះ** កំណត់វិបាកនៃការអភិវឌ្ឍជីវចម្រុះ និងសូចនាករសមស្រប និងគោលវង្វាស់វវាងរបស់វាសម្រាប់ត្រួតពិនិត្យការបាត់បង់ជីវចម្រុះ។ អភិក្រមគន្លឹះមួយ គឺធ្វើការពិចារណាទៅលើជីវៈសំខាន់ៗប៉ុន្តែទស្សនៈទូលំទូលាយមួយ គឺចាំបាច់ត្រូវមានដើម្បីការពារជីវៈទាំងនោះដែលនេះជាផ្នែកបញ្ញាលគ្នានូវមុខងារតំបន់ដីសើម និងសេវាកម្ម និងដែលទាមទារឱ្យមានផែនទីផ្នែកប្រព័ន្ធអេកូឡូស៊ី រួមទាំងទីជម្រក និងតួនាទីរបស់ទឹកដីល្បាប់ និងលំហូរជីវជាតិ និង

■ **ផលប៉ះពាល់សង្គម និងជីវភាពរស់នៅតាមច្រករបៀងទន្លេមេនៅទន្លេសាប និងតាមប្រព័ន្ធទន្លេទាំង៣**

ស្រាវជ្រាវអំពីផលប៉ះពាល់ និងហានិភ័យនៃការអភិវឌ្ឍដែលកំពុងដំណើរការ និងដែលគ្រោងធ្វើទៅលើជីវិតរស់នៅរបស់ស្ត្រី និងបុរសនៅក្នុងតំបន់ទាំងនេះ និងកំណត់ដំណោះស្រាយដើម្បីកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា។

## ៥. ស្វែងរកជម្រើសសម្រាប់ការចែករំលែកផលប្រយោជន៍សំខាន់ៗរួម និងហានិភ័យនៃកាលានុវត្តភាពអភិវឌ្ឍន៍

**ផលប្រយោជន៍សំខាន់ៗពីកាលានុវត្តភាពអភិវឌ្ឍន៍ដែលបានកំណត់រួចអាចត្រូវបានចែករំលែកដើម្បីផ្តល់នូវសំណាងរំលោះនិង/ឬផ្តោតលើហានិភ័យចំពោះបរិស្ថាន វិស័យផ្សេងទៀតដែលទាក់ទងនឹងទឹក និងជីវភាពរស់នៅរបស់ប្រជាជន។**

ផលប្រយោជន៍សំខាន់ៗពីកាលានុវត្តភាពអភិវឌ្ឍន៍ដែល (ឧទាហរណ៍ពីលំហូរទឹករដូវប្រាំបន្ថែមសម្រាប់ការផ្គត់ផ្គង់ទឹកនាវាចរណ៍ប្រព័ន្ធស្រោចស្រព និងផលប្រយោជន៍នៃការប្រើប្រាស់ផ្សេងៗនិងពីការអភិវឌ្ឍវារីអគ្គិសនី)អាចត្រូវបានចែករំលែក ដើម្បីផ្តល់នូវសំណងរំលោះនិង /ឬ ផ្តោតលើហានិភ័យចំពោះបរិស្ថានវិស័យដទៃទៀតដែលទាក់ទងនឹងទឹក និងជីវភាពរស់នៅរបស់ប្រជាជន។ ជម្រើសនឹងត្រូវបានកំណត់ ហើយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS)នឹងជួយគាំទ្រ ព្រមទាំងជួយសម្រួលដល់ដំណោះស្រាយដោយមានការចរចារសម្រាប់ចែករំលែកផលប្រយោជន៍ និងហានិភ័យដែលជាចំណុចរសើប ចំពោះតំបន់ដោយប្រយោជន៍គណៈកម្មការទន្លេមេគង្គ និងគោរពទៅតាមយុទ្ធសាស្ត្រ និងស្មារតីអភិវឌ្ឍន៍សម្រាប់កិច្ចសហប្រតិបត្តិការភាគីក្នុងតំបន់។

## ៦. បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

ការកាត់បន្ថយផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុជាចំណុចចំបងពាក់ព័ន្ធនឹងថាមពលដែលការបន្សុំាមានជាប់ទាក់ទងសំខាន់ទៅនឹងទឹក។ការព្យាករណ៍អាចធ្វើបានតែក្នុងករណីនៃភាពមិនច្បាស់លាស់ធំៗ ប៉ុន្តែការគម្រាមកំហែងមានលក្ខណៈធ្ងន់ធ្ងរខ្លាំង។ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលត្រូវបានព្យាករណ៍ថានឹងធ្វើអោយផ្លាស់ប្តូរធនធានទឹក និងធនធានដែលពាក់ព័ន្ធរបស់អាងមេគង្គពីរយៈពេលមធ្យមទៅរយៈពេលវែង នឹងត្រូវបានដោះស្រាយ និងចាត់ចូលជាផ្នែកមួយសំខាន់នៃការវាយតម្លៃដែលបានអនុវត្តសម្រាប់កាលានុវត្តភាពអភិវឌ្ឍអាងដូចដែលមានយោងនៅក្នុងយុទ្ធសាស្ត្រនេះ។

លទ្ធផលនេះនឹងត្រូវប្រើប្រាស់ក្នុងការរៀបចំនិងក្នុងការចរចារអំពីយុទ្ធសាស្ត្របន្សុំាចំពោះការប្រែប្រួលអាកាសធាតុសម្រាប់អាងទន្លេមេគង្គក្រោម យុទ្ធសាស្ត្រនេះនឹងត្រូវបានបញ្ជ្រាបទៅក្នុងប្រព័ន្ធការធ្វើផែនការជាតិ និងផែនការអាងរយៈពេល៤ឆ្នាំ និងរយៈពេលវែង។

វិធានការបន្សុំាដែលបានជ្រើសនឹងត្រូវបានសាកល្បងដើម្បីស្វែងរកកម្រិតនៃភាពជោគជ័យ។ អាទិភាពនឹងត្រូវបានផ្តល់ដល់សកម្មភាពបន្សុំាតាមរយៈការផ្តោមលើៈ ការកើនឡើងនៃគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតរួមទាំងការកែលំអការព្យាករណ៍ និងប្រព័ន្ធប្រកាសព័ត៌មានដំបូង និងការកាត់បន្ថយការ

ខូចខាត ការអភិវឌ្ឍន៍វារីអគ្គិសនីដោយនិរន្តភាព សន្តិសុខស្បៀង រួមទាំងកសិកម្ម និងជលផល តំបន់ដីសើម និងជីវចម្រុះជីវភាពរស់នៅរបស់ក្រុមដែលងាយរងគ្រោះ និងការរកើនឡើងនូវកម្ពស់ទឹកសមុទ្រនៅតាមដីសណ្តរមេគង្គ។

## ៧. ការពិចារណាបញ្ចូលផែនការអភិវឌ្ឍន៍

យុទ្ធសាស្ត្រនេះ នឹងទទួលបានជោគជ័យប្រសិន បើវាត្រូវបានដាក់បញ្ជ្រាបទៅក្នុងដំណើរការធ្វើសេចក្តីសម្រេច និងការធ្វើផែនការជាតិគួបផ្សំជាមួយប្រទេសនីមួយៗ ដែលមានគោលការណ៍គ្រឹះ ដំណើរការនិង សកម្មភាពអភិវឌ្ឍន៍ ជាក់លាក់របស់ប្រទេស។ កំណើនឡើងនៃវិស័យឯកជនយ៉ាងឆាប់រហ័សទៅលើវិស័យទាក់ទងនឹងទឹក សង្កត់ធ្ងន់ទៅលើសារៈសំខាន់តួនាទីរបស់ស្ថាប័នគ្រប់គ្រងធនធានទឹកថ្នាក់ជាតិ (ក្រសួងធនធានទឹកនិងឧតុនិយមនៅកម្ពុជារដ្ឋបាលធនធានទឹក និងបរិស្ថាននៅឡាវ ក្រសួងធនធានធម្មជាតិ និងបរិស្ថាននៅថៃ និងក្រសួងធនធានធម្មជាតិនិងបរិស្ថាននៅវៀតណាម) ដោយមានការសម្របសម្រួលអភិក្រមបញ្ចូលគ្នាមួយជាមួយការធ្វើផែនការ តាមវិស័យទាំងវិស័យនៅថ្នាក់ជាតិនិងនៅថ្នាក់តំបន់។ យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់លើសារៈសំខាន់ខ្លាំងនៃការពង្រឹងការអនុវត្តនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ។ ការអនុវត្តយុទ្ធសាស្ត្រនេះ ទាមទារនូវសកម្មភាពបញ្ចូលគ្នាដូចតទៅ:

**កំណើនឡើងនៃវិស័យឯកជនយ៉ាងឆាប់រហ័សទៅលើវិស័យទាក់ទងនឹងទឹកសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃតួនាទីរបស់ស្ថាប័នគ្រប់គ្រងធនធានទឹកថ្នាក់ជាតិដោយមានការសម្របសម្រួលអភិក្រមបញ្ចូលគ្នាមួយជាមួយការធ្វើផែនការតាមវិស័យទាំងវិស័យនៅថ្នាក់ជាតិ និងថ្នាក់តំបន់។**

- **បន្សីការធ្វើផែនការអភិវឌ្ឍន៍ធនធានទឹកនៅថ្នាក់ជាតិ និងការកំណត់អត្តសញ្ញាណគម្រោង** ជាមួយកាលានុវត្តភាពអភិវឌ្ឍន៍ដែលបានកំណត់ដើម្បីធានាឆ្ពោះទៅការអភិវឌ្ឍន៍ដោយចីរភាព។

- **ផ្តោតលើហានិភ័យពីជំហូងទីដែលបានកំណត់នៅក្នុងដំណាក់កាលរៀបចំ** និងកំណត់អត្តសញ្ញាណគម្រោងដែលនឹងផ្តល់កាលានុវត្តភាពមួយសម្រាប់គម្រោងកាន់តែឆ្លើយតបទៅនឹងបទបញ្ញត្តិថ្នាក់ជាតិការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) តាមដែលអាចធ្វើទៅបាន និង

- **រក្សាការចុះបញ្ជីគម្រោងទាក់ទងនឹងទឹក និងការអភិវឌ្ឍធនធានទឹកដែលមាន ដែលកំពុងអនុវត្ត និងដែលគ្រោងរួច នៅលេខាធិការដ្ឋានគណៈកម្មាធិការជាតិគណៈកម្មាធិការជាតិទន្លេមេគង្គ នៅប្រទេសសមាជិកទាំងបួន** (NMCSs) **និងនៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ** (MRCS) ដើម្បីជួយសម្រួលការត្រួតពិនិត្យការងារអភិវឌ្ឍន៍ទឹក នៅអាងទន្លេមេគង្គភាគខាងក្រោមនៅថ្នាក់ជាតិ និងថ្នាក់តំបន់និងដើម្បីផ្តល់ដំបូន្មានទាន់ ពេលអំពីហានិភ័យអន្តរព្រំប្រទល់។ ប្រការនេះនឹង ជួយជម្រុញដល់ការអភិវឌ្ឍ និងការផ្សព្វផ្សាយអំពីសំណុំឯកសារគម្រោងដើម្បីគាំទ្រដល់ការគ្រប់គ្រងអាងដោយមានការសម្របសម្រួល។

## ៤.៣ អាទិភាពយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងអាង

### ១. បង្កើតកម្មវត្ថុ និងយុទ្ធសាស្ត្រគ្រប់គ្រងអាងសម្រាប់វិស័យទាក់ទងនឹងទឹក

*ការបញ្ចូលនូវយុទ្ធសាស្ត្រគ្រប់គ្រងសម្រាប់ជលផល នាវាចរណ៍ហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួត ទេសចរណ៍ ប្រព័ន្ធអេកូឡូស៊ី តំបន់ដីសើម និងទីជម្រាលជាមួយគ្នាមាន សារៈសំខាន់សម្រាប់ការធ្វើផែនការអាង។*

ការបញ្ចូលនូវយុទ្ធសាស្ត្រគ្រប់គ្រងសម្រាប់ ជលផល នាវាចរណ៍ ហានិភ័យទឹកជំនន់ និងគ្រោះរាំងស្ងួតទេសចរណ៍ ប្រព័ន្ធអេកូឡូស៊ី តំបន់ដីសើម និងទីជម្រាលជាមួយគ្នា មានសារៈសំខាន់សម្រាប់ការធ្វើផែនការអាង។ អាទិភាពដំបូងនឹងត្រូវផ្តល់ដល់៖

- **ការគ្រប់គ្រងជលផល** កត្តានេះតម្រូវឱ្យមានការសិក្សា ដើម្បីបង្កើនចំណេះដឹងផ្នែកជលផលឱ្យកាន់តែប្រសើរ(អាទិភាពយុទ្ធសាស្ត្រទី១ ក្នុងផ្នែក៤.២) និងការអភិវឌ្ឍយុទ្ធសាស្ត្រគ្រប់គ្រងតជលផលតាម អាងនិងដោយទូលំលាយដោយផ្អែកលើយុទ្ធសាស្ត្រនិងផែនការជាតិការសិក្សាតាមអាងថ្មីៗនេះរបស់គណៈកម្មការទន្លេមេគង្គ និងការប្រតិបត្តិល្អប្រសើររបស់អន្តរជាតិ។ កត្តានេះចាំបាច់ត្រូវមានឥទ្ធិពល និងមានការណែនាំអភិវឌ្ឍន៍អាង និងការធ្វើផែនការគ្រប់គ្រងសម្រាប់៥ឆ្នាំខាងមុខទៀត។

- **ការធ្វើនាវាចរណ៍**
  កម្មវិធីនាវាចរណ៍របស់គណៈកម្មការទន្លេមេគង្គ នឹងរៀបចំផែនការមេមួយសម្រាប់ការដឹកជញ្ជូល តាមផ្លូវទឹកថ្នាក់តំបន់និងការអភិវឌ្ឍន៍ការដឹកជញ្ជូលតាមទឹកនៅជនបទ ផែនការមេសម្រាប់ នាវាចរណ៍នៅកម្ពុជា និងផែនការកែលំអនាវាចរណ៍មួយឱ្យកាន់តែប្រសើរ ដែលនឹងបន្តកំណត់រកកាលានុវត្តភាពការអភិវឌ្ឍសម្រាប់នាវាចរណ៍(មើលផ្នែក ៤.១)។ ផែនការទាំងនេះក៏នឹងកំណត់អត្តសញ្ញាណយុទ្ធសាស្ត្រដើម្បីគ្រប់គ្រងហានិភ័យនៃនាវាចរណ៍ដែលកើនឡើងដូចជាគ្រោះថ្នាក់ និងការបំផ្លិចបំផ្លាញបរិស្ថាន។

- **ការគ្រប់គ្រងហានិភ័យនៃគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត**
  របបលំហូរផ្លូវទឹកទន្លេមេគង្គ និងតាមដៃទន្លេ នឹងមានការផ្លាស់ប្តូរហើយការប្រែប្រួលអាកាសធាតុត្រូវបានព្យាករណ៍ថា នឹងមានការកើនឡើងជាញឹកញាប់ និងស្ថានភាពធ្ងន់ធ្ងរនៃហេតុការណ៍ ទឹកជំនន់ការវិភាគលំអិតនឹងត្រូវធ្វើទៅលើបម្រែបម្រួលលំហូរ និងទឹកជំនន់នៅតាមទន្លេមេពីតំបន់ភាគខាងជើងប្រទេសថៃទៅកាន់ដីសណ្តរ ដែលជាព័ត៌មានមួយដាក់បញ្ចូលក្នុងការធ្វើផែនការរួមតាមរយៈផែនទីនិង

- **ការគ្រប់គ្រងតំបន់ដីសើម**
  បម្រែបម្រួលក្នុងរបបលំហូរនឹងជះឥទ្ធិពលដល់បម្លាស់ប្តូរយ៉ាងខ្លាំងនៃតំបន់ដីសើម ដែលប្រែប្រួលដល់អថេរប្រចាំរបស់វា និងបង្កើននូវការភាគបំណែករបស់វា។ តំបន់ដីសើមដើរតួនាទីសំខាន់សម្រាប់ជីវភាពរស់នៅរបស់ប្រជាជបក្រីក្រជាច្រើន។ ការយកចិត្តទុកដាក់ជាអាទិភាពនិងអាស្រ័យលើសេវាកម្មរបស់វា ដូចជាទន្លេសាប។

សកម្មភាព នឹងរួមបញ្ចូលនូវការត្រួតពិនិត្យការបាត់បង់ជីវចម្រុះការលើកស្ទួយការធ្វើសមាហរណកម្មគ្រប់គ្រងតំបន់ដីសើមនិងការគាំទ្រការអនុវត្តអនុសញ្ញារ៉ាំសារ (RAMSAR)។

## ២. ពង្រឹងដំណើរការគ្រប់គ្រងធនធានទឹកនៅថ្នាក់ជាតិ

យុទ្ធសាស្ត្រនេះអាស្រ័យនឹងការអនុវត្តដោយប្រសិទ្ធភាពនៅតាមប្រទេសទាំងអស់ទៅលើដំណើរការមូលដ្ឋាននៃការត្រួតពិនិត្យទឹកលើដីនិងទឹកក្រោមដីការចេញអាជ្ញាប័ណ្ណប្រើប្រាស់ទឹក (ការទាញយកនិងបញ្ចេញជាតិពុល)បទបញ្ញត្តិ និងលក្ខខណ្ឌអាជ្ញាប័ណ្ណក្នុងការធានាការស្របច្បាប់ និងការថែទាំរក្សាប្រព័ន្ធព័ត៌មានទឹកតាមកុំព្យូទ័រ។ កត្តានេះនឹងផ្តល់ជាមូលដ្ឋានគ្រឹះរឹងមាំសម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកនៅក្នុងអាងនេះ។បង្កើននិងថែរក្សាឱ្យបាននូវកិច្ចការសំខាន់ទាំងនេះតម្រូវឱ្យមានហិរញ្ញវត្ថុបន្ថែមទៀត។

**យុទ្ធសាស្ត្រនេះទទួលស្គាល់សារសំខាន់នៃការអភិវឌ្ឍន៍ កម្មវត្ថុតាមអាង ឬ "ស្វែងរកការរៀបចំគោល" ដោយមានការព្រមព្រៀងដែលនឹងគ្រប ដណ្តប់លើកត្តា បរិស្ថាន សង្គម និង សេដ្ឋកិច្ច តាមរយៈការឆ្លុះបញ្ចាំង និង ការគិតគូដល់ អធិតេយ្យភាពជាតិ គោលនយោបាយ និងដំណើរការ។**

## ៣. ពង្រឹងដំណើរការគ្រប់គ្រងអាង

### ■ ការអនុវត្តនិតិវិធីរបស់គណៈកម្មការទន្លេមេគង្គ ( តារាងទី២)

យុទ្ធសាស្ត្រនេះអះអាងឡើងវិញនូវភាពជាប់ពាក់ព័ន្ធនិងសារៈសំខាន់នៃនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ និងពង្រឹងការអនុវត្តនិងប្រសិទ្ធភាពរបស់វាដោយជម្រុញឱ្យដំណើរការទៅបានសម្រាប់ការអភិវឌ្ឍអាងដោយចីរភាព។



## តារាងទី២ នីតិវិធីរបស់គណៈកម្មការទន្លេមេគង្គ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធ

| នីតិវិធី និងគោលការណ៍ណែនាំបច្ចេកទេស | ស្ថានភាព |
| --- | --- |
| នីតិវិធីសម្រាប់ការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន (PDIES) | អនុម័តដោយក្រុមប្រឹក្សាគណកម្មការទន្លេមេគង្គ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០១ |
| គោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការអនុវត្ត នីតិវិធីការដោះដូរ និងការចែករំលែកទិន្នន័យ និងព័ត៌មាន (PDIES) | អនុម័តដោយគណកម្មការធិការរួមនៃគណកម្មការទន្លេមេគង្គនៅខែកក្កដា ឆ្នាំ២០០២ |
| និតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) | អនុម័តដោយក្រុមប្រឹក្សានៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ |
| គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការអនុវត្តនិតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) | អនុម័តដោយគណកម្មាធិការរួមនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៥ |
| នីតិវិធីសម្រាប់ការតាមដានការប្រើប្រាស់ទឹក (PWUM) | អនុម័តដោយក្រុមប្រឹក្សា ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៣ |
| គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការអនុវត្តនីតិវិធីសម្រាប់ការត្រួតពិនិតតាមដានការប្រើប្រាស់ទឹក (PWUM) | អនុម័តដោយគណកមាធិការរួម នៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០០៦ |
| នីតិវិធីសម្រាប់ការរក្សាលំហូរនៅលើទន្លេមេ (PMFM) | អនុម័តដោយក្រុមប្រឹក្សា ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៦ |
| គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការអនុវត្តនីតិវិធីសម្រាប់ការរក្សាលំហូរនៅលើទន្លេមេ (PMFM) | កំពុងរៀបចំ |
| នីតិវិធីសម្រាប់គុណភាពទឹក (PWQ) | អនុម័តដោយក្រុមប្រឹក្សានៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ |
| គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការអនុវត្តនីតិវិធីសម្រាប់គុណភាពទឹក (PWQ) | កំពុងរៀបចំ |



- **ឧបករណ៍ និងវិធីសាស្ត្រដែលស៊ីសង្វាក់គ្នា** ពង្រឹង និងធ្វើឱ្យស្តង់ដារ ឧបករណ៍ ប្រព័ន្ធធានាគុណភាព សម្រាប់ការគ្រប់គ្រងធនធានទឹកអោយស៊ីសង្វាក់គ្នា។ បើមានភាពខុសបែកគ្នាខ្លាំងរវាងប្រទេសនៅអាងទន្លេមេគង្គភាគខាងក្រោមនោះវាមានការលំបាក ក្នុងការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានដែលអាចទុកចិត្តបាន ក្នុងការចរចាររកកិច្ចព្រមព្រៀងដែលសមហេតុផល និងរក្សាកិច្ចសហប្រតិបត្តិការដោយប្រសិទ្ធិភាព។

- **ស្ថានភាពត្រួតពិនិត្យ និង ធ្វើរបាយការណ៍អាង** ពង្រឹងប្រព័ន្ធតាមដានពីថ្នាក់ជាតិដល់តំបន់ ដែលអាចឈានដល់ទិដ្ឋភាពផ្សេងនៃធនធានទឹក និងធនធានពាក់ព័ន្ធ និងត្រួតពិនិត្យផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយះវេទិកាមេគង្គស្តីពីការប្រែប្រួលអាកាសធាតុ (កំពុងត្រូវបានបង្កើតដោយគណកម្មការទន្លេមេគង្គ)។ ប្រការនេះនឹងឈានដល់ការធ្វើរបាយការណ៍រៀងរាល់៥ឆ្នាំម្តងនូវស្ថានភាពអាង។

- **ការតាមដានវដ្តគម្រោងសំដៅគាំទ្រការធ្វើផែនការអាង**
  ការអភិវឌ្ឍ និងការអនុវត្តប្រព័ន្ធតាមដានការអភិវឌ្ឍគម្រោងទូលំទូលាយមួយនៅក្នុងអាងដោយប្រើប្រាស់នីតិវិធីរបស់គណៈកម្មការទន្លេមេគង្គសម្រាប់ការដោះដូរ និងចែករំលែកទិន្នន័យនិងព័ត៌មាន (PDIES) និងនីតិវិធី ការតាមដានការប្រើប្រាស់ទឹក (PWUM) និងឧបករណ៍ដទៃទៀត។

  កំណត់ត្រានេះនឹងជួយឱ្យមានការចុះបញ្ជីគម្រោងជាលក្ខណៈជាតិបានរហ័សជាមួយបច្ច័យអន្តរព្រំប្រទល់នៅក្នុងគម្រោងទិន្នន័យមូលដ្ឋានមេ និងកំណត់ត្រាស្ថានភាព និងលក្ខណៈចំបងរបស់វាដើម្បីដឹកនាំការវាយតម្លៃកំណើនបន្តបន្ទាប់តាមអាងតាមដានការប្រើប្រាស់ក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍ (DOS) ផ្តួចផ្តើមធ្វើកិច្ចសន្ទនាអំពីគម្រោង ដែលមានវាទប្បដិវាទ និងបន្ថែមគម្រោងដែលទទួលបានការអនុម័តនៅថ្នាក់ជាតិ និងថ្នាក់តំបន់នៃអន្តរព្រំប្រទល់ចំពោះសំណុំឯកសារគម្រោងសម្រាប់ជម្រុញ ការលើកស្ទួយ និងការអនុវត្តដែលជាផ្នែកមួយនៃការអនុវត្តយុទ្ធសាស្ត្រនេះ។

> **កំណើនឡើងនៃវិស័យឯកជនយ៉ាងឆាប់រហ័សទៅលើវិស័យទាក់ទង នឹង ទឹកសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃតួនាទីរបស់ស្ថាប័នគ្រប់គ្រងធនធានទឹកថ្នាក់ជាតិដោយមានការសម្របសម្រួលអភិក្រមបញ្ចូលគ្នាមួយជាមួយការធ្វើផែនការតាមវិស័យទាំងវិស័យនៅថ្នាក់ជាតិ និងថ្នាក់តំបន់។**

- **បណ្តាញនៃស្ថានជាតិគ្រប់គ្រងធនធានទឹក និងអង្គការអាងទន្លេ** (RBOs) ជនបង្គោលសម្រាប់ការអនុវត្តយុទ្ធសាស្ត្រ គឺស្ថាប័នជាតិគ្រប់គ្រងធនធានទឹកដែលជាអាជ្ញាធរសំខាន់សម្រាប់ការងារធនធានទឹកក្នុងប្រទេសនីមួយៗ រួមជាមួយនឹងគណៈកម្មាធិការទន្លេមេគង្គទាំង៤ និងអង្គការអាងទន្លេនានា។ អង្គភាពទាំងនេះ នឹងធ្វើសកម្មភាពជាទៀងទាត់តាមរយៈ បណ្តាញមួយដោយមានការជួយសម្រួលពីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គជាមួយគោលបំណងពង្រឹងតួនាទីនៃការធ្វើផែនការគ្រប់គ្រងធនធានទឹកចម្រុះរបស់ខ្លួន ការសម្របសម្រួល និងការត្រួរពិនិត្យ និងការអភិវឌ្ឍអាងជារួម។

> **ការអភិវឌ្ឍន៍បណ្តាញស្ថាប័នគ្រប់គ្រងធនធានទឹកថ្នាក់ជាតិ និងអង្គការអាងទន្លេ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពនៃការអនុវត្តការកសាងសមត្ថភាពលើបញ្ហាគ្រប់គ្រងធនធានទឹកចម្រុះ (IWRM)។**

- **ពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធ** ពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់តំបន់នឹងផ្អែកលើដំណើរការ ដែលត្រូវបានបង្កើតនៅក្នុងការរៀបចំយុទ្ធសាស្ត្រការគោរពសិទ្ធិសហគមន៍ និងអភិក្រមការចូលរួមយ៉ាងទូលំទូលាយតាមប្រទេសនីមួយៗ។បង្កើនលទ្ធភាពអ្នកពាក់ព័ន្ធក្នុងការទទួលបាននូវព័ត៌មានដែលត្រូវបានធានាតាមរយៈការអនុវត្តយុទ្ធសាស្ត្រ ទំនាក់ទំនង និងគោលនយោបាយបើកចំហរព័ត៌មានរបស់គណៈកម្មការការទន្លេមេគង្គ។

- **ការគ្រប់គ្រងភាពខុសប្លែកគ្នា** កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥(មាត្រា៣៤ និង៣៥)មានប្រការដែលចែងអំពីដំណោះស្រាយជម្លោះ។ ប៉ុន្តែវាអាចជាបញ្ហាដោយឡែក ដែលជាប់ទាក់ទងនឹងការអភិវឌ្ឍន៍អាង ដូចជាបង្កើនការអភិវឌ្ឍន៍វារីអគ្គិសនីដែលអាចនាំឱ្យមានទំនាស់រវាងវិស័យ ឬរវាងប្រទេស។ ក្នុងករណីដែលវាអាចសមស្របសម្រាប់ទំនាស់ដែលមិនអាចដោះស្រាយបានក្នុង(ការអនុវត្តតាមនីតិវិធីជាក់លាក់នៅក្នុងកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ វាគួរតែបានចាត់ទុកថាជា "ដំណើរការមួយដែលត្រូវប្រកាន់យកចុងក្រោយ"។ ការពិចារណានឹងត្រូវផ្ដល់ចំពោះការអភិវឌ្ឍនូវគោលការណ៍ណែនាំ ឬ យន្តការដែលនឹងជួយដល់ភាគីទាំងឡាយក្នុងការពិភាក្សា និងចរចារនៅកម្រិតបច្ចេកទេសនានានិងតាមកាចាំបាច់នៅកម្រិតគោលនយោបាយថ្នាក់លើ។

## ៩. បង្កើតកម្មវត្ថុបរិស្ថាន និងសង្គម និងសូចនាករង្វាស់គោល

**យុទ្ធសាស្ត្រនេះទទួលស្គាល់សារសំខាន់នៃការអភិវឌ្ឍន៍ កម្មវត្ថុតាមអាង ឬ "សូចនាករង្វាស់គោល" ដោយមានការព្រមព្រៀងដែលនឹងគ្របដណ្ដប់លើកត្តា បរិស្ថាន សង្គម និង សេដ្ឋកិច្ចតាមរយៈការឆ្លុះបញ្ចាំង និង ការគិតគូរដល់អធិបតេយ្យភាពជាតិ គោលនយោបាយ និងដំណើរការ។**

យុទ្ធសាស្ត្រនេះទទួលស្គាល់សារៈសំខាន់នៃការអភិវឌ្ឍកម្មវត្ថុតាមអាងឬ"សូចនាករង្វាស់គោល"ដោយមានការព្រមព្រៀងដែលនឹងគ្របដណ្ដប់លើកតមានការព្រមព្រៀង ដែលនឹងគ្របដណ្ដប់លើកត្តា បរិស្ថាន សង្គម និងសេដ្ឋកិច្ច តាមរយៈការឆ្លុះបញ្ចាំង និងការគិតគូរដល់អធិបតេយ្យភាព ជាតិគោលនយោបាយ និងដំណើរការ។ វាជាការចាំបាច់បន្ទាន់ដើម្បីណែនាំ ការអនុវត្តនិង ធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រ និងដើម្បីផ្ដល់មូលដ្ឋានមួយដែលអាចវាយតម្លៃផលប៉ះពាល់ជម្រើសការអភិវឌ្ឍ។

កម្មវត្ថុមួយចំនួនកំពុងត្រូវបានបង្កើនឡើងជាផ្នែកមួយនៃគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការអនុវត្តនីតិវិធីរបស់គណៈកម្មទន្លេមេគង្គ ដូចជាក្របខ័ណ្ឌកម្រិតលំហូរនៅទន្លេមេគង្គ (ដូចចែងក្នុង PMFM) និងប៉ារ៉ាម៉ែត្រគុណភាពទឹកសម្រាប់សុខភាពមនុស្ស ជីវៈក្នុងទឹក និងស្ថានភាពគុណភាពទឹក (ដូចមានចែងក្នុង PWQ)។ កម្មវត្ថុផ្សេងទៀតត្រូវបានភ្ជាប់ ការតាំងចិត្តទៅនឹងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ទី៧ ស្ដីពីនិរន្តរភាពធនធាន បរិស្ថាន ដែលផ្ដោតលើការកាត់បន្ថយការបាត់បង់ជីវចម្រុះ ។

## ៥. អនុវត្តកម្មវិធីកសាងសមត្ថភាពគោលដៅគ្រប់គ្រងធនធានទឹកចម្រុះ (IWRM)

ការអនុវត្តយុទ្ធសាស្ត្រនេះនឹងទាមទារឱ្យមាននូវៈការរៀបចំស្ថាប័នដ៏រឹងមាំជំនាញការទាំងបុរស និងស្ត្រីនៅក្នុងតំបន់ពាមប្រកបដោយសមត្ថភាពលើគ្រប់វិស័យទាក់ទង នឹងទឹកចេះដឹងពីដំណើរការធ្វើសេចក្តីសម្រេច និងធ្វើផែនការនៅកម្រិតអាងនិងនៅថ្នាក់ជាតិ ព្រមទាំងការប្រាស្រ័យទាក់ទង និងការចូលរួមដោយប្រសិទ្ធភាព ដើម្បីធានាការចូលរួមពីរាល់ក្រុមអ្នកពាក់ព័ន្ធនឹងអាងទាំងអស់។ យុទ្ធសាស្ត្រនេះ មានរួមទាំងការអនុវត្តកម្មវិធីកសាងសមត្ថភាពដែលជាគោលដៅ ដោយផ្សារភ្ជាប់ទៅនឹងគំនិតផ្តួចផ្តើមរួមរបស់គណៈកម្មការទន្លេមេគង្គ និងដែលជួយបំពេញបន្ថែមដល់សកម្មភាពកសាងសមត្ថភាពថ្នាក់ជាតិ។

### ៤.៤ ការសិក្សា និងគោលការណ៍នាំការសិក្សា

#### ការសិក្សា

យុទ្ធសាស្ត្រនេះ (ផ្នែក ៤.២.១)បង្ហាញច្បាស់ពីការសិក្សាបន្ទាន់សំដៅ ផ្តល់ព័ត៌មានដែលត្រូវការសម្រាប់ការធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍធនធានទឹកដែលបានគ្រោង។ តារាងទី៣ បង្ហាញពីការសិក្សាសារៈសំខាន់យុទ្ធសាស្ត្រដទៃផ្សេងទៀតក្នុងការបំពេញកង្វះខាតចំណេះដឹងបច្ចុប្បន្នលើកម្រិតមួយដែលអាចទទួលយកបាន និងគាំទ្រការអនុវត្តអាទិភាពយុទ្ធសាស្ត្រនេះ។



### ការគ្រប់គ្រងធនធានទឹក និងគោលការណ៍ណែនាំតាមវិស័យ

សារសំខាន់នៃគោលការណ៍ណែនាំក្នុងការគ្រប់គ្រងធនធានទឹកតាមអាងនិងគោលការណ៍ណែនាំចាំបាច់សម្រាប់ផ្តោតលើបញ្ហាអភិវឌ្ឍន៍ និងគ្រប់គ្រងតាមវិស័យនៅក្នុងអាងត្រូវបានកំណត់អត្តសញ្ញាណ។ គោលការណ៍ណែនាំមួយចំនួនត្រូវបាន ឬបានកំពុងរៀបចំដោយគណៈកម្មការទន្លេមេគង្គដូចជាក្របខ័ណ្ឌនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅតំបន់ឆ្លងដែន (TBEIA) ការណែនាំតាក់តែងក្នុងដំណាក់កាលដំបូងសម្រាប់វារីអគ្គិសនីនៅតាមទន្លេ និងគោលការណ៍ណែនាំសម្រាប់ការធ្វើសមាហរណកម្មគ្រប់គ្រងហានិភ័យទឹកជំនន់។ បញ្ជីនេះមាននៅក្នុងឯកសារគាំទ្រ "ធ្វើការឆ្ពោះទៅយុទ្ធសាស្ត្រអភិវឌ្ឍន៍អាង តាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ហើយបញ្ជីនេះនឹងត្រូវបានធ្វើចំណាត់អាទិភាព ដោយស្ថាប័នបណ្តាញថ្នាក់ជាតិដែលពាក់ព័ន្ធនិងដោយកម្មវិធីគណៈកម្មការទន្លេមេគង្គវិស័យដើម្បីសម្រេចបាន តាមតម្រូវការបន្ទាន់ក្នុងបរិបទនៃការអភិវឌ្ឍន៍ធនធានទឹកនិងធនធានដែលពាក់ព័ន្ធកាន់តែទូលំទូលាយក្នុងអាង។



## តារាងទី៣ បញ្ជីនៃការសិក្សាផ្សេងៗដែលជាអាទិភាព

| ការសិក្សា | |
|---|---|
| ១ | កំណត់អត្តសញ្ញាណលើតំបន់ទីជម្រកអាទិភាពនិងលើចំណុចធ្ងន់ធ្ងរផ្នែកបរិស្ថាន និងលើការអភិវឌ្ឍ ការគ្រប់គ្រងផែនការសម្រាប់តំបន់ទាំងឡាយណាដែលអាចទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ឬមធ្យមតាមរយៈបម្លាស់ប្តូរស្ថានភាពលំហូរខ្លាំង និងលើទំនប់នៅតាមទន្លេមេក្នុងតំបន់អាងទន្លេមេគង្គភាគខាងក្រោម។ |
| ២ | ការកាត់បន្ថយលើផលប៉ះពាល់នៃការបង្វែរចរន្តទឹកហូរខ្លាំងទៅជាតំបន់ទឹកហូរយឺតៗរវាងទំនប់តាមទន្លេតំបន់អាងទន្លេមេគង្គភាគខាងក្រោម ដែលបានស្នើរឡើង។ |
| ៣ | ការវាយតម្លៃជម្រើសថាមពលដែលអាចផ្លាស់បាន និងសក្តានុពលវារីអគ្គីសនីតាមដៃទន្លេ និងតាមទន្លេមេ រួមទាំងគម្រោងការវារីអគ្គីសនីច្នៃប្រឌិតថ្មីដែលមិនប៉ះពាល់ដល់ចំណងទាក់ទងតំបន់ក្នុងអាងផ្នែកខាងក្រោម។ |
| ៤ | ការធ្វើម៉ូដែលលំអិតនៃផលប៉ះពាល់ដែលទាក់ទងនឹងទឹកជំនន់នៅតំបន់ខ្សែទឹកខាងលើនៃខេត្តក្រចេះដើម្បីស្វែងយល់ផលប៉ះពាល់លើបម្លាស់ប្តូរចរន្តលំហូរទឹកផ្សេងនៅកណ្តាលទន្លេមេគង្គ និងតើទំនប់វារីអគ្គិសនីនៅតាមទន្លេមេគង្គនឹងប៉ះពាល់ចរន្តលំហូរទឹកផ្សេងនៅកណ្តាលទន្លេយ៉ាងដូចម្តេច។ |
| ៥ | ការសិក្សាអំពីពហុវិស័យ និងនៅទូទាំងអាងនូវជម្រើសការគ្រប់គ្រងទឹកជំនន់រយៈពេលវែងសម្រាប់ដីសណ្តរមេគង្គ ដើម្បីឆ្លើយតបទៅនឹងកំណើនសម្ពាធពីការអភិវឌ្ឍការកើនឡើងកម្ពស់ទឹកសមុទ្រការប្រែប្រួលអាកាសធាតុ និងផែនការអភិវឌ្ឍន៍តំបន់ខ្សែទឹកខាងលើ។ |
| ៦ | ការសិក្សាពីបន្សុំការប្រែប្រួលអាកាសធាតុតំបន់អនុអាងសំដៅសំណត់និន្នាការប្រែប្រួលអាកាសធាតុ រួមទាំងហេតុការណ៍ធ្ងន់ធ្ងរនានា និងសំដៅដាក់បញ្ចូលផែនការតាមវិស័យទាក់ទងនឹងទឹករួមទាំងវារីអគ្គិសនី។ |
| ៧ | កម្មវិធីត្រួតពិនិត្យនិងវាយតម្លៃដើម្បីវិភាគពីទំនាក់ទំនងការប្រែប្រួលអាកាសធាតុលើជលសាស្ត្រអាងរយៈពេលវែង លើកសិកម្ម និងសន្តិសុខស្បៀង និងលើស្ថានភាពអេកូឡូស៊ី និងជីវចម្រុះ។ |
| ៨ | ធ្វើបច្ចុប្បន្នភាពសន្និធិទឹកក្រោមដីនៅទូទាំងអាងសំដៅកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រង។ |



# ៥.ការអនុវត្តយុទ្ធសាស្ត្រ

## ៥.១ ផែនទីបង្ហាញផ្លូវ

**សកម្មភាព គោលដៅ និងសមិទ្ធិផល:** សកម្មភាពអាទិភាពដែលចាំបាច់សម្រាប់អនុវត្តយុទ្ធសាស្ត្រនេះត្រូវបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវនៃឧបសម្ព័ន្ធ។ ផែនទីបង្ហាញផ្លូវនេះផ្តល់នូវសកម្មភាពអាទិភាពដែលចាំបាច់ជាមួយសំណើររយៈពេល និងសមិទ្ធិផលជាពិសេសសម្រាប់ដំណើរការថ្មី ឬដំណើរការដែលបានពង្រឹងដើម្បីជម្រុញគម្រោងពី "កាលានុវត្តភាព អភិវឌ្ឍន៍" ឆ្ពោះទៅដំណើរការកាន់តែកំណត់ដែលគម្រោងត្រូវបានគិតបញ្ចូលតទៅក្នុងសំណុំឯកសារគម្រោង ដែលគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនេះ។

កិច្ចពិគ្រោះយោបល់ដំបូងសម្រាប់ទំនប់ទីមួយនៅតាមទន្លេមេនៃទន្លេមេគង្គ (សាយ៉ាប្វូរី) ត្រូវបានគ្រោងនឹងបញ្ចប់នៅមុនខែមេសា ឆ្នាំ២០១១។ កិច្ចពិគ្រោះយោបល់នេះនឹងផ្តល់ជាទស្សនៈស៊ីជម្រៅទៅក្នុងការអនុវត្តជាក់ស្តែងលើអាទិភាពយុទ្ធសាស្ត្រមួយចំនួន។

**ផែនការសកម្មភាពអាង:** ផែនការសកម្មភាពអាងសម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះនឹងត្រូវបានរៀបចំនៅឆ្នាំ២០១១ ដែលក្នុងនេះមានផែនការសកម្មភាពថ្នាក់តំបន់ និងផែនការបំពេញបន្ថែមនិងផែនការចង្អុលបង្ហាញ ថ្នាក់ជាតិដែលស៊ីសង្វាក់គ្នាចំនួន៤ (ផែនការមួយសម្រាប់ប្រទេសជាសមាជិកនីមួយ)។ ផែនការនីមួយៗនឹងមានសេចក្តីអធិប្បាយមួយអំពីសកម្មភាពវិធីសាស្ត្រការអនុវត្ត និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងគោលវង្វាស់សមិទ្ធិផល និងការចំណាយនិងតម្រូវការសម្របសម្រួល។ ការរៀបចំផែនការសកម្មភាពថ្នាក់តំបន់នឹងត្រូវបានដឹកនាំធ្វើដោយគណៈកម្មការទន្លេមេគង្គ និងអនុវត្តតាមរយៈផែនការយុទ្ធសាស្ត្រឆ្នាំ ២០១១-២០១៥ របស់គណៈកម្មការទន្លេមេគង្គ។

ផែនការចង្អុលបង្ហាញថ្នាក់ជាតិ គួរតែបំពេញដំណើរ ធ្វើផែនការជាតិដែលមានពិសេសតាមរយៈការផ្តល់សកម្មភាព បន្ថែមចាំបាច់ដល់ការអនុវត្តយុទ្ធសាស្ត្រនេះ នៅក្នុងប្រទេសនីមួយៗ។ សកម្មភាពបន្ថែមទាំងនេះនឹងខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ តាមរយៈការឆ្លុះបញ្ចាំងពីភាពខុសគ្នានៃអាទិភាព និងតំបន់ដែលផ្តោតលើការរៀបចំផែនក ារ ចង្អុលបង្ហាញថ្នាក់ជាតិនេះ នឹងត្រូវបានដឹកនាំដោយគណៈកម្មាធិការជាតិទន្លេមេគង្គ ដោយមានការពិគ្រោះយោបល់ ជាមួយស្ថាប័នបណ្តាញដែលពាក់ព័ន្ធ។ ផែនការចង្អុលបង្ហាញថ្នាក់ជាតិនេះ នឹងព្យាយាមបញ្ចូលទស្សនវិស័យយុទ្ធសាស្ត្រអាងទៅក្នុងដំណើរការធ្វើផែនការជាតិ ការធ្វើសម្រេច និងអភិបាលកិច្ចរួមបញ្ចូលវិសាលភាពដែលអាចធ្វើទៅបាននូវផែនការវិស័យសេដ្ឋកិច្ចសង្គម រយៈពេល ៥ឆ្នាំ និងផែនការការងារប្រចាំឆ្នាំរបស់ស្ថាប័នជាតិដែលពាក់ព័ន្ធ។

> **ផែនការចង្អុលបង្ហាញថ្នាក់ជាតិ និងព្យាយាមបញ្ចូលទស្សនវិស័យយុទ្ធសាស្ត្រអាងទៅក្នុងដំណើរការធ្វើផែនការជាតិ ការធ្វើសេចក្តីសម្រេច និងអភិបាលកិច្ចរួមបញ្ចូលវិសាលភាព ដែលអាចធ្វើទៅនូវផែនការវិស័យសេដ្ឋកិច្ចសង្គម រយៈពេល៥ឆ្នាំ និងផែនការការងារប្រចាំឆ្នាំ។**

ដំណើរការបញ្ចូលនេះនឹងនាំអោយកើនបណ្តាញទំនាក់ទំនង រួមទាំងកំណើននៃការយល់ដឹងទូលំទូលាយ និងភាពជាម្ចាស់លើទស្សនវិស័យយុទ្ធសាស្ត្រថ្នាក់តំបន់។ កត្តានេះនឹងបង្កើនប្រសិទ្ធភាពអនុវត្តយុទ្ធសាស្ត្រនេះ ព្រមទាំងបញ្ចូលនូវទស្សនវិស័យថ្នាក់ជាតិទៅក្នុងការធ្វើបច្ចុប្បន្នកម្ម យុទ្ធសាស្ត្រនាពេលអនាគតហើយនិង "បង្កើតវឌ្ឍភាពជាម្ចាស់កម្មសិទ្ធិ" រវាងគណៈកម្មការទន្លេមេគង្គ និងបណ្តាប្រទេសជាសមាជិក ព្រមទាំងកាលានុវត្តភាពឆ្ពោះទៅមុខងារស្នូល គ្រប់គ្រងអាងទន្លេរបស់គណៈកម្មការទន្លេមេគង្គ។ កម្មវិធី ( BDP) របស់គណៈកម្មការទន្លេមេគង្គសំរាប់ឆ្នាំ ២០១១-២០១៥ ផ្តល់ការណែនាំរួមសម្រាប់ការសម្របសម្រួល និងការគាំទ្រចំពោះការអនុវត្តយុទ្ធសាស្ត្រនេះ។

## ៥.២ តួនាទី និងការទទួលខុសត្រូវ

**យុទ្ធសាស្ត្រនេះត្រូវបានគ្រប់គ្រង និងអនុវត្តដោយប្រទេសសមាជិកគណៈកម្មការមេគង្គ នៅអាងទន្លេមេគង្គភាគខាងក្រោមដែលមានការគាំទ្រ និងតាមដានដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ វាតម្រូវឱ្យមានព័ត៌មានដាក់បញ្ចូល និងដឹកនាំការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើននៅទីនោះ។**

**ភាពជាម្ចាស់ប្រទេស និងជាដៃគូទូលំទូលាយ:** យុទ្ធសាស្ត្រនេះត្រូវបានគ្រប់គ្រង និងអនុវត្តដោយប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ នៅក្នុងអាងទន្លេមេគង្គភាគខាងក្រោមដោយមានការគាំទ្រ និងតាមដានដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ វាតម្រូវឱ្យមានព័ត៌មានដាក់បញ្ចូល និងការចូលរួមពីអ្នកពាក់ព័ន្ធជាច្រើននៅទូទាំងអាង ក៏ដូចជាពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នម្ចាស់ជំនួយ។ វាតម្រូវឱ្យមានភាពជាដៃគូរដើម្បីធ្វើការអភិវឌ្ឍតម្រូវឱ្យបង្កើតបណ្តាញ និងតម្លាភាពព្រមទាំងការចូលរួម និងកិច្ចគ្រោះយោបល់ប្រកបដោយអត្ថន័យ។

ក្រុមហ៊ុនឯកជន និងវិនិយោគិននឹងទទួលបានផលប្រយោជន៍តាមរយៈការអនុវត្តគោលការណ៍ ណែនាំដែលកើតឡើងពីយុទ្ធសាស្ត្រនេះឯសង្គមស៊ីវិល (NGO's ) អាចធ្វើការបានកាន់តែជិតស្និតជាមួយគណៈកម្មការទន្លេមេគង្គ និងស្ថាប័នជាតិ។ ការបង្កើតបណ្តាញរវាងស្ថាប័នគ្រប់គ្រងធនធាននេះរបស់ប្រទេសនៅតំបន់ពាម និងអង្គការអាងទន្លេនានានៅក្នុងប្រទេសទាំងនេះ គឺជាមធ្យោបាយដ៏មានសារសំខាន់សម្រាប់ការគ្រប់គ្រងដំណើរការយុទ្ធសាស្ត្រនេះ។

**សកម្មភាពដែលបានគ្រោង និងមានស្រាប់នៃកម្មវិធីរបស់ គណៈកម្មការទន្លេមេគង្គ គឺត្រូវបានយ៉ាងរីកចំរើនជាមួយអទិភាពជាយុទ្ធសាស្ត្រ ដើម្បីធានាការឆ្លើយតបច្បាស់លាស់មួយនៅថ្នាក់តំបន់**

**កម្មវិធីគាំទ្ររបស់គណៈកម្មការទន្លេមេគង្គ:** កម្មវិធី (BDP) របស់គណៈកម្មការទន្លេមេគង្គសំរាប់ឆ្នាំ២០១១-២០១៥ នឹងជួយគាំទ្រប្រតិបត្តិការលើផែនការសកម្មភាពអាងក្នុងឆ្នាំ២០១១។ ផ្នែកមួយនៃផែនការសកម្មភាពអាងថ្នាក់តំបន់ នឹងត្រូវបានអនុវត្តដោយមានការគាំទ្រពីកម្មវិធីរបស់គណៈកម្មការទន្លេមេគង្គ នៅក្នុងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គឆ្នាំ២០១១-២០១៥។ សកម្មភាពដែលមាននិងដែលគ្រោង ដោយកម្មវិធីរបស់គណៈកម្មការទន្លេមេគង្គនឹងត្រូវវិវត្តស៊ីគ្នាជាមួយនឹងអាទិភាពយុទ្ធសាស្ត្រសំដៅធានាការឆ្លើយតបយ៉ាងធំ នៅថ្នាក់តំបន់ចំពោះអាទិភាពទាំងនេះ។ តាមការចាំបាច់ឯកសារកម្មវិធីនីមួយៗនឹងត្រូវពិនិត្យឡើងវិញ នៅក្នុងអំឡុងដំណាក់កាលចាប់ផ្តើមដើម្បីសម្រេចបានការបន្ស៊ីនេះ។

**ពង្រីកការចូលរួមទូលំទូលាយ:** ក្នុងអំឡុងពេលរៀងចំផែនការសកម្មភាពអាងសម្រាប់ការអនុវត្តយុទ្ធសាស្ត្រនេះ កិច្ចពិគ្រោះយោបល់ធំៗនឹងត្រូវរៀបចំឡើង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធក្នុងអាងនិងស្ថាប័នដទៃទៀត សំដៅយល់ព្រមលើអភិក្រមចំពោះការអនុវត្តយុទ្ធសាស្ត្រ និងការពិនិត្យឡើងវិញនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ និងដើម្បីកំណត់តួនាទី និងការទទួលខុសត្រូវរបស់ក្រុមទាំងអស់។

ក្នុងអំឡុងពេលអនុវត្តយុទ្ធសាស្ត្រនេះ វេទិកានឹងត្រូវបានរៀបចំឡើងនៅថ្នាក់ជាតិនិងថ្នាក់តំបន់ដើម្បីធ្វើការពិនិត្យអ្នកពាក់ព័ន្ធធម្មតាឡើងវិញចំពោះការអនុវត្តយុទ្ធសាស្ត្រនេះ។ ទាល់តែអ្នកពាក់ព័ន្ធនៅអាងមេគង្គ ទាំងអស់ចូលរួមយ៉ាងសកម្មដោយបើកទូលាយ និងមានតម្លាភាពប៉ុណ្ណោះ ទើបយើងអាចសម្រេចការងារប្រកបដោយមហិច្ឆតាធំ និងកិច្ចការលំបាកៗរបស់យុទ្ធសាស្ត្រនេះ ហើយនិងបន្ទាប់មកយើងអាចឆ្ពោះទៅការអភិវឌ្ឍន៍ដោយចិរភាពការកាត់បន្ថយភាពក្រីក្រ និងការធ្វើឱ្យជីវភាពរស់នៅកាន់តែប្រសើរ។

## ៥.៣ ត្រួតពិនិត្យ វាយតម្លៃ និងការធ្វើរបាយការណ៍

**ការត្រួតពិនិត្យយ៉ាងទូលំទូលាយនូវសកម្មភាព និងសមិទ្ធិផល:** កម្មវិធីត្រួតពិនិត្យយ៉ាងទូលំទូលាយនៃការអនុវត្តសកម្មភាពនិងសមិទ្ធិផលរបស់យុទ្ធសាស្ត្រនេះនឹងត្រូវបានបង្កើតឡើងក្នុងឆ្នាំ ២០១១នេះ។ ការត្រួតពិនិត្យនិងការធ្វើរបាយការណ៍ នឹងផ្តល់ឱ្យអ្នកធ្វើផែនការ អ្នកធ្វើសេចក្តីសម្រេច និងអ្នកផ្តល់មូលនិធិជាមួយព័ត៌មានចាំបាច់ក្នុងការកំណត់សម្រេច ថាតើសមិទ្ធិផលនឹងត្រូវបានសម្រេចដែរ ឬយ៉ាងណា។

កម្មវិធីតាមដាននេះ ក៏នឹងត្រូវដាក់បញ្ចូលទៅក្នុងការត្រួតពិនិត្យនិងធ្វើរបាយការណ៍អាងរបស់គណៈកម្មការទន្លេមេគង្គដែរ និងការតាមដានការប្រែប្រួលអាកាសធាតុរបស់វេទិកាទន្លេមេគង្គ ស្តីពីការប្រែប្រួលអាកាសធាតុ (MPCC) (មើលផ្នែក ៤.៣.៤ ខាងលើ) ដែលនឹងធ្វើការត្រួតពិនិត្យចុងក្រោយលើសមិទ្ធិផល និងកត្តាពាក់ព័ន្ធរបស់យុទ្ធសាស្ត្រនេះទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងធនធានរបស់អាងនេះ។





## ផែនទីបង្ហាញផ្លូវ

| សកម្មភាពអាទិភាព | គោលដៅ | សមិទ្ធិផល |
|---|---|---|
| **ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រអាង** | | |
| ១ ផែនការសកម្មភាពថ្នាក់តំបន់ | បានរៀបចំ និងអនុម័តដោយគណៈកម្មធិការរួមក្នុងឆ្នាំ ២០១១ | កម្មវត្ថុសមិទ្ធិផល និងសកម្មភាពនៅថ្នាក់តំបន់ច្បាស់លាស់ នឹងត្រូវបានអនុវត្តជាចំបងដោយផែនការយុទ្ធសាស្ត្ររបស់គណៈកម្មការទន្លេមេគង្គប៉ុន្តែក្នុងភាពជាដៃគូជាមួយអង្គការ និងកម្មវិធីនៅថ្នាក់តំបន់។<br>ប្រព័ន្ធតាមដាននឹងវាយតម្លៃថ្នាក់តំបន់ដឹកនាំដោយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។ |
| ២ ផែនការចង្អុលបង្ហាញថ្នាក់ជាតិ | បានរៀបចំ និងអនុម័តដោយគណៈកម្មធិការជាតិទន្លេមេគង្គ/អាជ្ញាធរជាតិពាក់ព័ន្ធក្នុងឆ្នាំ ២០១១ | កម្មវត្ថុគោលការណ៍ និងសកម្មភាពនៅថ្នាក់ជាតិច្បាស់លាស់ សម្រាប់ការដាក់បញ្ចូល និងការអនុវត្តអាទិភាពយុទ្ធសាសស្រ្តនៅក្នុងប្រព័ន្ធជាតិ និងក្នុងតំបន់បង្គោល។<br>ប្រព័ន្ធតាមដាន និងវាយតម្លៃថ្នាក់ជាតិត្រូវបានសម្របសម្រួលដោយស្ថាប័នគ្រប់គ្រងធនធាន/លេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គ។ |
| **អាទិភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍអាង** | | |
| ១ ផ្តោតលើកាលានុវត្តភាព និងវិបាកនៃការអភិវឌ្ឍកំពុងដំណើរការ | វិធានការត្រូវបានឯកភាពយល់ព្រមនៅចុងឆ្នាំ ២០១១ សកម្មភាពអនុវត្តមុនឆ្នាំ ២០១៣ | កិច្ចសហប្រតិបត្តិការថ្នាក់តំបន់ផ្តល់តម្លៃបន្ថែមចំពោះកាលានុវត្ត ភាពអភិវឌ្ឍន៍ និងសកម្មភាពកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដោយប្រទេសជាសមាជិក។ |
| ២ ពង្រីកនិងធ្វើឱ្យមានប្រពលភាពកសិកម្មប្រព័ន្ធស្រោចស្រព | គោលការណ៍ណែនាំនឹងត្រូវបានរៀបចំមុនឆ្នាំ ២០១៣ និង អនុវត្តមុនឆ្នាំ ២០១៥ | បង្កើនសន្តិសុខស្បៀង និងកាលានុវត្តភាពសម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅតាមបណ្តាលប្រទេសក្នុងអាងទន្លេមេគង្គក្រោម និងក្នុងតំបន់។ |
| ៣ បង្កើនការអភិវឌ្ឍវារីអគ្គិសនីដោយចីរភាព | នឹងរៀបចំឱ្យបានមុនឆ្នាំ ២០១៣ អនុវត្តបន្តបន្តចាប់ពីនោះទៅ | ការជម្រុញស្ថានភាព និងគោលការណ៍ណែនាំ "ត្រូវបានបញ្ចូល" ឱ្យដំណើរការក្នុងការធ្វើផែនការជាតិ និងប្រព័ន្ធនិយ័តករ និងបានអនុវត្តដោយក្រុមហ៊ុនគម្រោងដោយនិយ័តករ និងដោយស្ថាប័នជាតិ។ |
| ៤ ទទួលបានចំណេះដឹងដើម្បីផ្តោតការយកចិត្តទុកដាក់លើភាពមិនច្បាស់លាស់ និងហានិភ័យ | ព័ម៌មានបន្ទាន់បំផុតអាចរកបាន និងត្រូវបានដាក់ឱ្យប្រើប្រាស់មុនឆ្នាំ ២០១៣ | ប្រព័ន្ធត្រួតពិនិត្យ (កំណល្បាប់ ជលផលនិងបញ្ហាសង្គម)ដំណើរការ និងទិន្នន័យអាចរកបានសម្រាប់ការធ្វើវិភាគ និងការធ្វើសេចក្តីសម្រេច។ |

| | | |
|---|---|---|
| ៥ ស្វែងរកជម្រើសការបែងចែកផលប្រយោជន៍ និងការចំណាយ | ជម្រើសនឹងត្រូវបានរៀបចំនៅមុនឆ្នាំ ២០១៤ និងអនុវត្តជាបន្ត | កាន់តែមានជម្រើសដោយចីរភាពសម្រាប់ការអភិវឌ្ឍធនធានទឹកដែលលើកស្ទួយដល់កិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តាប្រទេស។ |
| ៦ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | យុទ្ធសាស្ត្របន្សាំនឹងត្រូវបានបង្កើនឡើងមុនឆ្នាំ ២០១៣ | យុទ្ធសាស្ត្របន្សាំត្រូវបានបញ្ជ្រាបទៅក្នុងការធ្វើផែនការជាតិ និងផែនការអាង។<br>បង្កើនការគ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត<br>ការធ្វើផែនការបន្សាំត្រូវបានសាកល្បងសម្រាប់វិស័យពាក់ព័ន្ធសម្រាប់ប្រព័ន្ធធម្មជាតិ និងសម្រាប់ក្រុមងាយរងគ្រោះ។<br>ការអភិវឌ្ឍធនធានទឹកថ្នាក់ជាតិនិងផែនការ និងគម្រោងបន្តទៅមុខនៅក្នុងក្របខ័ណ្ឌកាលានុវត្តភាពអភិវឌ្ឍន៍ (DOS) ដែលបានកំណត់រួចស្របទៅនឹងគោលការណ៍ណែនាំ និងអាទិភាពយុទ្ធសាស្ត្រ។ |
| ៧ បញ្ចូលការគិតគូអំពីអាងទៅក្នុងប្រព័ន្ធជាតិ | បន្ត | ការអភិវឌ្ឍ ធនធានទឹកថ្នាក់ជាតិ និងផែនការ និងគម្រោង បន្ត ទៅមុខនៅ ក្នុង ក្របខ័ណ្ឌកាលានុវត្តភាព អភិវឌ្ឍន៍ ដែលបាន់កំណត់រួច ស្របទៅនឹងគោលការណ៍ណែនាំ និងអាទិភាពយុទ្ធសាស្ត្រ។ |
| **អាទិភាពយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងអាង** | | |
| ១ បង្កើនទស្សនវិស័យអាង និងយុទ្ធសាស្ត្រគ្រប់គ្រងវិស័យទាក់ទងនឹងទឹក | ទស្សនវិស័យនឹងត្រូវបានរៀបចំហើយមុនឆ្នាំ ២០១២ចំណែកយុទ្ធសាស្ត្រគ្រប់គ្រងនឹងត្រូវបានរៀបចំហើយមុនឆ្នាំ ២០១៤ | យុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍអាងនិងការគ្រប់គ្រងវិស័យទាក់ទងនឹងទឹក ត្រូវបានយល់ព្រម(ជលផលនាវាចរណ៍ ការគ្រប់គ្រងទឹកជំនន់ទេសចរណ៍បរិស្ថាន និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីការគ្រប់គ្រងទីជម្រាល)។ |
| ២ ពង្រឹងដំណើរការគ្រប់គ្រងធនធានទឹកចម្រុះថ្នាក់ជាតិ | បន្ត | ទិន្នន័យមូលដ្ឋានដែលទាក់ទងនឹងស្ថានភាពនិងការប្រើប្រាស់ធនធា ទឹកដែលមាន និងដែលអាចរកបានសម្រាប់មនុស្សគ្រប់រូប។ |
| ៣ ពង្រឹងដំណើរការគ្រប់គ្រងអាង | បន្ត | និតីវិធីសាស្ត្រ ឧបករណ៍ និងដំណើរការអាង (ថ្នាក់តំបន់) និងថ្នាក់ជាតិត្រូវបានពង្រឹង និងធ្វើអោយស៊ីសង្វាក់គ្នាដែលនាំដល់ការកើនឡើងនូវកិច្ចសហប្រតិបត្តិការអាងទាំងមូលសម្រាប់ការគ្រប់គ្រងនិងការអភិវឌ្ឍអាងដោយចីរភាព។ |

| | | |
|---|---|---|
| ៤ បង្កើតសូចនាករអាង មូលដ្ឋានគោលលើ ផ្នែកសង្គមនិងបរិស្ថាន | នឹងត្រូវបានរៀបចំហើយមុន ឆ្នាំ ២០១៣ | កម្រងសូចនាករសង្គម និងជីវសាស្ត្រអាង ដែលនឹងត្រូវបានប្រើប្រាស់ដើម្បីវាយតម្លៃ ដល់ការអភិវឌ្ឍនាពេលអនាគត ទទួលបាន ការយល់ព្រម។ |
| ៥ កសាងសមត្ថភាព សម្រាប់ការគ្រប់គ្រង ធនធានទឹកចម្រុះ នៅកម្រិតអាង | បន្ត | ការសម្របសម្រួល និងការផ្លាស់ប្តូរទិន្នន័យ និងព័ត៌មានរវាង បណ្តាញស្ថាប័នថ្នាក់ជាតិ បានបង្កើនឱ្យប្រសើរ។ កាលានុវត្តភាព ការគ្រប់គ្រងនិងការអភិវឌ្ឍ ផលប្រយោជន៍ទៅវិញទៅមកនៅកម្រិតអាង។ |
| **គោលការណ៍នាំ និងការសិក្សាដែលមានអាទិភាព** | | |
| ១ ការសិក្សាដែលមាន អាទិភាព | នឹងត្រូវបញ្ចប់មុនឆ្នាំ ២០១៥ | គម្លាតចំណេះដឹងសំខាន់ៗសម្រាប់ធ្វើផែន ការ និងធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍ នាពេលអនាគតត្រូវបាន “បំពេញ“ ជាមួយព័ត៌មានដែលត្រូវការចាំបាច់។ |
| ២ គោលការណ៍ណែនាំ | គោលការណ៍ណែនាំចំនួន៥ នឹងបញ្ចប់ មុនឆ្នាំ ២៩១៥។ គោលការណ៍ណែនាំទាំងអស់ នឹងបពាប់មុនឆ្នាំ ២០២០ | សហការធ្វើផែនការតាមរយៈការប្រើប្រាស់ និងការគ្រប់គ្រងធនធានទឹក។ |
| **ការតាមដាន និងវាយតម្លៃ** | | |
| ១ ការត្រួតពិនិត្យ | នឹងត្រូវបង្កើតឡើងក្នុងឆ្នាំ ២០១១ នឹងត្រូវប្រតិបត្តិមុនឆ្នាំ | អ្នកធ្វើផែនការ និងអ្នកធ្វើសេចក្តីសម្រេច មានព័ត៌មានអំពីស្ថានភាព និងផលប៉ះពាល់ អំពីផែនការរបស់ខ្លួនគ្រប់ពេល។ |
| ២ ការវាយតម្លៃ | ក្នុងឆ្នាំ ២០១៥ | ព័ត៌មានតើយុទ្ធសាស្ត្រអភិវឌ្ឍអាងចាំបាច់ ត្រូវកែតម្រូវដែរ និងឬយ៉ាងដូចម្តេច។ |
| ៣ ការធ្វើបច្ចុប្បន្នភាព | ក្នុងឆ្នាំ ២០១៥ | យុទ្ធសាស្ត្រអភិវឌ្ឍអាង បានធ្វើបច្ចុប្បន្នភាព ផ្អែកតាមព័ត៌មានថ្មីទាក់ទងទៅនឹងតម្រូវការ កាលានុវត្តភាព និងឧបសគ្គ។ |



Mekong River Commission
Cambodia • Lao PDR • Thailand • Viet Nam

For more information, visit
www.mrcmekong.org

**Office of the Secretariat in Phnom Penh (OSP)**
576 National Road, #2, Chak Angre Krom,
P.O. Box 623, Phnom Penh, Cambodia
Tel: (855-23) 425 353.
Fax: (855-23) 425 363

**Office of the Secretariat in Vientiane (OSV)**
Office of the Chief Executive Officer
184 Fa Ngoum Road,
P.O. Box 6101, Vientiane, Lao PDR
Tel: (856-21) 263 263.
Fax: (856-21) 263 264


March 2013

